**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

តាក់តែងឡើងដោយ

និស្សិតឈ្មោះ កញ្ញា **នួន សាវលក្ខ័**

កញ្ញា **ប៉ា សុគី**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **សួន ចំរើន**

ថ្នាក់បរិញ្ញាបត្រ **គ្រប់គ្រងធុរកិច្ច**

ជំនាន់ទី៧

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **នួន សាវលក្ខ័** និង **ប៉ា សុគី** ដែលជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ច ឆ្នាំទី៤ ជំនាន់ទី៧ ក្រុម M4C3 ក្នុងឆ្នាំសិក្សា២០២២-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ “ **ប្រតិបត្តិការបរធនបាលកិច្ចនៅប្រទេសកម្ពុជា**” ដើម្បីធ្វើជាសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

**សូមគោរពថ្លែងអំណរគុណ និងសំដែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ៖**

- លោកឪពុក និងអ្នកម្តាយ ជាអ្នកមានគុណដ៏ក្រៃលែង ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅ ទំនុកបំរុងរាល់ការខ្វះខាត និងផ្គត់ផ្គង់រាល់សម្ភារៈប្រើប្រាស់ និងថវិកា ដែលអាចឱ្យកូនមានឱកាសបានក្រេបជញ្ជក់ចំណេះវិជ្ជា ដើម្បីជាវិថីឆ្ពោះទៅកាន់ថ្ងៃអនាគតដ៏ល្អមួយសម្រាប់រូបកូន។ ហើយលោកទាំងពីរក៏បានពលីទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីធ្វើឱ្យកូនបានក្លាយខ្លួនជាកូនល្អ និងពលរដ្ឋល្អក្នុងសង្គមដូចសព្វថ្ងៃនេះ
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង លោក លោកស្រី សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ក្នុងការអប់រំទូន្មាន បង្ហាត់បង្រៀន និងខិតខំផ្តល់ចំណេះដឹងដល់យើងខ្ញុំ ដោយមិនខ្លាចនឿយហត់ក្នុងការបណ្តុះបណ្តាលឱ្យយើងខ្ញុំក្លាយជាធនធានមនុស្សដ៏មានគុណភាព ដើម្បីបំពេញតម្រូវការសង្គម និងប្រទេសជាតិ
- លោកសាស្ត្រាចារ្យជំនួយ **សួន ចំរើន** ជាសាស្ត្រាចារ្យណែនាំក្នុងការសិក្សាស្រាវជ្រាវ និងសរសេររបាយការណ៍បញ្ចប់ការសិក្សារបស់យើងខ្ញុំ។ លោកសាស្ត្រាចារ្យក៏បានជួយណែនាំ ចង្អុលបង្ហាញ ផ្តល់ជាអនុសាសន៍ ល្អៗ និងព័ត៌មានពាក់ព័ន្ធជាច្រើន ដើម្បីជាជំនួយក្នុងការសិក្សាស្រាវជ្រាវ និងសរសេររបាយការណ៍នេះឡើង។ជាពិសេស លោកបានផ្តល់ជាយោបល់និងជួយកែតម្រូវនូវរាល់ចំណុចខ្វះខាត ដែលកើតមានឡើងជាយថាហេតុក្នុងអំឡុងពេលនៃការរៀបចំរបាយការណ៍បញ្ចប់ការសិក្សានេះផងដែរ
- ឯកឧត្តមអគ្គនាយក និងឯកឧត្តមអគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករបរធនបាលកិច្ចទាំងអស់ ដែលបានអនុញ្ញាត និងណែនាំយើងខ្ញុំទាំងពីរ មានឱកាសស្វែងយល់ និងសិក្សាស្រាវជ្រាវរាល់ឯកសារមួយចំនួនពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ក៏ដូចជាប្រតិបត្តិការបរធនបាលកិច្ចនៅកម្ពុជានេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមធ្វើការគោរព ការដឹងគុណ និងសូមជូនពរដល់អ្នកមានគុណទាំងអស់ ជួបប្រទះតែសេចក្តីសុខ សុភមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លាងឃ្លៀតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សានេះ គឺជាលទ្ធផលដែលកើតចេញពីការស្រាវជ្រាវ និងចងក្រងយ៉ាងយកចិត្តទុកដាក់បំផុត ដោយផ្អែកទៅតាមចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ដែលបានបង្កើតឱ្យមានទីផ្សារបរធនបាល ដើម្បីជាមធ្យោបាយនៅក្នុងការប្រមូលមូលធន។ បរធនបាលកិច្ច កើតឡើងមកពីបន្សំនៃពាក្យ៖ "បរ+ធន+បាល+កិច្ច" ដែល "បរ" មាន ន័យថា ខាងក្រៅឬទីទៃឬដទៃ, "ធន" មានន័យថា ទ្រព្យឬសម្បត្តិ, "បាល" មានន័យថា អ្នកគ្រប់គ្រងឬអ្នកថែរក្សា, និង "កិច្ច" មានន័យថា ការងារឬកិច្ចការដែលត្រូវធ្វើ។ ដូចនេះ **បរធនបាលកិច្ច** មានន័យថា ជាកិច្ចការរបស់អ្នកថែរក្សាទ្រព្យ ខាងក្រៅ ឬទ្រព្យរបស់អ្នកដទៃ។ តាមន័យច្បាប់ បរធនបាលកិច្ច ជាទំនាក់ទំនងគតិយុត្ត ដែលបរធនបាលទាយកផ្តល់ ទ្រព្យដល់បរធនបាលក្នុងការមើលថែរក្សា និងប្រើប្រាស់ជាប្រយោជន៍ដល់អត្ថគាហកៈ។បរធនបាលកិច្ច ត្រូវបានបង្កើតឡើងដោយបរធនបាលទាយក ឬបទប្បញ្ញត្តិជាធរមាន និងត្រូវមានកម្មវត្ថុស្របច្បាប់ និងមិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។

ចំណែកឯ **និយ័តករបរធនបាលកិច្ច** គឺជាអាជ្ញាធរមួយ ដែលត្រូវអនុវត្តនូវមុខងារគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍ វិស័យបរធនបាលកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**វិស័យបរធនបាលកិច្ច** គឺជាវិស័យហិរញ្ញវត្ថុមិនមែនធនាគារមួយ ដែលមានប្រតិបត្តិការពាក់ព័ន្ធនឹងធុរកិច្ចរបស់ អ្នកគ្រប់គ្រង អ្នកមើលថែរក្សា ឬអ្នកចាត់ចែងទ្រព្យសម្បត្តិរបស់បុគ្គលផ្សេងទៀត សម្រាប់ជាប្រយោជន៍ដល់បុគ្គល ឬក្រុម គោលដៅ ណាមួយ ដែលត្រូវបានគេហៅថា "អត្ថគាហកៈ" និងត្រូវស្ថិតក្រោម ឬអនុលោមទៅតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ដូច្នេះហើយ ទើបធ្វើឱ្យយើងខ្ញុំទាំងពីរនាក់ បានធ្វើការរៀបចំនូវសារណាបញ្ចប់ការសិក្សាលើប្រធានបទស្តីពី **ប្រតិបត្តិការ បរធនបាលកិច្ចនៅប្រទេសកម្ពុជា** ដើម្បីយកមកបង្ហាញដល់ភាគីពាក់ព័ន្ធ វិនិយោគិន និងសារធារណៈជន ក៏ដូចជាសិស្ស-និស្សិត ដែលមានបំណងចង់ដឹង និងស្វែងយល់កាន់តែច្បាស់បន្ថែមពីវិស័យនេះ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងចូលរួមចំណែកក្នុងការបង្កើននូវចំណេះដឹងទាក់ទងនឹងវិស័យបរធនបាលកិច្ច ក៏ដូចជាប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ព្រមទាំងការជួយជំរុញលើកទឹកចិត្តដល់សិស្ស-និស្សិត វិនិយោគិន និងសារធារណៈជន ក៏ដូចជាភាគីពាក់ព័ន្ធ ឱ្យចូលរួមចំណែកកាន់តែច្រើននៅក្នុងវិស័យនេះ ក្នុងគោលបំណង ទទួលបាននូវអត្ថប្រយោជន៍នានាពីការវិនិយោគនៅក្នុងវិស័យនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមអភ័យទោសចំពោះរាល់កំហុសខុសឆ្គង ដែលកើតឡើងដោយប្រការណាមួយ និងសូមស្វាគមន៍ចំពោះរាល់មតិរិះគន់ស្ថាបនានានាពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស-និស្សិត និងមិត្តអ្នកអានគ្រប់រូប ដើម្បីធ្វើការកែលម្អសារណាមួយនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

# មាតិកា

ទំព័រ

បញ្ជីអក្សរកាត់ ........ v

បញ្ជីរូបភាព ........ vi

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣

៦. សារៈប្រយោជន៍នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១. ការកកើតនៃវិស័យបរធនបាលកិច្ច ........ ៦

១.២. តើអ្វីទៅជាបរធនបាលកិច្ច? ........ ៦

១.៣. តួអង្គសំខាន់ៗនៅក្នុងវិស័យបរធនបាលកិច្ច ........ ៧

១.៣.១. បរធនបាលទាយក ........ ៧

១.៣.២. បរធនបាល ........ ៨

១.៣.៣. អត្ថគាហកៈ (អ្នកទទួលផលប្រយោជន៍) ........ ៨

១.៤. អ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ច ........ ៩

១.៤.១. អាជ្ញាធរគ្រប់គ្រងវិស័យបរធនបាលកិច្ច ........ ៩

១.៤.២. ប្រតិបត្តិករ ........ ៩

១.៤.២.១. ក្រុមហ៊ុនបរធនបាល ........ ៩

១.៤.២.២. បរធនបាលរូបវន្តបុគ្គល ........ ៩

១.៤.២.៣. ប្រតិបត្តិករផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុក ........ ១០
១.៤.២.៤. ក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្ម ........ ១១
១.៤.២.៥. ក្រុមហ៊ុនវាយតម្លៃ ........ ១១
១.៤.៣. វិនិយោគិន ........ ១១
១.៥. ប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ........ ១២
១.៦. តួនាទីនៃវិស័យបរធនបាលកិច្ចនៅក្នុងដំណើរការសេដ្ឋកិច្ច........ ១២
១.៧. សារៈសំខាន់នៃវិស័យបរធនបាលកិច្ច........ ១៣

## ជំពូកទី២

## និយ័តករបរធនបាលកិច្ច ( ន.ប.ធ. )

២.១. ការកកើតនៃនិយ័តករបរធនបាលកិច្ច ........ ១៤
២.២. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ........ ១៥
២.២.១. រូបសញ្ញា........ ១៥
២.២.២. អត្ថន័យនៃរូបសញ្ញា........ ១៦
២.៣. ទីតាំងរបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)........ ១៦
២.៤. ចក្ខុវិស័យ និងបេសកកម្មរបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ........ ១៦
២.៤.១. ចក្ខុវិស័យ ........ ១៦
២.៤.២. បេសកកម្ម........ ១៧
២.៥. អង្គការចាត់តាំង ........ ១៧
២.៦. រចនាសម្ព័ន្ធគ្រប់គ្រង........ ១៧
២.៧. មុខងារ និងតួនាទីរបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)........ ១៨
២.៧.១.គោលនយោបាយយុទ្ធសាស្ត្រ........ ១៨
២.៧.២.គ្រប់គ្រង និងត្រួតពិនិត្យវិស័យ ........ ១៩
២.៧.៣.អភិវឌ្ឍវិស័យបរធនបាលកិច្ច ........ ១៩
២.៨. មុខងារ និងតួនាទីនាយកដ្ឋានចំណុះរបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)........ ១៩
២.៨.១. នាយកដ្ឋានកិច្ចការទូទៅ........ ១៩
២.៨.២. នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ........ ២០

២.៨.៣. នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច ........ ២១
២.៨.៤. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ ........ ២២

## ជំពូកទី៣
## ប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា

៣.១.ទិន្នន័យពាក់ព័ន្ធនិងវិស័យបរធនបាលកិច្ច ........ ២៤
៣.១.១.បរធនបាលជំនួស ........ ២៤
៣.១.២.ក្រុមហ៊ុនដែលបានចុះបញ្ជីក្នុងនិយ័តករបរធនបាលកិច្ច ........ ២៤
៣.១.៣.បញ្ជីឈ្មោះក្រុមហ៊ុនបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និងការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច. ........ ២៥
៣.១.៤.បញ្ជីឈ្មោះបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ច ........ ២៦
៣.១.៥.បញ្ជីឈ្មោះប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ........ ២៨
៣.១.៦.បញ្ជីឈ្មោះក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ........ ២៨
៣.១.៧.សេចក្តីសម្រេច ឬគោលការណ៍ណែនាំ ........ ២៩
៣.២. ប្រតិបត្តិការបរធនបាលកិច្ច ........ ៣០
៣.២.១. បរធនបាលកិច្ចបុគ្គល ........ ៣០
៣.២.២. បរធនបាលកិច្ចសង្គម ........ ៣០
៣.២.៣. បរធនបាលកិច្ចពាណិជ្ជកម្ម ........ ៣១
៣.២.៤. បរធនបាលកិច្ចហិរញ្ញវត្ថុ ........ ៣២
៣.២.៥. បរធនបាលកិច្ចសាធារណៈ ........ ៣២
៣.៣.ប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ច ........ ៣២
៣.៣.១.ការចុះបញ្ជីបរធនបាល ........ ៣២
៣.៣.២.ការត្រួតពិនិត្យបរធនបាលកិច្ច ........ ៣៣
៣.៣.៣. ការបញ្ចប់បរធនបាលកិច្ច ........ ៣៣
. ៣.៣.៤. កិច្ចគាំពារវិនិយោគិនក្នុងវិស័យបរធនបាលកិច្ច ........ ៣៤
៣.៣.៤.១. ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច ........ ៣៤

៣.៣.៤.២. ការធ្វើអធិការកិច្ចក្នុងវិស័យបរធនបាលកិច្ច......................................................................៣៤
៣.៣.៤.៣. ការពិនិត្យ និងការស៊ើបអង្កេតបទល្មើសក្នុងវិស័យបរធនបាលកិច្ច.................................៣៥
៣.៣.៤.៤. ការប្ដឹងតវ៉ាពីវិធានការរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច........................................៣៥
៣.៣.៤.៥. វិធានសម្រាប់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចក្នុងការប្រតិបត្តិការអនុវត្តច្បាប់.................៣៦
៣.៣.៤.៦. ការផាកពិន័យចំពោះប្រតិបត្តិការដែលមិនបានមកស្នើសុំចុះបញ្ជីបរធន........................៣៦
៣.៣.៤.៧. ការផាកពិន័យចំពោះការមិនរាយការណ៍ ការមិនផ្ដល់ព័ត៌មាន....................................៣៦
៣.៣.៤.៨. ការផ្ដន្ទាទោសចំពោះបុគ្គលដែលប្រព្រឹត្តល្មើសក្នុងវិស័យបរធនបាលកិច្ច......................៣៧
៣.៣.៤.៩.ការផ្ដន្ទាទោសពិន័យជាប្រាក់ចំពោះបរធនបាលដែលប្រព្រឹត្តល្មើស...............................៣៧
៣.៣.៤.១០.បណ្ដឹងតវ៉ាពីសេចក្ដីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច..............................៣៩
៣.៤.ការវិនិយោគលើវិស័យបរធនបាលកិច្ច...........................................................................................៣៩
៣.៤.អត្ថប្រយោជន៍នៃការវិនិយោគក្នុងវិស័យបរធនបាលកិច្ច............................................................. ៤០
៣.៥.១.អត្ថប្រយោជន៍នៃបរធនបាលទាយក........................................................................................ ៤២
៣.៥.២.អត្ថប្រយោជន៍នៃអត្ថគាហកៈ ........................................................................................៤២

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ..........................................................................................................................៤៣
២. ការផ្ដល់អនុសាសន៍ ........................................................................................................................ ៤៤
**ឯកសារយោង** .........................................................................................................................៤៥
**ឧបសម្ព័ន្ធ**..................................................................................................................................៤៨

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| **អ.ស.ហ.** | ៖ | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| **ន.ប.ធ.** | ៖ | និយ័តករបរធនបាលកិច្ច |
| **ន.ម.ក.** | ៖ | និយ័តករមូលបត្រកម្ពុជា |
| **ន.អ.ប.** | ៖ | និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ |
| **ន.គ.ស.** | ៖ | និយ័តករគណនេយ្យ និងសវនកម្ម |
| **FinTech** | ៖ | Financial Technology |
| **Trust Tech** | ៖ | Trust Technology |

# បញ្ជីរូបភាព


រូបភាព ១.១  តួអង្គសំខាន់ៗនៅក្នុងវិស័យបរធនបាលកិច្ច....................................................................៧
រូបភាព ១.២  អគ្គគាហកៈ (អ្នកទទួលផលប្រយោជន៍) .......................................................................... ៨
រូបភាព ១.៤.២ ប្រតិបត្តិការបរធនបាល ................................................................................................ ១០
រូបភាព ២.១. ស្លាកសញ្ញារបស់និយ័តករបរធនបាលកិច្ច ..................................................................... ១៥
រូបភាព ២.២.អង្គការលេខរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ............................................ ១៧
រូបភាព ២.៣.រចនាសម្ព័ន្ធរបស់និយ័តករបរធនបាលកិច្ច.................................................................. ១៨

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ ហើយស្របជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលបាន នឹង កំពុងខិតខំប្រឹងប្រែងអនុវត្តន៍នូវគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដើម្បីធ្វើការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនឈានទៅមុខជាលំដាប់។ ទន្ទឹមនឹងនេះ វិស័យហិរញ្ញវត្ថុបានដើរតួយ៉ាងសំខាន់ក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចក្នុងប្រទេសតាមរយៈការប្រមូលកៀរគរមូលធនពីអ្នកដែលមិនត្រូវការប្រើប្រាស់ ហើយទុកមូលធនទំនេរចោលនោះប្រគល់ឱ្យទៅអ្នកដែលមានតម្រូវការប្រើប្រាស់ ដើម្បីយកទៅវិនិយោគ ក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ប្រកបដោយប្រសិទ្ធភាព។ តាមរយៈការលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា រាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់នូវច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលតាមរយៈច្បាប់នេះដែរ ក៏បានបង្កើតឱ្យមាននូវនិយ័តករចំនួន ៦ សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យតាមផ្នែកនីមួយៗនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងនោះនិយ័តករបរធនបាលកិច្ច ឬសរសេរកាត់ថា **ន.ប.ធ.** ត្រូវបានបង្កើតឡើងផងដែរ ដែលជានិយ័តករមួយ សម្រាប់គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ព្រមទាំងអនុវត្តនូវមុខងារផ្សេងទៀតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាមួយគ្នានេះដែរ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯក-ឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទីផ្សារបរធនបាលកិច្ច ត្រូវបានប្រកាសដាក់ឱ្យប្រើ-ប្រាស់ជាផ្លូវការ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ កន្លងទៅនេះផងដែរ។ តាមរយៈការលេចឡើងនៃទីផ្សារបរ-ធនបាលកិច្ចនេះ គឺជាជម្រើសដ៏ថ្មីមួយបន្ថែមទៀត សម្រាប់តួអង្គ និងភាគីពាក់ព័ន្ធ ក៏ដូចជាវិនិយោគិននៅក្នុងវិស័យបរធនបាលកិច្ច អាចចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យកាន់តែរីកលូតលាស់ជាលំដាប់បន្ថែមទៀត។ ដោយឡែក សម្រាប់ប្រទេសកម្ពុជាផ្ទាល់វិញ វិស័យបរធនបាលកិច្ច អាចចាត់ទុកជាវិស័យដ៏ក្មេងខ្ចីមួយផងដែរ ដែលជាហេតុធ្វើឱ្យតួអង្គ អ្នកចូលរួម និងភាគីពាក់ព័ន្ធ ក៏ដូចជាវិនិយោគិននៅក្នុងវិស័យនេះ ព្រមទាំងសាធា-រណជនជាច្រើននៅពុំទាន់មានការយល់ដឹងបានទូលំទូលាយពាក់ព័ន្ធនឹងការប្រតិបត្តិនៅក្នុងវិស័យនេះនៅឡើយទេ។

ជាមួយគ្នានេះ ដើម្បីផ្តល់ភាពរលូននៃដំណើរការទីផ្សារបរធនបាលកិច្ចនៅកម្ពុជា **ន.ប.ធ.** ត្រូវបានបង្កើតឡើង និងដើរតួយ៉ាងសំខាន់ក្នុងការតាក់តែងច្បាប់ លក្ខខណ្ឌតម្រូវ នីតិវិធីប្រតិបត្តិការ ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងព័ត៌មានអំពីវិស័យនេះដល់សាធារណជន តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល ក៏ដូចជាបណ្តាញសង្គម និងនៅលើគេហទំព័រផ្លូវការនានារបស់ **ន.ប.ធ.** ផងដែរ។

ហេតុដូច្នេះហើយ បានជាយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី «**វិស័យបរធនបាលកិច្ចនៅប្រទេស កម្ពុជា**» មកធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយ ជូនសាធារណជនយល់ដឹងកាន់តែច្បាស់បន្ថែមទៀតអំពីវិស័យនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ ហើយស្របជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបាននឹងកំពុង បន្តខិតខំប្រឹងប្រែងអនុវត្តន៍នូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីធ្វើការអភិវឌ្ឍសេដ្ឋ-កិច្ចជាតិឱ្យមានការ រីកចម្រើនឈានទៅមុខជាលំដាប់។ ទន្ទឹមនឹងនេះដែរ វិស័យហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាបាននូវ កំណើនសេដ្ឋកិច្ចជាតិ និងការវិនិយោគនានា ដើម្បីស្វែងរកប្រាក់ចំណេញប្រកបដោយប្រសិទ្ធភាព។ តាមរយៈការ អភិវឌ្ឍយ៉ាងឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា រាជរដ្ឋាភិបាលបានដាក់ឱ្យមានដំណើរការទីផ្សារបរធនបាលកិច្ចនៅកម្ពុជា កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ កន្លងទៅ ដែលការលេចឡើងនៃទីផ្សារបរធនបាលកិច្ចនេះ គឺជាជម្រើសដ៏ថ្មីមួយបន្ថែមទៀត សម្រាប់ការវិនិយោគនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្រៅពីការវិនិយោគជាមួយនឹងវិស័យ ធនាគារ វិស័យមូលបត្រ ក៏ដូចជាវិស័យអចលនទ្រព្យ ជាដើម។ សម្រាប់ប្រទេសកម្ពុជាផ្ទាល់ ទីផ្សារបរធនបាលកិច្ច អាចត្រូវបានចាត់ទុកថាជាវិស័យដ៏ក្មេងខ្ចីមួយផងដែរ ដែលធ្វើឱ្យតួអង្គ អ្នកចូលរួម និងភាគីពាក់ព័ន្ធ ក៏ដូចជាវិនិយោគិននៅក្នុងវិស័យនេះ ព្រមទាំងសារធារណជនជាច្រើនមិនទាន់មានការយល់ដឹងទូលំទូលាយ និងស៊ីជម្រៅអំពីយន្តការ និងនីតិវិធីក្នុងការប្រតិបត្តិ ក៏ដូចជាអត្ថប្រយោជន៍ផ្សេងៗនៅក្នុងវិស័យមួយនេះបានច្បាស់នៅឡើយ។

ដោយការសម្លឹងមើលឃើញនូវចំណុចខ្វះខាតនេះហើយ ទើបធ្វើឱ្យមានការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី «**វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា**» នេះឡើង ដើម្បីឆ្លើយតបនឹងតម្រូវការរបស់តួអង្គ អ្នកចូលរួម ភាគីពាក់ព័ន្ធ វិនិយោគិន និងសារធារណៈជន ក៏ដូចជាសិស្ស-និស្សិត ដូចខាងក្រោម៖

- តើអ្វីទៅជា វិស័យបរធនបាលកិច្ច?
- តើអ្នកចូលរួម និងភាគីពាក់ព័ន្ធនៅក្នុងវិស័យបរធនបាលកិច្ចត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ទើបអាចចូលរួមនៅក្នុង ប្រតិបត្តិការនៃវិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជាបាន?
- តើទីផ្សារបរធនបាលកិច្ច ដែលបានដាក់ឱ្យដំណើរការជាផ្លូវការនេះនាំមកនូវអត្ថប្រយោជន៍អ្វីខ្លះដល់អ្នកចូលរួម ភាគីពាក់ព័ន្ធ វិនិយោគិន និងសេដ្ឋកិច្ចជាតិ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **«វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា»** នេះគឺផ្តោតសំខាន់ទៅលើ បទប្បញ្ញត្តិគ្រប់គ្រង និងត្រួតពិនិត្យនៅក្នុងវិស័យបរធនបាលកិច្ច និងតួអង្គសំខាន់ៗនៅក្នុងវិស័យនេះ។

គោលបំណងជាក់លាក់នៃការសិក្សាស្រាវជ្រាវនេះ ដូចខាងក្រោម៖

- ស្វែងយល់ពីនិយ័តករបរធនបាលកិច្ចកម្ពុជា
- ស្វែងយល់ពីប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា
- ស្វែងយល់ពីដំណើរការនៃទីផ្សារបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា
- ស្វែងយល់ពីប្រភេទផ្សេងៗនៃបរធនបាលកិច្ចនៅប្រទេសកម្ពុជា ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាទៅលើវិស័យបរធនបាលកិច្ចមានលក្ខណៈធំទូលាយ និងមានរយៈពេលច្រើនឆ្នាំមកហើយ បើគិតចាប់ពីពេលដាក់ឱ្យដំណើរការដំបូងរហូតមកដល់បច្ចុប្បន្ន។ ដូចនេះហើយទើបការសិក្សាលើប្រធានបទមួយនេះ ត្រូវបានផ្តោតសំខាន់តែលើយន្តការ នីតិវិធី និងលក្ខខណ្ឌតម្រូវ សម្រាប់ធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា ចាប់ពីឆ្នាំ២០០៨ ជាមួយទិន្នន័យត្រឹមត្រីមាសទី១ ឆ្នាំ២០២៣ នេះតែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

➢ **ការប្រមូលទិន្នន័យ**

ការប្រមូលទិន្នន័យ និងព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺពឹងផ្អែកលើប្រភពទិន្នន័យដែលមានស្រាប់ (បន្ទាប់បន្សំ) រួមមាន៖

✓ គេហទំព័ររបស់ **ន.ប.ធ.**

✓ ច្បាប់ អនុក្រឹត្យ និងប្រកាសនានា ចេញដោយរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច

✓ ឯកសារសារណាបញ្ចប់ការសិក្សារបស់សិស្សច្បងជំនាន់មុនៗ

✓ ឯកសាររបស់សាស្ត្រាចារ្យ

✓ ឯកសារផ្លូវការរបស់ **ន.ប.ធ.**

✓ បណ្តាញសង្គមផ្លូវការនានារបស់ **ន.ប.ធ.** ជាដើម។

➢ **ការវិភាគទិន្នន័យ**

បន្ទាប់ពីប្រមូលទិន្នន័យរួច ដំណាក់កាលបន្ទាប់នេះ គឺត្រូវធ្វើការវិភាគទិន្នន័យតាមបែបពណ៌នា ដើម្បីធ្វើការបកស្រាយឱ្យបានច្បាស់លាស់នូវអត្ថន័យនៃការសិក្សាស្រាវជ្រាវនេះ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី «**វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា**» អាចត្រូវបានចាត់ទុកថាជា ស្នាដៃនៃការសិក្សាស្រាវមួយ ដែលបានបង្កប់នូវអត្ថប្រយោជន៍ និងគុណសម្បត្តិជាច្រើនសម្រាប់សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងទទួលបាននូវឯកសារថ្មីៗសំខាន់ៗបន្ថែមទៀត សម្រាប់តម្កល់ទុកនៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យ ហើយសិស្ស-និស្សិត ដែលជាអ្នកស្រាវជ្រាវជំនាន់ក្រោយនឹងមានឱកាសក្នុងការសិក្សា ស្រាវជ្រាវបន្ថែមទៀតអំពីវិស័យបរធនបាលកិច្ចនេះឱ្យកាន់តែមានភាពទូលំទូលាយជាងពេលបច្ចុប្បន្ននេះ។

ចំពោះប្រធានបទនេះ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- **ចំពោះក្រុមយើងខ្ញុំផ្ទាល់**
  - ✓ បានផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តី ក៏ដូចជាការអនុវត្តជាក់ស្តែងនៅថ្ងៃក្រោយ
  - ✓ បានផ្តល់ជាចំណេះដឹងកាន់តែច្បាស់បន្ថែមទៀតពីវិស័យបរធនបាលកិច្ច
  - ✓ បានយល់ដឹងបន្ថែមពីរបៀបស្វែងរកឯកសារ និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទ
  - ✓ ចេះពីវិធីសាស្រ្តក្នុងការរៀបចំឯកសារ និងការបកស្រាយពីលទ្ធផលដែលបានពីការស្រាវជ្រាវ
  - ✓ បានចងក្រងទុកជាឯកសារយោងសម្រាប់អ្នកសិក្សាជំនាន់ក្រោយ
  - ✓ ទទួលបាននូវបទពិសោធន៍បន្ថែមទៀតទាក់ទងនឹងការសិក្សាស្រាវជ្រាវ
  - ✓ ចេះរៀបចំឯកសារ និងប្រមូលទិន្នន័យនានា ដើម្បីមកធ្វើការចងក្រង ជាដើម។
- **ចំពោះសិស្ស-និស្សិត និងអ្នកសិក្សាស្រាវជ្រាវ**
  - ✓ ស្វែងយល់ពីទីផ្សារបរធនបាលកិច្ចនៅកម្ពុជា
  - ✓ យល់ដឹងពីលក្ខខណ្ឌ និងនីតិវិធីនៅក្នុងប្រតិបត្តិការបរធនបាលកិច្ចនៅកម្ពុជា
  - ✓ ទទួលបានព័ត៌មាននានាពាក់ព័ន្ធនឹងទីផ្សារបរធនបាលកិច្ចនៅកម្ពុជា
  - ✓ ដឹងច្បាស់ថានរណាជាអាជ្ញាធរនៅក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា
  - ✓ ស្គាល់កាន់តែច្បាស់អំពីទីផ្សារបរធនបាលកិច្ច
  - ✓ ផ្តល់ជាទុនបន្ថែមដល់ការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើប្រធានបទ «**វិស័យបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា**»



# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ការកកើតនៃវិស័យបរធនបាលកិច្ច

ច្បាប់ស្តីពីបរធនបាលកិច្ចដំបូង មានប្រវត្តិនៅចក្រភពអង់គ្លេស ដែលច្បាប់នេះត្រូវបានបង្កើតឡើងនៅសតវត្សរ៍ទី ១២ ចាប់ពីពេលបូជនីយកិច្ចក្រោមយុត្តាធិការរបស់ព្រះមហាក្សត្រអង់គ្លេស។[1] ប្រវត្តិក្នុងការបង្កើតច្បាប់នេះ ជាប់ពាក់ព័ន្ធនឹងភាពជាកម្មសិទ្ធិលើដីធ្លី ដែលរឿងរ៉ាវបានកើតឡើងនៅពេលម្ចាស់ដីជាច្រើនត្រូវចាកចេញពីប្រទេសអង់គ្លេស ដើម្បីទៅធ្វើសង្គ្រាមក្នុងបូជនីយកិច្ចរបស់ពួកគាត់។ ក្នុងពេលអវត្តមាននោះ ពួកគាត់បានប្រគល់ដីឱ្យលោកម្ចាស់អធិការបតី ដែលមានសិទ្ធិគ្រប់គ្រងដី ហើយត្រូវប្រគល់ដីមកឱ្យពួកគាត់វិញពេលត្រឡប់មកពីធ្វើសង្គ្រាម។ ក៏ប៉ុន្តែ ក្រុមបូជនីយកិច្ចតែងតែធ្វើការបដិសេធពីលោកម្ចាស់អធិការបតី ហើយមិនព្រមប្រគល់ដីនៅពេលពួកគេត្រឡប់មកវិញនោះទេ។ ជាអកុសលសម្រាប់ក្រុមបូជនីយកិច្ច ប្រព័ន្ធច្បាប់របស់អង់គ្លេសនៅពេលនោះ មិនបានទទួលស្គាល់ការអះអាងរបស់គាត់ទេ មិនតែប៉ុណ្ណោះតុលាការយល់ថាដីទាំងនោះ គឺជាកម្មសិទ្ធិរបស់អ្នកទទួលខុសត្រូវលើដីដែលគ្មានកាតព្វកិច្ចត្រូវប្រគល់ដីនោះមកវិញទេ ដែលជាហេតុធ្វើឱ្យក្រុមបូជនីយកិច្ចគ្មានសិទ្ធិទាមទារស្របតាមផ្លូវច្បាប់ទេ។ នៅពេលនោះ មានលោកម្ចាស់អធិការបតីសប្បុរសម្នាក់ បានសម្រេចរឿងក្តីទៅតាម មនសិការរបស់លោក ដោយលោកចាត់ទុកថាវាជាការមិនត្រឹមត្រូវទេ ដែលអ្នកថែរក្សាដីបដិសេធមិនព្រមឱ្យទៅម្ចាស់ដីដែលជាក្រុមបូជនីយកិច្ចវិញនោះ។ ចាប់ពីពេលនោះមក តុលាការរបស់លោកម្ចាស់អធិការបតី តែងទទួលស្គាល់ជានិច្ចនូវការទាមទាររបស់ក្រុមបូជនីយកិច្ច ដែលវិលត្រឡប់មកពីធ្វើសង្គ្រាមវិញ ហើយបុគ្គលកាន់កាប់ដី ដើម្បីជាប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិដីដើម ត្រូវប្រគល់ដីឱ្យទៅម្ចាស់ដើមវិញនៅពេលមានការស្នើសុំ។

## ១.២. តើអ្វីទៅជាបរធនបាលកិច្ច?

បរធនបាលកិច្ច គឺជាទំនាក់ទំនងគតិយុត្ត ដែលបរធនបាលទាយកផ្តល់ទ្រព្យសម្បត្តិដល់បរធនបាលក្នុងការមើលថែរក្សា និងប្រើប្រាស់ជាប្រយោជន៍ដល់អត្ថគាហកៈ។ ជាទូទៅ ភាគីនៃបរធនបាលកិច្ចសំខាន់ៗមាន ៣ (បី) គឺ៖ បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ។ បរធនបាលកិច្ច ត្រូវបានបង្កើតឡើងដោយបរធនបាលទាយក ឬ បទប្បញ្ញត្តិជាធរមាន និងត្រូវមានកម្មវត្ថុស្របច្បាប់ និងមិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។ ទំនាក់ទំនងនេះ គឺជាកាតព្វកិច្ចដែលចែងដោយច្បាប់ ក្នុងការតម្រូវឱ្យបរធនបាលមានសិទ្ធិកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិ សម្រាប់ជាប្រយោជន៍ដល់បុគ្គលដែលនឹងត្រូវទទួលបានអត្ថប្រយោជន៍ពីទ្រព្យសម្បត្តិ

[1] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១

នោះ (យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១៦-២០២៥, ២០១៦; ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)។ ដំណើរការនៃការបង្កើតបរធនបាលកិច្ច មានដូចជា៖ (១).ករណីដែលបរធនបាលកិច្ច ត្រូវបានបង្កើតឡើងដោយបរធនបាលទាយក បរធនបាលទាយកត្រូវផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួនទៅឱ្យបរធនបាល តាមរយៈលិខិតបរធនបាលកិច្ច ដោយមានបញ្ជាក់ពីគោលបំណងជាក់លាក់របស់ បរធនបាលកិច្ច និង/ ឬបញ្ជាក់ពីអត្តសញ្ញាណអត្ថគាហកៈ (២).ករណីដែលបរធនបាលកិច្ច ត្រូវបានបង្កើតឡើងដោយបទប្បញ្ញត្តិជាធរមាន បរធនត្រូវបានផ្ទេរដោយស្វ័យប្រវត្តិឱ្យទៅបរធនបាល ដើម្បីគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ ស្របតាមបទប្បញ្ញត្តិជាធរមានដោយមានបញ្ជាក់ពីគោលបំណងជាក់លាក់របស់បរធនបាលកិច្ច និង/ឬបញ្ជាក់ពីអត្ត- សញ្ញាណរបស់អត្ថគាហកៈ។ បរធនបាលកិច្ច មានអានុភាពអនុវត្តបាន នៅពេលដែលបរធនបាលយល់ព្រមទទួលយក ជាលាយលក្ខណ៍អក្សរចំពោះការតែងតាំង (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩) ។[2]

### ១.៣. តួអង្គសំខាន់ៗនៅក្នុងវិស័យបរធនបាលកិច្ច

យោងតាមច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) ភាគីនៃបរធនបាលកិច្ចជាសំខាន់មាន ៣ (បី) គឺ៖ បរធនបាល ទាយក បរធនបាល និងអត្ថគាហកៈ។

រូបភាព ១.១ តួអង្គសំខាន់ៗនៅក្នុងវិស័យបរធនបាលកិច្ច




#### ១.៣.១. បរធនបាលទាយក

បរធនបាលទាយក គឺជាបុគ្គលដែលបានបង្កើត និងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច និងមានសិទ្ធិទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាល-កិច្ច ព្រមទាំងតែងតាំង និងបញ្ឈប់បរធនបាល (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)។

[2] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

### ១.៣.២. បរធនបាល

បរធនបាល គឺជាបុគ្គលដែលទទួលសិទ្ធិគ្រប់គ្រង និងចាត់ចែងបរធនពីបរធនបាលទាយក សម្រាប់ជាប្រយោជន៍ ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ ជាមួយគ្នានេះ បរធនបាលក៏មាន សិទ្ធិទទួលលាភការ ឬកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ច ចំណាយក្នុងសកម្មភាពសង្គមស្របតាមគោលបំណង និងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច និងស្វែងរកជំនួយឬមូលនិធិដើម្បីជាប្រយោជន៍របស់បរធនបាលកិច្ចផងដែរ។[3]

### ១.៣.៣. អត្ថគាហកៈ (អ្នកទទួលផលប្រយោជន៍)

អត្ថគាហកៈ គឺជាបុគ្គលដែលអាចទទួលផលប្រយោជន៍ពីបរធនបាលកិច្ច ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃបរធនបាលកិច្ច លើកលែងតែមានបទប្បញ្ញត្តិផ្សេងទៀត។ ករណីដែលមានអត្ថគាហកៈច្រើន អត្ថគា-ហកៈទាំងនេះមានសិទ្ធិទទួលអត្ថប្រយោជន៍ ដូចគ្នាឬផ្សេងគ្នាតាមរបៀបឬវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច។

ករណីដែលគ្មានរបៀប ឬវិធីទទួលផលដូចដែលបានចែងក្នុងកថាខណ្ឌខាងលើត្រូវសន្មត់ថាអត្ថគាហកៈទាំងនេះទទួលបានផលស្មើៗគ្នា។

ចំណែកសិទ្ធិរបស់អត្ថគាហកៈត្រូវបានចែងក្នុងមាត្រា ២៧ ថាអត្ថគាហកៈមានសិទ្ធិជាអាទិ៍ដូចជា (១) ទទួលប្រយោជន៍ដូចដែរមានចែងក្នុងលិខិតបរទណ្ឌបាលកិច្ច (២) ទាមទារឱ្យបរធនបាល បំពេញកាតព្វកិច្ចដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចនិងតាមបទប្បញ្ញត្តិ ជាធរមាន (៣) ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងនិងចាត់ចែងបរធនបាលកិច្ច និងសិទ្ធិផ្សេងទៀតដែលមានចែងក្នុងលិខិតបរធនបាលកិច្ច និងបទប្បញ្ញត្តិ ។[4]

រូបភាព ១.២ អត្ថគាហកៈ (អ្នកទទួលផលប្រយោជន៍)




[3] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១

[4] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១

## ១.៤. អ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ច

### ១.៤.១. អាជ្ញាធរគ្រប់គ្រងវិស័យបរធនបាលកិច្ច

អនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ ២០២១ នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវបានធ្វើសមាហរណកម្មជា និយ័តករបរធនបាលកិច្ច ឬហៅកាត់ថា **ន.ប.ធ.** គឺជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅក្នុង ព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងនៅក្នុងច្បាប់ស្តីពី បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យបរធនបាលកិច្ច។

### ១.៤.២. ប្រតិបត្តិករ

#### ១.៤.២.១. ក្រុមហ៊ុនបរធនបាល

ក្រុមហ៊ុនបរធនបាល សំដៅដល់បរធនបាលជានីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណ និង/ឬ ការអនុញ្ញាតពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន។

#### ១.៤.២.២. បរធនបាលរូបវន្តបុគ្គល

បរធនបាលរូបវន្តបុគ្គល សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើជាបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ឬបរធនបាលរូបវន្តបុគ្គលឯករាជ្យ។ បរធនបាលរូបវន្តបុគ្គល ត្រូវបានចែកចេញជា ២ ប្រភេទគឺ

១ .**បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល** សំដៅ ដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើជា បរធនបាលរូបវន្តបុគ្គលក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ ឬការ អនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាល។

២ .**បរធនបាល់រូបវន្តបុគ្គលឯករាជ្យ** សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ច មួយ ឬច្រើន ហើយបរធនបាលរូបវន្តបុគ្គលឯករាជ្យនេះ មិនស្ថិត នៅក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ ឬការអនុញ្ញាតរបស់ក្រុមហ៊ុន បរធនបាលណាមួយឡើយ។

**បញ្ជាក់**- បរធនបាលដែលត្រូវទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត អាចធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន ដូច ខាងក្រោម

-ប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ

- ប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ

- ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម

- ប្រតិបត្តិការបរធនបាលកិច្ចសង្គម

- ប្រតិបត្តិការបរធនបាលកិច្ចបុគ្គល និងប្រតិបត្តិការបរធនបាលកិច្ចផ្សេងទៀតតាមការកំណត់របស់ ន.ប.ធ. ។[5]

រូបភាព ១.៤.២ ប្រតិបត្តិការបរធនបាល




### ១.៤.២.៣. ប្រតិបត្តិករផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុក[6]

សេវារក្សាសុវត្ថិភាព/រក្សាទុក (Escrow Services) សំដៅដល់ប្រតិបត្តិការ ដែលក្នុងនោះម្ចាស់ទ្រព្យបានប្រគល់ទ្រព្យរបស់ខ្លួនឱ្យទៅធនគារពាណិជ្ជ ដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព/រក្សាទុក (Escrow Services) ដើម្បីរក្សាសុវត្ថិភាព ឬរក្សាទុកតាមរយៈការបង្កើត គណនី Escrow ក្នុងគោលបំណងដើម្បីធ្វើការទូទាត់ ឬប្រគល់ទ្រព្យនោះទៅឱ្យបុគ្គលណាមួយ ក្នុងប្រតិបត្តិការធុរកិច្ច ឬ ក្នុងប្រតិបត្តិការអចលនទ្រព្យ ឬក្នុងប្រតិបត្តិការវិនិយោគនានា នៅពេលកំណត់ជាក់លាក់ណាមួយ ទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀង។

ប្រតិបត្តិការសេវារក្សាសុវត្ថិភាព/រក្សាទុក (Escrow Services) ដែលមានអនុលោមភាពតាមច្បាប់ និង ចុះបញ្ជីបរធនបាលកិច្ចត្រឹមត្រូវ ផ្តល់នូវអត្ថប្រយោជន៍មួយចំនួន រួមមាន៖ (១).អាចជួយការពារហានិភ័យ បង្កើតទំនុកចិត្ត និងបង្កើនសុវត្ថិភាពដល់ភាគីពាក់ព័ន្ធ និង (២).អនុលោមភាព និងការគាំពារដោយច្បាប់ និងមាននិយ័តករធ្វើការតាមដាន និងត្រួតពិនិត្យទៅលើប្រតិបត្តិការនោះ។

[5] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី១២ ខែមេសា ២០២៣

[6] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី១០ ខែឧសភា ២០២៣

យោងតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ធនាគារពាណិជ្ជ ដែលអាចធ្វើជាប្រតិបត្តិករបរធន-បាលផ្តល់សេវារក្សាសុវត្ថិភាព/រក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច ត្រូវទទួលបានអាជ្ញាបណ្ណ/ការ អនុញ្ញាតពី **ន.ប.ធ.**។

### ១.៤.២.៤. ក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្ម

ក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្ម សំដៅដល់នីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណ ឬការអនុ-ញ្ញាតពី និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស.) និងទទួលបានការទទួលស្គាល់ជាក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្មពី **ន.ប.ធ.**។

### ១.៤.២.៥. ក្រុមហ៊ុនវាយតម្លៃ

ក្រុមហ៊ុនវាយតម្លៃ សំដៅដល់នីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណសេវាកម្មវាយតម្លៃពីនិយ័ត-ករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ (ន.អ.ប.) និងទទួលបានការទទួលស្គាល់ការវាយតម្លៃពី **ន.ប.ធ.**។

### ១.៤.៣. វិនិយោគិន

វិនិយោគិននៅទីនេះសំដៅដល់អ្នកប្រើប្រាស់ប្រតិបត្តិការបរធនបាលកិច្ចដែលអាចជាបរធនបាលទាយក អ្នកផ្តល់វិភាគទាន និងអត្ថគាហកៈ/អ្នកទទួលផលនៃបរធនបាលកិច្ចណាមួយ។ ជាលក្ខណៈស្តង់ដារអន្តរជាតិ កិច្ចការពារវិនិយោគិន/អ្នកប្រើប្រាស់ ត្រូវមានធាតុ ៣ សំខាន់គឺ៖ (១).ការបណ្តុះបណ្តាលឬផ្តល់ចំណេះដឹង (២).ការបើកឱ្យមានការការពារសិទ្ធិតាមរយៈយន្តការនៃការដាក់ពាក្យបណ្តឹង និង (៣).កិច្ចការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យនេះ។ ដូច្នេះ ក្នុងដំណាក់កាលនេះ កត្តាអាទិភាពរបស់ **ន.ប.ធ.** គឺ៖ (១).ការផ្តល់សេវាប្រឹក្សា និងពិគ្រោះយោបល់ផ្នែកច្បាប់ ដើម្បីជាការបើកឱ្យមានមធ្យោបាយទទួលបានការពិគ្រោះយោបល់ផ្នែកច្បាប់ពីមន្ត្រីជំនាញរបស់ **ន.ប.ធ.** ជូនសាធារណជន ដែលអាចជាក្រុមហ៊ុន ស្ថាប័ន ឬរូបវន្តបុគ្គលដែលមានចំណាប់អារម្មណ៍ ឬសង្ស័យថាអំពើឬសកម្មភាពរបស់ខ្លួនគឺពាក់ព័ន្ធនឹងបរធនបាលកិច្ចដែលត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយ **ន.ប.ធ.**។ ដូចនេះ **ន.ប.ធ.** នឹងរៀបចំយន្តការ បែបបទ និងនីតិវិធីពិគ្រោះយោបល់ផ្នែកច្បាប់ពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច ដោយរួមបញ្ចូលទាំងទម្រង់ពាក្យស្នើសុំពិគ្រោះយោបល់ផងដែរ និង (២).ក្របខណ្ឌកិច្ចសហ-ការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការជំរុញការគោរពច្បាប់ និងពង្រឹងអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាការផ្តល់ និងបញ្ជ្រាបចំណេះដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងបរធនបាលកិច្ច។

ជារួម **ន.ប.ធ.** នឹងដាក់ចេញនូវកិច្ចសហការនានាជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់កិច្ចសហការគ្នាទៅវិញទៅមក ដើម្បីធានាអនុលោមភាពតាមច្បាប់ និងភាពស៊ីសង្វាក់គ្នារវាងអន្តរវិស័យទៅលើសកម្មភាពពាក់ព័ន្ធនឹងបរ-ធនបាលកិច្ច។

## ១.៥. ប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា

ប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨ តាមរយៈការគិតគូររៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងគោលបំណង ដើម្បីគ្រប់-គ្រងមូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុលដែលដៃគូអភិវឌ្ឍន៍ផ្តល់ឱ្យរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យ ធនាគារ និងវិស័យមីក្រូហិរញ្ញវត្ថុ ដែលមូលនិធិទាំងនោះ ត្រូវបានគ្រប់គ្រងនិងចាត់ចែងប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

តាមរយៈការគិតគូររៀបចំគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំជាសេចក្តីព្រាងច្បាប់ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងបានដាក់ឆ្លងអង្គប្រជុំអន្តរក្រសួងបានម្តង ប៉ុន្តែត្រូវដកយកមកពិនិត្យ និងរៀបចំឡើងវិញ ដើម្បីពង្រីកវិសាលភាពឱ្យកាន់តែទូលំទូលាយ។

សម្រាប់ដំណើរការការងារបណ្តោះអាសន្ន ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការចាំបាច់ក្នុងការគ្រប់គ្រងលើមូលនិធិនានា ដែលត្រូវបានផ្តល់ឱ្យរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានស្នើក្នុងក្របខណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ ការគ្រប់គ្រងឆ្នាំ២០១៣ បានរៀបចំអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣។ នៅក្នុងដំណាក់កាលនៃការអនុវត្តបណ្តោះអាសន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមាន នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុបានទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជី បរធនបាលកិច្ចហិរញ្ញវត្ថុចំនួន ៩ ដែលមានទំហំសមតុល្យបរធនដើមគ្រាប្រមាណ ១១៤,៨០៨,១២៣ ដុល្លារអាមេរិក ហើយរហូតមកដល់ពេលនេះមានទំហំសមតុល្យបរធនប្រមាណជាង ១៣ពាន់លាន ដុល្លារអាមេរិក។[7]

## ១.៦. តួនាទីនៃវិស័យបរធនបាលកិច្ចនៅក្នុងដំណើរការសេដ្ឋកិច្ច

នៅក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្អែកលើមូលដ្ឋានទីផ្សារសកលភាវូបនីយកម្ម និងសេរីភាវូបនីយកម្មនៃរំហូរមូលធន ធ្វើឱ្យមានប្រតិបត្តិការរំហូរមូលធនចាក់ចូលគ្រប់វិស័យក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា។ នៅក្នុងក្របខណ្ឌនៃប្រតិបត្តិការរំហូរមូលធននេះ វិស័យបរធនបាលកិច្ចបានដើរតួនាទីយ៉ាងសំខាន់មានជាអាទិ៍ ដូចជា៖ ជាថ្នាល ក្នុងការបង្កើត និងបង្កើនទំនុកចិត្តរវាងភាគីពាក់ព័ន្ធ, ជាយន្តការតាមដាន ការគ្រប់-គ្រង ការចាត់ចែង និងការថែរក្សា សុវត្ថិភាពជំនួស (ថាតើមានអនុលោមភាពតាមច្បាប់ឬទេ មានតម្លាភាព គណ-នេយ្យភាព ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព ឬទេ?)និងជាយន្តការកាត់បន្ថយហានិភ័យពាក់ព័ន្ធ តាមរយៈការកំណត់សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវតាមច្បាប់ របស់ភាគីពាក់ព័ន្ធ។[8]

---

[7] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០២២

[8] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០២២

## ១.៧. សារៈសំខាន់នៃវិស័យបរធនបាលកិច្ច

វិស័យបរធនបាលកិច្ច ជាវិស័យដ៏សំខាន់មួយដែលមានវិសាលភាពទូលំទូលាយ ដែលមិនត្រឹមតែគ្របដណ្តប់លើ វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ ថែមទាំងមានវិសាលភាពគ្របដណ្តប់លើវិស័យធានារ៉ាប់រង និងសោធន, វិស័យអចលនទ្រព្យ, វិស័យមូលបត្រ និងវិស័យផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច និងសង្គមផងដែរ ដើម្បីគ្រប់គ្រងលើបរធនបាលកិច្ចនៅក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម ព្រមទាំងដើម្បីដោះស្រាយការគ្រប់គ្រងចាំបាច់លើមូលនិធិនានា ដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាលដោយដៃគូអភិវឌ្ឍន៍នានាផងដែរ។

គុណប្រយោជន៍នៃការបង្កើតវិស័យបរធនបាលកិច្ច មានជាអាទិ៍៖ (១).បង្កើនការវិនិយោគក្នុងស្រុកដែលជាប្រភពនៃការបន្ថែមចំណូលពន្ធជាតិ (២).ជំរុញការធ្វើពិពិធកម្មហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា និង (៣).ផ្តល់ លទ្ធភាពដល់ការតាមដាន និងគ្រប់គ្រងនូវលំហូរទុនលើគ្រប់វិស័យ ដែលកំពុងធ្វើប្រតិបត្តិ-ការក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅទាក់ទាញទំនុកចិត្តបន្ថែមពីដៃគូអភិវឌ្ឍន៍នានា ហើយវិស័យបរធនបាលកិច្ច មានវិសាលភាពទូលំទូលាយ ដែលមិនត្រឹមតែគ្របដណ្តប់លើវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ ថែមទាំងមានវិសាលភាពគ្របដណ្តប់លើវិស័យធានារ៉ាប់រង, វិស័យអចនលទ្រព្យ, វិស័យមូលបត្រ, និងវិស័យផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច និងសង្គមផងដែរ ដើម្បីគ្រប់គ្រងលើបរធនបាលកិច្ចនៅក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម ព្រមទាំងដើម្បីដោះស្រាយការគ្រប់គ្រងចាំបាច់លើមូលនិធិនានាដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាលដែលផ្តល់ដោយដៃគូអភិវឌ្ឍផងដែរ។

# ជំពូកទី២
# និយ័តករបរធនបាលកិច្ ច

( ន.ប.ធ. )

# ជំពូកទី២

# និយ័តករបរធនបាលកិច្ច (ន.ប.ធ.)

## ២.១. ការកកើតនៃនិយ័តករបរធនបាលកិច្ច

នៅឆ្នាំ២០០៨ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចាប់ផ្តើមគិតគូររៀបចំគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ ដោយបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុលើកដំបូង ក្នុងគោលបំណងគ្រប់គ្រងមូលនិធិ ហិរញ្ញប្បទានឥតសំណង ឬអនុបំណុល ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់វិស័យមីក្រូហិរញ្ញវត្ថុ ដែលមូលនិធិទាំងនោះ ត្រូវបានគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានដាក់ឆ្លងអង្គប្រជុំអន្តរក្រសួងបានម្តង ប៉ុន្តែត្រូវដកយកមកពិនិត្យរៀបចំឡើងវិញ ដើម្បីពង្រីកវិសាលភាពឱ្យកាន់តែ ទូលំទូលាយ។

សម្រាប់ដំណើរការការងារបណ្តោះអាសន្ន ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការចាំបាច់ក្នុងការគ្រប់គ្រងលើមូលនិធិនានា ដែលត្រូវបានផ្តល់ឱ្យរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានស្នើក្នុងក្របខណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ រៀបចំអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣។ នៅក្នុងដំណាក់កាលនៃការអនុវត្តបណ្តោះអាសន្ននេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមាននាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ បានទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុចំនួន ៩ ដែលមានទំហំបរធន ឬទំហំធនធានហិរញ្ញវត្ថុប្រមាណ ១១៤,៨០៨,១២៣ ដុល្លារអាម៉េរិក ក៏ប៉ុន្តែការគ្រប់គ្រងតាមរយៈអនុក្រឹត្យនេះមិនទាន់មានប្រសិទ្ធភាពខ្ពស់ស្របតាមការវិវត្តរបស់វិស័យនេះនៅឡើយ។

ក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋានទីផ្សារសកលភាវូបនីយកម្ម និងសេរីភាវូបនីយកម្មនៃលំហូរមូលធន វិស័យបរធនបាលកិច្ចមានវិសាលភាពទូលំទូលាយ ដែលមិនត្រឹមតែគ្របដណ្តប់លើវិស័យ ធនាគារ និងមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ ថែមទាំងគ្របដណ្តប់លើវិស័យធានារ៉ាប់រងនិងសោធន វិស័យអចលនវត្ថុ វិស័យមូលបត្រ និងវិស័យផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច និងសង្គមផងដែរ។ ដើម្បីឱ្យវិស័យនេះអាចចូលរួមចំណែកជំរុញដល់ការធ្វើពិពិធកម្មវិស័យហិរញ្ញវត្ថុនៅកម្ពុជា ឱ្យទទួលបាននូវការអភិវឌ្ឍកាន់តែឆាប់រហ័សស្របតាមនិន្នាការនៃការអភិវឌ្ឍវិស័យ ហិរញ្ញវត្ថុក្នុងតំបន់ និងសកលលោក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំតាក់តែងសារជាថ្មីនូវសេចក្តីព្រាងច្បាប់ស្តីពីបរធនបាលកិច្ច ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានវិសាលភាពគ្របដណ្តប់លើបរធនបាលកិច្ចទូទៅនៅក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម។ ក្នុងន័យនេះ ក្របខណ្ឌ

នៃការគ្រប់គ្រង និងអភិវឌ្ឍវិស័យបរធនបាលកិច្ច ត្រូវបាន ពង្រីកវិសាលភាព តាមរយៈក្របខណ្ឌច្បាប់ស្តីពីបរធន-បាលកិច្ច ឆ្នាំ២០១៩ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើនៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៩។

អនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ ២០២១ នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវបានធ្វើសមាហរណកម្មជា និយ័តករ បរធនបាលកិច្ច ឬហៅកាត់ថា **ន.ប.ធ.** ជានិយ័តករមួយដែលត្រូវអនុវត្តនូវមុខងារគ្រប់គ្រង ត្រួត-ពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែង ក្នុងច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យបរ-ធនបាលកិច្ច។

## ២.២. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់និយ័តករបរធនបាលកិច្ច

### ២.២.១. រូបសញ្ញា

អនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបាន ប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ និយ័តករបរធនបាលកិច្ច ឬហៅកាត់ថា **ន.ប.ធ.** ជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តសមត្ថ-កិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យបរធនបាលកិច្ច។

រូបភាព ២.១. ស្លាកសញ្ញារបស់និយ័តករបរធនបាលកិច្ច

### ២.២.២. អត្ថន័យនៃរូបសញ្ញា

យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ និមិត្តសញ្ញារបស់និយ័តករ បរធនបាលកិច្ចមានអត្ថន័យដូចខាងក្រោម៖

- **រូបហង្សពណ៌មាស** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរ-ធនបាលកិច្ច ដើម្បីធានាឱ្យណើរការប្រតិបត្តិការបរធនបាលកិច្ច ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបបាតដៃទាំងបី** ដែលមានពណ៌ខៀវ ពណ៌មាស និងពណ៌បៃតង ស្រាក់ចូលគ្នា តំណាងឱ្យប្រតិ-បត្តិការ បរធនបាលកិច្ច ដែលក្នុងនោះបរធនបាលគ្រប់គ្រង និងថែរក្សាជំនួសបរធន ដែលផ្តល់ដោយបរ-ធនបាលទាយក សម្រាប់ ជាប្រយោជន៍ដល់អត្ថគាហកៈ
- **រូបហង្សពណ៌មាសឈរលើរូបបាតដៃបី** បង្ហាញពីប្រតិបត្តិការបរធនបាលកិច្ច ស្ថិតនៅក្រោមការគ្រប់-គ្រង និងត្រួតពិនិត្យរបស់និយ័តករបរធនបាលកិច្ច ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបស្លឹកឈើ** លទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យបរធនបាលកិច្ចក្នុងការអភិវឌ្ឍសេដ្ឋ-កិច្ចជាតិ។

## ២.៣. ទីតាំងរបស់និយ័តករបរធនបាលកិច្ច

**ន.ប.ធ.** មានអាសយដ្ឋាន ស្ថិតនៅអគារ ១៦៨F (ជាន់ទី ៨) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## ២.៤. ចក្ខុវិស័យ និងបេសកកម្មរបស់និយ័តករបរធនបាលកិច្ច

### ២.៤.១. ចក្ខុវិស័យ

**ន.ប.ធ.** មានចក្ខុវិស័យគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការបង្កើនការវិនិយោគក្នុងស្រុកដែលជាប្រភពនៃការបន្ថែមចំណូលពន្ធជាតិ, ជំរុញការធ្វើពិពិធកម្មហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់ប្រជា-ពលរដ្ឋកម្ពុជា និងផ្តល់ លទ្ធភាពដល់ការតាមដាន និងគ្រប់គ្រងនូវលំហូរទុនលើគ្រប់វិស័យ ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅទាក់ទាញទំនុកចិត្តបន្ថែមពីដៃគូអភិវឌ្ឍនានា និងដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

### ២.៤.២. បេសកកម្ម

**ន.ប.ធ.** នឹងបន្តពង្រឹង និងអភិវឌ្ឍស្ថាប័ន, មុខងារស្ថាប័ន និងអភិវឌ្ឍវិស័យបរធនបាលកិច្ច តាមរយៈការពង្រឹងការគ្រប់គ្រងកិច្ចការទូទៅ, ការកសាងសមត្ថភាពរបស់មន្ត្រី, ការគ្រប់គ្រងការចុះបញ្ជីបរធនបាលកិច្ច, ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ និងការអនុវត្តច្បាប់, និងការស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។

## ២.៦. អង្គភាពខាត់តាំង

អនុលោមតាមអនុក្រឹត្យស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនគារ" អង្គភាពក្រោមឱវាទរបស់ អ.ស.ហ. រួមមាន៖ អគ្គលេខាធិការដ្ឋាននៃ អ.ស.ហ., និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករមូលបត្រកម្ពុជា, និយ័តករសន្តិសុខសង្គម, និយ័តករបរធនបាលកិច្ច, និយ័តករគណនេយ្យ និងសវនកម្ម, និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.។

រូបភាព ២.២.អង្គការលេខរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**ខាងក្រោមនេះគឺជាអង្គការលេខរបស់ អ.ស.ហ.**




## ២.៦. រចនាសម្ព័ន្ធគ្រប់គ្រង

ក្រោមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រចនាសម្ព័ន្ធស្ថាប័ននៃនិយ័តករបរធនបាលកិច្ច ត្រូវបានធ្វើនិយ័តកម្មដោយយោងតាមអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវា

ហិរញ្ញវត្ថុមិនមែនធនាគារ ដែល ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករបរធនបាលកិច្ច ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ត្រូវដឹកនាំដោយអគ្គនាយក ចំនួន ១ រូប អមដោយអគ្គនាយករងមួយចំនួន និងមាន នាយកដ្ឋានចំណុះចំនួន ៤ រួមមាន៖ នាយកដ្ឋានកិច្ចការទូទៅ, នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច, នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការដែលនាយកដ្ឋាននីមួយៗមានការិយាល័យចំណុះចំនួន ៣។

រូបភាព ២.៣.រចនាសម្ព័ន្ធរបស់និយ័តករបរធនបាលកិច្ច

**ខាងក្រោមនេះគឺជារចនាសម្ព័ន្ធគ្រប់គ្រងរបស់ ន.ប.ធ.**



## ២.៧. មុខងារ និងតួនាទីរបស់និយ័តករបរធនបាលកិច្ច ( ន.ប.ធ. )

### ២.៧.១. គោលនយោបាយយុទ្ធសាស្ត្រ

- រៀបចំ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យបរធនបាលកិច្ច
-សម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស និងរៀបចំថវិការបស់**ន.ប.ធ.**ជាមួយអគ្គលេខាធិការដ្ឋាន **អ.ស.ហ**.
- គ្រប់គ្រងហិរញ្ញវត្ថុ និងត្រួតពិនិត្យបុគ្គលិករបស់ **ន.ប.ធ.**
- គ្រប់គ្រងមូលនិធិទ្រទ្រង់
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ប្រធាន **អ.ស.ហ.**។

### ២.៧.២. គ្រប់គ្រង និងត្រួតពិនិត្យវិស័យ

- ត្រួតពិនិត្យ និងតាមដានការអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ
- រៀបចំធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តបទប្បញ្ញត្តិ
- ពិនិត្យ និងស្នើសុំរៀបចំក្រុមប្រឹក្សាដោះស្រាយវិវាទពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។

### ២.៧.៣. អភិវឌ្ឍវិស័យបរធនបាលកិច្ច

- អភិវឌ្ឍន៍វិស័យបរធនបាលកិច្ចតាមការណែនាំរបស់របស់ប្រធាន **អ.ស.ហ.**
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ។

## ២.៨. មុខងារ និងតួនាទីនាយកដ្ឋានចំណុះរបស់និយ័តករបរធនបាលកិច្ច ( ន.ប.ធ. )

### ២.៨.១. នាយកដ្ឋានកិច្ចការទូទៅ

នាយកដ្ឋានកិច្ចការទូទៅ មានការិយាល័យចំណុះចំនួន ៣ គឺ៖

១).ការិយាល័យរដ្ឋបាល និងបុគ្គលិក

២).ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ និង

៣).ការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា

ដែលការិយាល័យទាំង៣ នេះ មានមុខងារ និងតួនាទី ដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាល និងបុគ្គលិករបស់ **ន.ប.ធ.**
- សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួមរបស់ **ន.ប.ធ.**
- លើកសំណើ និងអនុវត្តលទ្ធកម្មសាធារណៈរបស់ **ន.ប.ធ.**
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន

- ចាត់ចែងការងារពិធីការរបស់ **ន.ប.ធ.**

- គ្រប់គ្រងទ្រព្យសម្បត្តិ និងបញ្ជីសារពើភណ្ឌរបស់ **ន.ប.ធ.**

- ផ្សព្វផ្សាយជាសាធារណៈពីកិច្ចដំណើរការនិងវឌ្ឍនភាពរបស់ **ន.ប.ធ.**

- គ្រប់គ្រងកិច្ចការគណនេយ្យ និងហិរញ្ញវត្ថុរបស់ **ន.ប.ធ.**

- រៀបចំ និងអនុវត្តថវិកាសម្រាប់កិច្ចដំណើរការ **ន.ប.ធ.**

- ពិនិត្យ និងតាមដានការអនុវត្តនីតិវិធីលទ្ធកម្មសាធា-រណៈរបស់ **ន.ប.ធ.**

- រៀបចំឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បី ស្នើសុំ និងទូទាត់ថវិការបស់ **ន.ប.ធ.**

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកព័ត៌មានវិទ្យាសម្រាប់ **ន.ប.ធ.**

- រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្សព្វផ្សាយរបស់ **ន.ប.ធ.**

- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា សម្ភារៈព័ត៌មានវិទ្យា និងសេវាព័ត៌មានវិទ្យាសម្រាប់ដំណើរការ **ន.ប.ធ.**

- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូផ្សេងៗក្នុងការអភិវឌ្ឍផ្នែកព័ត៌មានវិទ្យា

- អនុវត្តការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**២.៨.២. នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច**

នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច មានការិយាល័យចំណុះចំនួន ៣ គឺៈ

១).ការិយាល័យគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ

២).ការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសាធារណៈ និងពាណិជ្ជកម្ម និង

៣).ការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសង្គម និងបុគ្គល

ដែលការិយាល័យខាងលើនេះមានមុខងារ និងតួនាទី ដូចខាងក្រោមៈ

- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើឡើងនូវបទប្បញ្ញត្តិឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុ-ញ្ញាត និង/ឬការចុះបញ្ជីនូវការបង្កើតបរធនបាលកិច្ច

- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើឡើងនូវបទប្បញ្ញត្តិឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់អាជ្ញា-បណ្ណ ការអនុញ្ញាត និង/ឬការចុះបញ្ជីប្រតិបត្តិករបរធនបាល និងអ្នកចូលរួមដទៃទៀត

- ពិនិត្យ និងផ្តល់យោបល់លើការសុំចុះបញ្ជីបរធនបាលកិច្ច និងការសុំអាជ្ញាបណ្ណ ការអនុញ្ញាត និង/ឬ ការចុះបញ្ជីប្រតិបត្តិករបរធនបាលនិងអ្នកចូលរួមដទៃទៀត

- ពិនិត្យ និងផ្តល់យោបល់លើការសុំផ្លាស់ប្តូរឬកែប្រែអាសយដ្ឋាន សមាសភាពក្រុមប្រឹក្សាភិបាល បរធនបាល អគ្គគាហក: ការកែប្រែ ឬការបញ្ចប់បរធនបាលកិច្ច ឬការជម្រុះបញ្ជីបរធនបាលកិច្ច

- ត្រួតពិនិត្យ និងតាមដានការអនុវត្តតាមលក្ខខណ្ឌនៃការចុះបញ្ជីបរធនបាលកិច្ច ប្រតិបត្តិការរបស់ប្រតិបត្តិករបរធនបាល និងអ្នកចូលរួមដទៃទៀត

- ត្រួតពិនិត្យដល់ទីកន្លែងនូវប្រតិបត្តិការបរធនបាលកិច្ច ប្រតិបត្តិការរបស់ប្រតិបត្តិករបរធន-បាល និងអ្នកចូលរួមដទៃទៀត

- ត្រួតពិនិត្យរបាយការណ៍ របាយការណ៍អាជីវកម្ម ប្រតិវេទន៍ និងឯកសារចាំបាច់របស់បរធន-បាលកិច្ច

- អនុវត្តការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

### ២.៨.៣. នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច

នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច មានការិយាល័យចំណុះចំនួន ៣ គឺ៖

១).ការិយាល័យដោះស្រាយពាក្យបណ្តឹង

២).ការិយាល័យអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ និង

៣).ការិយាល័យនីតិកម្ម

ដែលមានមុខងារ និងតួនាទី ដូចខាងក្រោម៖

- រៀបចំបង្កើត និងសម្របសម្រួលការងារជាមួយក្រុមប្រឹក្សាដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិប-ត្តិការ បរធនបាលកិច្ច

- រៀបចំ និងអនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងកិច្ចគាំពារវិនិយោគិនក្នុងវិស័យបរធនបាលកិច្ច

-រៀបចំ និងស្នើឡើងនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងយន្តការនៃការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងក្នុងវិស័យបរធនបាលកិច្ច

- រៀបចំនីតិវិធីទទួល និងដោះស្រាយបណ្តឹងដែលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច

- ចូលរួមសហប្រតិបត្តិការដោះស្រាយវិវាទ ចំពោះរាល់វិវាទពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច

- ប្រមូល និងចងក្រងរាល់សំណុំរឿងវិវាទ បណ្តឹង កំណត់ហេតុសម្រុះសម្រួល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច

- ធ្វើអធិការកិច្ច ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ ឆែកឆេរ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិរបស់បុគ្គលទទួលបានការអនុញ្ញាតពាក់ព័ន្ធនឹងការបង្កើតនិងចុះបញ្ជីបរធនបាល-

កិច្ច បុគ្គលទទួលបាន ការអនុញ្ញាត និង/ឬការចុះបញ្ជីធ្វើជាប្រតិបត្តិករបរធនបាល រូបវន្តបុគ្គល/នីតិបុគ្គលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច និងអ្នកចូលរួមដទៃទៀត

- ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធ ដើម្បីស៊ើបអង្កេតលើករណីសង្ស័យ ឬបទល្មើសក្នុងវិស័យបរធនបាលកិច្ច

- ពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការដាក់ពិន័យនានាលើបុគ្គលប្រព្រឹត្តិល្មើសក្នុងវិស័យបរធនបាលកិច្ច រួមទាំងការមិនអនុវត្តតាមសេចក្តីសម្រេចនានារបស់ **ន.ប.ធ.**

- ផ្សព្វផ្សាយនូវព័ត៌មាន ដើម្បីទប់ស្កាត់ពាក្យចចាមអារ៉ាមនានាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ និងវិស័យបរធនបាលកិច្ច

- ប្រមូល និងរក្សាទុកនូវភស្តុតាង ទិន្នន័យ និងការចាត់វិធានការពិន័យផ្សេងៗពាក់ព័ន្ធនឹងករណីប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច

- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំរាល់លិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ **ន.ប.ធ.**

- ធ្វើបច្ចុប្បន្នភាព រៀបចំ និងកែប្រែបទប្បញ្ញត្តិចាំបាច់នានា ព្រមទាំងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីជំរុញដល់ការអភិវឌ្ឍវិស័យបរធនបាលកិច្ច

- ចូលរួម និងផ្តល់យោបល់ផ្នែកច្បាប់ លើអនុស្សារណៈនៃការយោគយល់គ្នា ឬកិច្ចព្រមព្រៀងនានាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការឆ្លងវិស័យថ្នាក់តំបន់ និងអន្តរជាតិ

- ពិនិត្យ និងផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ក្នុងវិស័យបរធនបាលកិច្ច

- ចងក្រងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច

- អនុវត្តការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

### ២.៩.៤. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ មានការិយាល័យចំណុះចំនួន ៣ គឺ៖

១).ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍទីផ្សារ

២).ការិយាល័យបណ្តុះបណ្តាល និងផ្សព្វផ្សាយ និង

៣).ការិយាល័យសហប្រតិបត្តិការ

ដែលការិយាល័យទាំង៣ ខាងលើមានមុខងារ និងតួនាទី ដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវអំពីយុទ្ធសាស្ត្រនានា និងរៀបចំគម្រោងផែនការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើនវានុវត្តន៍បរធនបាលកិច្ច ព្រមទាំងផ្តល់យោបល់អំពីផលប៉ះពាល់ និងអត្ថប្រយោជន៍សម្រាប់អ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច

- ចូលរួមអនុវត្តការធ្វើសុខដុមនីយកម្មនៃក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិទៅក្នុងតំបន់

- រៀបចំវចនានុក្រមសម្រាប់វិស័យបរធនបាលកិច្ច

- រៀបចំ និងអនុវត្តផែនការបណ្តុះបណ្តាល អប់រំ កសាងសមត្ថភាព និងផ្សព្វផ្សាយពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច

- រៀបចំយន្តការ ឬបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងលើការបណ្តុះបណ្តាល ការអប់រំ ការកសាងសមត្ថភាព និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច

- រៀបចំលក្ខខណ្ឌ និងផ្តល់ការបញ្ជាក់ពីគុណវុឌ្ឍិរបស់បុគ្គលដែលតម្រូវដោយបទប្បញ្ញត្តិជាធរមាន

- តាមដាន និងវាយតម្លៃការអនុវត្តការបណ្តុះបណ្តាល ការអប់រំ ការកសាងសមត្ថភាព និងការផ្សព្វផ្សាយ

- រៀបចំ និងអនុវត្តផែនការសហប្រតិបត្តិការជាមួយនិយ័តកររបស់វិស័យបរធនបាលកិច្ចនៃបណ្តាប្រទេសផ្សេងទៀត និងដៃគូអភិវឌ្ឍន៍ជាតិអន្តរជាតិ

- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយនិយ័តកររបស់វិស័យបរធនបាលកិច្ចនៃបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក

- សម្របសម្រួលការអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ និងមូលនិធិផ្សេងៗ

- តាមដាន និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ និងដំណើរការវិវត្តន៍ជាអន្តរជាតិក្នុងវិស័យបរធនបាលកិច្ច

- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

# ជំពូកទី៣
# ប្រតិបត្តិការបរធនបាលកិច្ច
# នៅក្នុងប្រទេសកម្ពុជា

# ជំពូកទី៣
# ប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា

## ៣.១ ទិន្នន័យពាក់ព័ន្ធនិងវិស័យបរធនបាលកិច្ច

### ៣.១.១.បរធនបាលជំនួស

បរធនបាល អាចត្រូវបានជំនួសដោយបុគ្គលផ្សេងទៀត តាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ ករណីដែលគ្មានចែងអំពីលក្ខខណ្ឌ និង នីតិវិធីដូចមានចែងក្នុងប្រយោគខាងដើម បរធនបាលត្រូវបាន ជំនួសតាមលក្ខខណ្ឌដូចជា៖ (១) បើបរធនបាលជារូបវន្តបុគ្គល-បរធនបាលនេះត្រូវបានជំនួស (ក) ជាស្វ័យប្រវត្តិ នៅពេលដែល ខ្លួនទទួលមរណភាព អសមត្ថភាពផ្លូវកាយ ឬផ្លូវចិត្ត ត្រូវបានប្រកាស ដោយអាជ្ញាធរមានសមត្ថកិច្ចថាក្ស័យធន ប្រព្រឹត្តបទល្មើសមជ្ឈិម ឬឧក្រិដ្ឋ ឬតាមលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយបទប្បញ្ញត្តិ ជាធរមានរបស់និយ័តករបរធនបាលកិច្ច (ន. ប. ធ) / បញ្ញត្តិករ ពាក់ព័ន្ធ។(ខ) តាមសេចក្តីសម្រេចភាគច្រើនដាច់ខាតរបស់បរធន បាលទាំងអស់ នៅពេលដែលបរធនបាលចូលនិវត្តន៍ ឬបដិសេធ មិនបំពេញការងារ ឬមិនសក្តិសមបំពេញការងារ។(២) បើបរធនបាល ជានីតិបុគ្គលបរធនបាលនេះ ត្រូវបានជំនួសនៅពេលដែលបរ ធនបាល បញ្ឈប់សកម្មភាពរបស់ខ្លួន ហើយត្រូវបានជម្រះបញ្ជីឬ ត្រូវបានរំលាយ។

**ន ប. ធ.** / បញ្ញត្តិករពាក់ព័ន្ធជាអ្នកចេញសេចក្តីសម្រេច តែងតាំងបរធនបាលជំនួស។ ករណីបញ្ញត្តិ-ករពាក់ព័ន្ធតែងតាំងបរធនបាលជំនួស, បរធនបាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅនិយ័តករបរធន-បាលកិច្ច ( ន .ប .ធ) ។ ការជំនួសបរធនបាល អាចធ្វើបានលុះត្រាតែមាន ចែងលក្ខខណ្ឌ និងនីតិវិធី-ជំនួសបរធនបាលនៅក្នុងលិខិតបរធម៌- បាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន(ច្បាប់ស្តីពីបរធនបាលកិច្ច,២០១៩ ច្បាប់-ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែន ៣,២០២១)។[9]

### ៣.១.២.ក្រុមហ៊ុនដែលបានចុះបញ្ជីក្នុងនិយ័តករបរធនបាលកិច្ច

បរធនបាលកិច្ចដែលបានចុះបញ្ជី ក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលប្រតិបត្តិករបរធនបាល និងបុគ្គលពាក់ព័ន្ធដទៃទៀតនាយកដ្ឋានចុះបញ្ជីបទធនបាលគិតត្រឹមថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣៖

| □. | បរធនបាលកិច្ចបានចុះបញ្ជី | ចំនួន | ទំហំបរធន |
|---|---|---|---|
| 1. | បរធនបាលកិច្ចសាធារណៈ | 1 | $64,200,068 |
| 2. | បរធនបាលកិច្ចហិរញ្ញវត្ថុ | 9 | $369,271,960 |

[9] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញនៅថ្ងៃទី០៤ ខែតុលា ២០២១

| | | |
|---|---|---|
| 3. បរធនបាលកិច្ចពាណិជ្ជកម្ម | 602 | $735,791,945 |
| 4. បរធនបាលកិច្ចសង្គម | 1 | $1,018,468 |
| 5. បរធនបាលកិច្ចបុគ្គល | 7 | $2,185,553 |
| **សរុប** | **620** | **$1,172,467,994** |
| □□. បរធនបាលកិច្ចដែលទទួលបានអាជ្ញាប័ណ្ណ/ការអនុញ្ញាត និងក្រុមក្រុមហ៊ុនទទួលបានការទទួលស្គាល់ | | |
| 1. ក្រុមហ៊ុនបរធនបាល | 9 | |
| 2. ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិ-ភាព ឬរក្សាទុក (Escrow Services) នៅក្នុងវិ-ស័យបរធនបាលកិច្ច | 11 | |
| 3. បងធនបាលរូបវន្តបុគ្គលឯករាជ្យ | 24 | |
| 4. បរធនបាលរូបបុគ្គលនៃក្រុមហ៊ុនបរធនបាន | 22 | |
| **5.** ក្រុមហ៊ុនវាយតម្លៃនៅក្នុងវិស័យបងធន-បាលកិច្ច | 10 | |
| **III.** ការចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រ | | |
| **1.** ប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រ | 10 | |

### ៣.១.៣.បញ្ជីឈ្មោះក្រុមហ៊ុនបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និងការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច[10]

បញ្ជីឈ្មោះក្រុមហ៊ុនបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និងការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច

| ឈ្មោះក្រុមហ៊ុន | Company's Name |
|---|---|
| ១-ក្រុមហ៊ុន កាណា ត្រាស ឯ.ក | 1. Cana Trust Co., Ltd. |
| ២-ក្រុមហ៊ុន ហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក | 2. Phillip Trustee (Cambodia) Co., Ltd. |
| ៣-ក្រុមហ៊ុន ហាវត្រាស ឃែភីថល អ៊ិនវេសមិន ឯ.ក | 3. HAOTRUST Capital Investment Co., Ltd. |

[10] https://www.trustregulator.gov.kh/TrustyCompany.html (បានចូលទស្សនានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣)

| | |
|---|---|
| ៤-ក្រុមហ៊ុន អេសជី ថប ត្រាស ឯ.ក | 4. SG Top Trust Co., Ltd. |
| ៥-ក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក | 5. Stronghold Trustee Co., Ltd. |
| ៦-ក្រុមហ៊ុន ហ្គ្រេន កាថេ អ៊ិនវេសមិន ត្រាស (ខេមបូឌា) ម.ក | 6. Grand Cathay Investment Trust (Cambodia) Plc. |
| ៧-ក្រុមហ៊ុន ប៊ី.អាយ.ស៊ី ត្រាស ឯ.ក | 7. B.I.C Trust CO.,LTD. |
| ៨-ក្រុមហ៊ុន ដឹ ហ្វឹស ឆាយណា អ៊ិនវេសមេន អេន ត្រាស ឯ.ក | 8. The First China Investment and Trust Co., Ltd. |
| ៩. ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | 9. CIMB Bank Plc. |

### ៣.១.៤. បញ្ជីឈ្មោះបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ច[11]

បញ្ជីឈ្មោះបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ច

| ឈ្មោះ | បរធនបាលកិច្ច |
|---|---|
| ១-លោកបណ្ឌិត អ៊ិន ចាន់នី | បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ |
| ២-លោស្រី ម៉ារ អមរា | បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ |
| ៣-លោកស្រី Clark Heather | បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ |
| ៤-លោកស្រី គឹម សុធាវី | បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ |
| ៥-លោកស្រី ប៊ុត ប៊ុនសីហា | បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ |
| ៦-លោក ជា ហាង | បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ |
| ៧-លោក ស៊ីម សេនាជាតិ | បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ |

[11] https://www.trustregulator.gov.kh/TrustyIndependant.html (បានចូលទស្សនានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣)

| | |
|---|---|
| ៨-លោក អ៊ុំ សូផន | បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ |
| ៩-លោក យ៉ាង គីមស្រេង | បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ |
| ១០-លោក សាយ សូនី | បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ |
| ១១-លោក ជា ផល្លារិន | បរធនបាលកិច្ចហិរញ្ញវត្ថុ អមតៈ |
| ១២-លោក ហួត អៀងគុង | បរធនបាលកិច្ចហិរញ្ញវត្ថុហត្ថាកសិករ |
| ១៣-លោកស្រី អ៊ឹម វណ្ឌិត | បរធនបាលកិច្ចហិរញ្ញវត្ថុហត្ថាកសិករ |
| ១៤-លោក លី ស៊ីវ៉េន | បរធនបាលកិច្ចហិរញ្ញវត្ថុហត្ថាកសិករ |
| ១៥-លោកផូវ សំភី | បរធនបាលកិច្ចហិរញ្ញវត្ថុសីលានិធិ |
| ១៦-លោក ប៊ុន សីហា | បរធនបាលកិច្ចហិរញ្ញវត្ថុ ពាយ័ព្យ ហ្វាយនែនហ្សល ត្រាស់ |
| ១៧-លោក ចាន់ ម៉ាច | បរធនបាលកិច្ចហិរញ្ញវត្ថុក្រេឌីត |
| ១៨-លោកបណ្ឌិត ព្រំ វិសុទ្ធ | Mr. Prom Visoth |
| ១៩-លោក កូយ ឡេសាន | Mr. Koy Lesan |
| ២០-លោក អ៊ឹម ពិសី (មេធាវី) | Mr. Im Pisey ការិយាល័យមេធាវី វីចេង |
| ២១-លោក រស់ មុនិន្ទៈ (មេធាវី) | Mr. Ros Monin ក្រុមហ៊ុនមេធាវី ខេមជីន |
| ២២-ឧកញ៉ាបណ្ឌិត ប៊ុន មុនី | បរធនបាលកិច្ចហិរញ្ញវត្ថុ ស្ថាបនាសហគមន៍កម្ពុជា |
| ២៣-លោក ស៊ុំ សាកល | បរធនបាលកិច្ចហិរញ្ញវត្ថុ ស្ថាបនាសហគមន៍កម្ពុជា |
| ២៤-លោក អ៊ាប ប៊ុនថាន | បរធនបាលកិច្ចហិរញ្ញវត្ថុ ស្ថាបនាសហគមន៍កម្ពុជា |

### ៣.១.៥.បញ្ជីឈ្មោះប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក[12]

បញ្ជីឈ្មោះប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក

| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង |
|---|---|
| ១-ធនាគារ អេស៊ីលីដា ភីអិលស៊ី | ACLEDA Bank Plc |
| ២-ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) | Advanced Bank of Asia Limited. (ABA) |
| ៣-ធនាគារ ហ្វីលីព ភីអិលស៊ី | Phillip Bank Plc. |
| ៤-ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | J Trust Royal Bank Plc. |
| ៥-ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក | Asia-Pacific Development Bank Plc.. |
| ៦-ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | Maybank (Cambodia) Plc. |
| ៧-ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | BRED Bank (Cambodia) PLC. |
| ៨-ធនាគារ វីង (ខេមបូឌា) ម.ក | Wing Bank (Cambodia) Plc. |
| ៩-ធនាគារ ស្ថាបនា ភីអិលស៊ី | SATHAPANA BANK PLC. |
| ១០-ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | CIMB Bank Plc. |
| ១១-ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | BIC (CAMBODIA) BANK PLC. |

### ៣.១.៦.បញ្ជីឈ្មោះក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច[13]

បញ្ជីឈ្មោះក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច

| ឈ្មោះក្រុមហ៊ុន | Company´s Name |
|---|---|
| ១-ក្រុមហ៊ុន ស៊ី ភី អែល ខេមបូឌា ប្រភើធី លីមីតធីត | 1. C.P.L Cambodia Properties Limited. |
| ២-ក្រុមហ៊ុន មេហ្គា អាសិត មេនេចមិន | 2. Mega Asset Management Co., Ltd. |
| ៣-ក្រុមហ៊ុន ខូហ្សីហូម ឯ.ក | 3. Cozy Home Co., Ltd. |
| ៤-ក្រុមហ៊ុន ខ្មែរ រៀល អ៊ីស្តេត ឯ.ក | 4. Khmer Real Estate Co., Ltd. |

[12] https://www.trustregulator.gov.kh/OperatorDeposit.html (បានចូលទស្សនានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣)

[13] https://www.trustregulator.gov.kh/OperatorEvaluate.html(បានចូលទស្សនានៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣)

| | |
|---|---|
| ៥-ក្រុមហ៊ុន ខ្មែរ ហ្វោនដេសិន អឹព្រេហ្សល ខូអិលធីឌី | 5. Khmer Foundation Appraisal Co., Ltd. |
| ៦-ក្រុមហ៊ុន អេស អិម គ្លូបិល អឹព្រេហ្សល | 6. S M GLOBAL APPRAISAL Inc. |
| ៧- ក្រុមហ៊ុន អ៊ិនឌីភេនដិនថ៍ ប្រផឹធី សឺវីស ខូល អិលធីឌី | 7. Independent Property Services Co., Ltd. |
| ៨-ឃី រៀល អ៊ីស្ទេត | 8. Key Real Estate Co., Ltd. |
| ៩- ខេត អឹព្រេហ្សល ឯ.ក | 9. KAT APPRAISAL CO., LTD. |
| ១០- ណាយ ហ្វ្រែង (ខេមបូឌា) | 10.Knigt Frank (Combodia) Pte., Ltd. |

### ៣.១.៧. សេចក្តីសម្រេច ឬគោលការណ៍ណែនាំ

- សេចក្តីណែនាំស្តីពីបែបបទនៃការអនុវត្តការងាររបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- សេចក្តីសម្រេចលេខ ០៧ សសរ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពគណ:- កម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

- សេចក្តីសម្រេចលេខ ០៦៤ សហវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

- គោលការណ៍ណែនាំស្តីពីការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការស៊ើបអង្កេត និងកិច្ចសហការជាតិក្នុងការស៊ើបអង្កេត

- គោលការណ៍ណែនាំរួមស្តីពី "ការចុះបញ្ជី និងការស្នើសុំការអនុញ្ញាតបន្ថែមរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ"

- សេចក្តីណែនាំស្តីពី "ការរាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដោយបុគ្គលរាយការណ៍សម្រាប់វិស័យធានារ៉ាប់រងសុខភាព"

-គោលការណ៍ណែនាំស្តីពី "បែបបទនិងយន្តការពិគ្រោះយោបល់ពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។

## ៣.២. ប្រតិបត្តិការបរធនបាលកិច្ច

### ៣.២.១. បរធនបាលកិច្ចបុគ្គល

បរធនបាលកិច្ចបុគ្គល គឺជាប្រភេទមួយក្នុងចំណោមប្រភេទ បរធនបាលកិច្ច ៣ ប្រភេទផ្សេងទៀតរួមមាន៖ បរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចពាណិជ្ជកម្ម និងបរធនបាលកិច្ចសង្គម។ បរធនបាលកិច្ច

បុគ្គល ត្រូវបាន បង្កើតឡើងដោយបរធនបាលទាយក ដើម្បីផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិទៅឱ្យបរធនបាលធ្វើការចាត់ចែង គ្រប់គ្រង និងថែរក្សាជំនួស សម្រាប់ជាប្រយោជន៍របស់បរធនបាលទាយកខ្លួនឯងវិញ ឬសម្រាប់បុគ្គលដែលបានកំណត់ជាក់លាក់ (ច្បាប់ស្តីពីបរធនបាលកិច្ច ២០១៩)។ បរធនបាលកិច្ចបុគ្គលនេះ ត្រូវបានកំណត់លក្ខខណ្ឌ សិទ្ធិ កាតព្វកិច្ច និងការ ទទួលខុសត្រូវ ដោយមានការព្រមព្រៀងរវាងបរធនបាលទាយក បរធនបាល និងអត្ថគាហកៈ តាមរយៈលិខិតបរធន- បាលកិច្ច។

ការបង្កើតបរធនបាលកិច្ចបុគ្គល អាចធ្វើក្នុងលក្ខខណ្ឌដែលៈ (១).បរធនបាលទាយកជារូបវន្តបុគ្គលដែល ធ្វើប្រទានកម្មទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួនឱ្យទៅបរធនបាល សម្រាប់ជាប្រយោជន៍របស់ខ្លួនផ្ទាល់ ឬរបស់បុគ្គល ផ្សេងទៀត ឬ (២).ការផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិដោយបរធនបាលទាយក ដែលនៅមានជីវិត ហើយត្រូវធ្វើលិខិត បរធនបាលកិច្ចដោយមានការបញ្ជាក់ពីសារការី មេធាវី ឃុំសង្កាត់ ឬករណីបរធនបាលទាយកធ្វើមតកសាសន៍ នៅពេល ដែលបរធនបាលទាយកនោះទទួលមរណភាព ដែលតាមរយៈមតកសាសន៍នេះ បង្កើតជាបរធនបាលកិច្ច ស្របតាម ក្រមរដ្ឋប្បវេណី។ បរធនបាលកិច្ចបុគ្គល ត្រូវទទួលបានការអនុញ្ញាតឱ្យបង្កើត និងចុះបញ្ជីនៅ **ន. ប. ធ.**។

### ៣.២.២. បរធនបាលកិច្ចសង្គម

បរធនបាលកិច្ចសង្គម ត្រូវបានបង្កើតឡើងនៅពេលដែល បរធនបាលទាយក ធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបរធនបាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គម ដូចជាគោលបំណង វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)។

លក្ខណៈបរធនបាលកិច្ចសង្គម ត្រូវបានកំណត់ជា ២ ដូចខាងក្រោមៈ

- **មូលនិធិពិសេសៈ** (ក).មូលនិធិដែលបង្កើតដោយបរធនបាលទាយកតាមរយៈប្រទានកម្ម ឬមតកសាសន៍, (ខ).តាមរយៈការទទួលទ្រព្យសម្បត្តិពីអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនៅមានជីវិត ឬទទួលទ្រព្យសម្បត្តិតាមមតក- សាសន៍របស់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច, (គ).ទ្រព្យសម្បត្តិត្រូវបានផ្ទេរឱ្យទៅបរធនបាលដើម្បីបំពេញគោលបំណង ជាប្រយោជន៍សង្គម, (ឃ).មិនស្វែងរកប្រាក់ចំណេញ ឬគ្មានប្រតិបត្តិការជាសហគ្រាសពាណិជ្ជកម្ម និង (ង).លើកលែង តែមានចែងផ្សេងក្នុងលិខិតបរធនបាលកិច្ច ទ្រព្យសម្បត្តិដំបូង និងទ្រព្យសម្បត្តិបន្ថែមផ្សេងទៀត ដែលអ្នកផ្តល់វិភាគទាន បរធនបាលកិច្ចបានផ្ទេរចូលមូលនិធិណាមួយ ត្រូវរក្សាទុកដើម្បីបំពេញគោលបំណងបរធនបាលកិច្ច ហើយអនុញ្ញាតឱ្យចែកចាយតែផលដែលបានពីទ្រព្យសម្បត្តិនោះប៉ុណ្ណោះ។

- **មូលនិធិសម្រាប់ជាប្រយោជន៍ដល់អង្គការវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រៈ** ទ្រព្យសម្បត្តិទទួលពីបុគ្គល រួមមាន ប្រទានកម្ម ឬមតកសាសន៍ ហើយទ្រព្យសម្បត្តិនេះត្រូវបានផ្ទេរ ដើម្បីបម្រើគោលដៅសម្រាប់ជាប្រយោជន៍ ជាអាទិ៍ វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

### ៣.២.៣. បរធនបាលកិច្ចពាណិជ្ជកម្ម

យោងតាមច្បាប់ស្តីពីបរធនបាលកិច្ច ឆ្នាំ២០១៩ បរធនបាលកិច្ច ត្រូវបានបែងចែកជា ៤ ប្រភេទ រួមមាន៖ (១).បរធនបាលកិច្ចពាណិជ្ជកម្ម, (២).បរធនបាលកិច្ចសាធារណៈ, (៣).បរធនបាលកិច្ចសង្គម និង (៤).បរធនបាលកិច្ច បុគ្គល។

អ្វីទៅជាបរធនបាលកិច្ចពាណិជ្ជកម្ម? តើវាមានលក្ខណៈដូចម្តេចខ្លះ?

បរធនបាលកិច្ចពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ឬគោលបំណង ផ្សេងទៀត សម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬបុគ្គលណាមួយជាក់លាក់ដែលកំណត់ដោយ អ្នកផ្តល់វិភាគទានបរធនបាលកិច្ចនោះ។

លក្ខណៈនៃបរធនបាលកិច្ចពាណិជ្ជកម្មមាន ៣ ធំៗដូចខាងក្រោម៖

- មូលនិធិសោធននិវត្តន៍ មូលនិធិអប់រំ និងមូលនិធិប្រហាក់ប្រហែល ដែលត្រូវបានផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិ ទាំងនោះទៅឱ្យបរធនបាល គ្រប់គ្រង និងចាត់ចែង ឬវិនិយោគ ដើម្បីជាប្រយោជន៍ដល់ម្ចាស់មូលនិធិ អ្នកផ្តល់វិភាគទាន ឬបុគ្គលផ្សេងទៀត

- សេវារក្សាទុកដែលទ្រព្យសម្បត្តិ ឬមូលនិធិ ត្រូវបានផ្ទេរដោយបុគ្គលណាមួយឱ្យទៅបរធនបាលគ្រប់គ្រង និងចាត់ចែង ហើយបរធនបាលនោះ ត្រូវផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិនោះត្រឡប់ទៅបុគ្គលនោះវិញ ឬបុគ្គលណាមួយ ផ្សេងទៀត។ រក្សាទុកនូវទ្រព្យសម្បត្តិ ឬមូលនិធិនេះ អាចត្រូវបានរក្សាទុកនៅមន្ទីរសារការី ឬការិយាល័យមេធាវី ឬក្រុមហ៊ុន គណនេយ្យ ឬនៅសេវារក្សាទុកផ្សេងទៀត ដែលមានការអនុញ្ញាតពីបញ្ញត្តិករពាក់ព័ន្ធ ដូចជា ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងសកម្មភាព ដែលស្ថិតក្រោមតួនាទី និងភារកិច្ចរបស់ខ្លួន (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)

- គម្រោងភាគហ៊ុននិយោជិត ឬផលប្រយោជន៍និយោជិត នៅពេលដែលបរធនបាល គ្រប់គ្រងទ្រព្យសម្បត្តិ ឬមូលនិធិ ដើម្បីវិនិយោគក្នុងនាមនិយោជិតនោះ (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)។

### ៣.២.៤. បរធនបាលកិច្ចហិរញ្ញវត្ថុ

បរធនបាលកិច្ចហិរញ្ញវត្ថុ សំដៅដល់មូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុល ដែលដៃគូអភិវឌ្ឍន៍ផ្តល់ ឱ្យរដ្ឋាភិបាល ដែលកំពុងត្រូវបានគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យធនាគារនិងវិស័យ មីក្រូហិរញ្ញវត្ថុ។

### ៣.២.៥. បរធនបាលកិច្ចសាធារណៈ

បរធនបាលកិច្ចសាធារណៈ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទូទៅ។

បរធនបាលកិច្ចសាធារណៈនេះ រួមមានៈ

- **ការអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅពេលដែលៈ** (ក).ដៃគូអភិវឌ្ឍផ្តល់ទ្រព្យសម្បត្តិ ឬ មូលនិធិរបស់ខ្លួន សម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ហើយទ្រព្យសម្បត្តិ ឬមូលនិធិទាំងនោះបាននិងកំពុង គ្រប់គ្រង និងចាត់ចែងនៅក្នុងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀត និង (ខ).តាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

- ជាប្រយោជន៍សាធារណៈផ្សេងទៀតនៅពេលដែលបញ្ញត្តិករពាក់ព័ន្ធតែងតាំងបរធនបាល ដើម្បីគ្រប់គ្រង និងការពារមូលនិធិនានា តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ លក្ខខណ្ឌ ទាំងនេះ មានជាអាទិ៍ៈ (ក).មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាល ឬត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា ដើម្បីបំពេញគោលបំណងជាក់លាក់ណាមួយរបស់អ្នកផ្តល់ជំនួយ ហើយអ្នកផ្តល់ជំនួយទាមទារឱ្យមូលនិធិនេះ ត្រូវបានចាត់ចែងប្រើប្រាស់ និងអាស្រ័យផលស្របតាមគោលបំណងរបស់ខ្លួន ឬ (ខ).ត្រូវការពារផលប្រយោជន៍របស់ កុមារ ឬអសមត្ថជនផ្សេងទៀត ឬ (គ).មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋតាមបទប្បញ្ញត្តិជាធរមាន។[14]

## ៣.៣. ប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ច

### ៣.៣.១. ការចុះបញ្ជីបរធនបាល

បរធនបាលកិច្ចទាំងអស់មានសុពលភាព លុះត្រាតែចុះបញ្ជីនៅនិយ័តករបរធនបាលកិច្ច ក្នុងរយៈពេលមិន លើសពី ៣ (បី) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ច។ លក្ខខណ្ឌ និងនីតិវិធីលម្អិតនៃការចុះបញ្ជី ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច។ មុននឹងធ្វើការចុះបញ្ជីសម្រាប់ប្រតិបត្តិករបរធនបាលកិច្ចនៅ **ន.ប.ធ.** ស្របតាមមាត្រា២៨ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) ការបង្កើតបរធនបាលកិច្ច ដើម្បីគោលបំណង ណាមួយនៃច្បាប់នេះ ត្រូវមានការអនុញ្ញាតជាគោលការណ៍ជាមុនពី **ន.ប.ធ.**/បញ្ញត្តិករពាក់ព័ន្ធ។ ការធ្វើប្រតិបត្តិការនៃបរធនបាលកិច្ចស្របតាមគោលបំណងនៃច្បាប់ស្តីពីបរធនបាលកិច្ច ត្រូវមានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.**/បញ្ញត្តិករ ពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិដែលមានជាធរមាន។

**ន.ប.ធ.** មានកាតព្វកិច្ចកត់ត្រា គ្រប់គ្រង និងរក្សាទុកនូវរាល់ ព័ត៌មានរបស់ បរធនបាលទាយក, បរធនបាល, អត្ថគាហកៈ, បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ, ប្រតិវេទន៍ប្រចាំឆ្នាំ, ការផ្លាស់ប្តូរបរធនបាល និងព័ត៌មានចាំបាច់ផ្សេងៗពាក់ព័ន្ធនឹងការចុះបញ្ជី។ លក្ខខណ្ឌ និងនីតិវិធីធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងសេចក្តីជូន

[14] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី០២ ខែសីហា ២០២១

ដំណឹងពីការផ្លាស់ប្តូរបរធនបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.។[15]

### ៣.៣.២. ការត្រួតពិនិត្យបរធនបាលកិច្ច

រាល់ប្រតិបត្តិការនៃបរធនបាលកិច្ច ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ **ន.ប.ធ.**/បញ្ញត្តិករពាក់ព័ន្ធ ដើម្បី ការពារការប្រើប្រាស់បរធនឱ្យស្របតាមគោលបំណងបរធនបាលកិច្ច។ ករណីចាំបាច់ដែលមិនមានការកំណត់ផ្សេងពីនេះ **ន.ប.ធ.**/បញ្ញត្តិករ អាចតម្រូវឱ្យធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយសវនករឯករាជ្យ។ សវនករឯករាជ្យ ត្រូវមានការយល់ព្រមពី **ន.ប.ធ.** ហើយចំណាយលើសវនកម្មជាបន្ទុករបស់បរធនបាលកិច្ច។ តាមសំណើរបស់ **ន.ប.ធ.** និងមិនមានការកំណត់ផ្សេងពីនេះពីបញ្ញត្តិករពាក់ព័ន្ធ បរធនបាល ត្រូវអនុញ្ញាតឱ្យមានការត្រួត- ពិនិត្យលើកំណត់ត្រាបរធនបាលកិច្ច និងផ្តល់របាយការណ៍ហិរញ្ញវត្ថុ ឬព័ត៌មានផ្សេងទៀត (ច្បាប់ស្តីពីបរធនបាលកិច្ច ឆ្នាំ២០១៩)។

### ៣.៣.៣. ការបញ្ចប់បរធនបាលកិច្ច

បរធនបាលកិច្ច ត្រូវបានបញ្ចប់ក្នុងករណីមួយចំនួនដូចជា៖ (១).ការមកដល់នៃកាលវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច, (២).បានសម្រេចគោលបំណងរបស់បរធនបាលកិច្ច, (៣).ការសម្រេចដោយឆន្ទានុសិទ្ធិ ឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក, (៤).តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬ (៥).តាមករណីផ្សេងទៀត ដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

នៅពេលបញ្ចប់បរធនបាលកិច្ច បរធនបាល ត្រូវប្រគល់របាយការណ៍នៃការគ្រប់គ្រងបរធនបាលកិច្ចទៅ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**)./បញ្ញត្តិករពាក់ព័ន្ធ ដោយលម្អិតអំពីព័ត៌មាននៃបរធនដែលនៅសល់ ចំណូល ចំណាយ និងព័ត៌មានដែលចាំបាច់ ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

បរធនបាលកិច្ច ត្រូវបន្តអានុភាពអនុវត្តរហូតដល់បញ្ចប់ការជម្រះបញ្ជី ហើយដែលអ្នកជម្រះបញ្ជីត្រូវជ្រើសរើស ដោយបុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច។ បរធននៅសល់ក្រោយពីការជម្រះបញ្ជី ត្រូវបែងចែក ឬផ្តល់ ឱ្យទៅបរធនបាលទាយក ឬបុគ្គលផ្សេងទៀត ដូចមានចែងក្នុងលិខិតបរធនបាលកិច្ច ឬទុកជាទ្រព្យសម្បត្តិរដ្ឋ (ច្បាប់ស្តីពី បរធនបាលកិច្ច, ២០១៩)។[16]

[15] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី១១ ខែតុលា ២០២១

[16] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញផ្សាយនៅថ្ងៃទី២៥ ខែតុលា ២០២១

### ៣.៣.៤. កិច្ចគាំពារវិនិយោគិនក្នុងវិស័យបរធនបាលកិច្ច

#### ៣.៣.៤.១. ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដោះស្រាយដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃ **ន.ប.ធ.** លើកលែងតែមានការកំណត់ផ្សេងពីនេះដោយបញ្ញត្តិការពាក់ព័ន្ធ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទជាកម្មវត្ថុនៃបណ្តឹងរដ្ឋបាល ឬបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។ ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះ- ស្រាយវិវាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាម សំណើរបស់ **ន.ប.ធ.** (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុ នៃមនធនាគារ, ២០២១)។

#### ៣.៣.៤.២. ការធ្វើអធិការកិច្ចក្នុងវិស័យបរធនបាលកិច្ច

អគ្គនាយកនៃ **ន.ប.ធ.** មានសិទ្ធិចាត់តាំងមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់ស្តីពីបរធនបាលកិច្ច។ មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មានសិទ្ធិធ្វើអធិការកិច្ចលើ បរធនបាលកិច្ច និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ **ន.ប.ធ.**។ មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មាន សិទ្ធិតាមដាន ត្រួតពិនិត្យ ស្រាវជ្រាវ និងស៊ើបអង្កេតបទល្មើសក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច ដោយអនុវត្តឱ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បែបបទ និងនីតិវិធី នៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** តាម សំណើរបស់ **ន.ប.ធ.** (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

#### ៣.៣.៤.៣. ការពិនិត្យ និងការស៊ើបអង្កេតបទល្មើសក្នុងវិស័យបរធនបាលកិច្ច

ក្នុងក្របខណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការពិនិត្យ និងការស៊ើបអង្កេតបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មានសិទ្ធិអំណាចធ្វើការឆែកឆេរ, ចាប់យកវត្ថុតាង,

កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណី ចាំបាច់ដែលត្រូវឃាត់ខ្លួនជនសង្ស័យ មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។

រាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ក្នុងការពិនិត្យ, ស៊ើបអង្កេតបទល្មើស និងការឃាត់ខ្លួនជនសង្ស័យត្រូវអនុវត្ត ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិ ស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធផ្សេងទៀត ដើម្បី ចូលរួមបង្ក្រាបបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច។ នៅក្នុងដំណើរការអធិការកិច្ចបរធនបាលកិច្ច ក្នុងករណីមានភស្តុតាង ឬលទ្ធផលវិភាគផ្ទៀងផ្ទាត់បញ្ជាក់ថាមានការធ្វើបរធនបាលកិច្ច ដែលផ្ទុយពីការអះអាងនឹងការផ្តល់សិទ្ធិនៅក្នុងលិខិតបរធនបាលកិច្ច មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិចាត់វិធានការផ្អាកជាបណ្តោះអាសន្ន (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ,២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១) ។

### ៣.៣.៤.៤. ការប្តឹងតវ៉ាពីវិធានការរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច អាចប្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ទៅ **ន.ប.ធ.** គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច។ **ន.ប.ធ.** ត្រូវសម្រេចលើ បណ្តឹងតវ៉ា ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង។ ក្នុងករណីបុគ្គលនោះមិនសុខចិត្ត ចំពោះសេចក្តីសម្រេចរបស់ **ន.ប.ធ.** បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

### ៣.៣.៤.៥.វិធានសម្រាប់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចក្នុងការប្រតិបត្តិការអនុវត្តច្បាប់

នៅពេលធ្វើប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវស្លៀកពាក់ឯកសណ្ឋាន, ពាក់សញ្ញាសម្គាល់, និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។ ឯកសណ្ឋាន, សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់ មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** តាមសំណើរបស់ **ន.ប.ធ.** ។ មន្ត្រីអធិការកិច្ចបរធន

បាលកិច្ច ដែលបំពេញមុខងារ និងភារកិច្ចត្រឹមត្រូវតាមច្បាប់ស្តីពីបរធនបាលកិច្ច ត្រូវបានការពារដោយច្បាប់ (ច្បាប់ស្តីពីបរធន- បាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា, ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា, ២០២១)។

### ៣.៣.៤.៦. ការផាកពិន័យចំពោះប្រតិបត្តិការដែលមិនបានមកស្នើសុំចុះបញ្ជីបរធន

យោងតាមមាត្រា៤៣ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាល ដែលធ្វើប្រតិបត្តិការដោយមិនបានមកស្នើសុំចុះបញ្ជីបរធន ដូចមានកំណត់ក្នុងមាត្រា២៨ នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ច បរធនបាលកិច្ច ពី ២០ ០០០ ០០០ (ម្ភៃលាន)រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន)រៀល និងត្រូវបញ្ឈប់សកម្មភាព បរធនបាលកិច្ចជាបន្ទាន់ រួចតម្រូវឱ្យមកចុះបញ្ជីបរធននៅ **ន.ប.ធ.** ស្របតាមបទប្បញ្ញត្តិនៃច្បាប់។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល និង/ឬដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ១ (មួយ)ឆ្នាំ (ច្បាប់ស្តីពីបរធនបាលកិច្ច,២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២១; អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២១)។

### ៣.៣.៤.៧. ការផាកពិន័យចំពោះការមិនរាយការណ៍ ការមិនផ្តល់ព័ត៌មាន និងការមិនផ្តល់របាយការណ៍

យោងតាមមាត្រា ៤៤ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាល ត្រូវផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ពី ២០ ០០០ ០០០ (ម្ភៃលាន)រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន)រៀល ចំពោះអំពើដូចជា៖ (១).មិនបានរាយការណ៍ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចឱ្យបរធនបាលទាយក អត្ថគាហកៈ និងបញ្ញត្តិករពាក់ព័ន្ធ និង (២).មិនផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិករពាក់ព័ន្ធ និងទៅ ន.ប.ធ.។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល និង/ឬដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ១ (មួយ)ឆ្នាំ (ច្បាប់ស្តីពីបរធនបាលកិច្ច ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការបព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ,

២០២១; អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមទិវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

### ៣.៣.៤.៨. ការផ្តន្ទាទោសចំពោះបុគ្គលដែលប្រព្រឹត្តល្មើសក្នុងវិស័យបរធនបាលកិច្ច

យោងតាមមាត្រា ៤៥ នៃច្បាប់ស្ដីពីបរធនបាលកិច្ច (២០១៩) បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើស ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះអំពើណាមួយក្នុងវិស័យបរធនបាលកិច្ចក្នុងចំណោម អំពើដូចជា៖ (១).រំលោភលើទំនុកចិត្ត ឬរំលោភអំណាចក្នុងការបំពេញមុខងាររបស់បរធនបាល ក្នុងគោលបំណងទទួល ផលប្រយោជន៍ផ្ទាល់ខ្លួន ឬដល់តតិយជន ឬក្នុងគោលបំណងធ្វើឱ្យខូចប្រយោជន៍ដល់ភាគីពាក់ព័ន្ធ, (២).ឆបោកក្នុង វិស័យបរធនបាលកិច្ច ដែលប្រព្រឹត្តដោយបរធនបាល, (៣).រារាំង ឬជ្រៀតជ្រែកដល់មន្ត្រីអធិការកិច្ចក្នុងការបំពេញមុខងារ ដូចមានចែងក្នុងមាត្រា៣៥ នៃច្បាប់នេះ, (៤).ក្លែងបន្លំឯកសារ ឬបំភ័ន្តនិយ័តករបរធនបាលកិច្ច ឬផ្សព្វផ្សាយ ឬផ្តល់ ព័ត៌មានមិនពិតប្រព្រឹត្តដោយបរធនបាល ដែលនាំឱ្យខូចផលប្រយោជន៍ដល់ភាគីពាក់ព័ន្ធ និង (៥).បំផ្លាញឯកសារ ភស្តុតាងនៃបទល្មើសក្នុងវិស័យបរធនបាលកិច្ច ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្រាវជ្រាវរបស់មន្ត្រីអធិការកិច្ច ឬមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ច្បាប់ស្ដីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់ អាជ្ញាធសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

### ៣.៣.៤.៩.ការផ្តន្ទាទោសពិន័យជាប្រាក់ចំពោះបរធនបាលដែលប្រព្រឹត្តល្មើស

មាត្រា ៤៦ និង ៤៧ នៃច្បាប់ស្ដីពីបរធនបាលកិច្ច (២០១៩) បានចែងថា បរធនបាលដែលមានចេតនាផ្តល់ព័ត៌មានមិនពិតក្នុងការចុះបញ្ជីបរធនដំបូង ឬចុះបញ្ជីបរធនបន្ត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ ២០០ ០០០ ០០០ (ពីររយលាន)រៀល និង/ឬដាក់ពន្ធនាគារ ពី ៦ (ប្រាំមួយ)ខែ ទៅ ៣ (បី)ឆ្នាំ។ បុគ្គល ឬបរធនបាលដែលចូលរួមប្រព្រឹត្តបទល្មើសទាក់ទងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដោយអនុលោមតាមច្បាប់ស្ដីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន។

បរធនបាល ដែលទម្លាយការសម្ងាត់វិជ្ជាជីវៈដែលបណ្តាលឱ្យខូចនូវផលប្រយោជន៍ភាគីពាក់ព័ន្ធ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល និង/ឬ ដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ១ (មួយ)ឆ្នាំ (ច្បាប់ស្ដីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្ដីពីការរៀបចំនិង

ការប្រព្រឹត្តទៅ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

យោងតាមមាត្រា៤៨ និង៤៩ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាល ដែលទម្លាយការសម្ងាត់វិជ្ជាជីវៈដែលបណ្តាលឱ្យខូចនូវផលប្រយោជន៍ភាគីពាក់ព័ន្ធ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពី ៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល និង/ឬដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ១ (មួយ)ឆ្នាំ។ នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ នៃច្បាប់នេះ ស្តីពី ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងកថាខណ្ឌទី២ នៃ មាត្រា៤៣ កថាខណ្ឌទី២ នៃមាត្រា៤៤, និងចំណុចទី១ ទី៤ និងទី៥ នៃមាត្រា៤៥ មាត្រា ៤៦ និងមាត្រា៤៨ នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ ២០០ ០០០ ០០០ (ពីររយ លានរៀល) និងមិនអនុញ្ញាតឱ្យធ្វើជាបរធនបាលនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ ស្តីពីទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

យោងតាមមាត្រា៥០ និង៥១ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បានចែងថា រូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៤៣ កថាខណ្ឌទី២ នៃមាត្រា៤៤ និងមាត្រា៤៥ ដល់មាត្រា៤៨ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា៥៤ ( ប្រភេទទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ដោយរួមទាំងការសម្រេចមិនអនុញ្ញាតឱ្យធ្វើជាបរធនបាលនៅព្រះរាជាណាចក្រកម្ពុជា។ ចំណែកខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។ ចំពោះបទ- ល្មើសទាំងឡាយណាដែលពុំមានចែងនៅក្នុងច្បាប់នេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ( ច្បាប់ស្តីពីបរធនបាលកិច្ច,២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

### ៣.៣.៤.១០.បណ្តឹងតវ៉ាពីសេចក្តីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច

យោងតាមមាត្រា៥២ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ ពីសេចក្តីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចដូចមានចែងនៅក្នុងជំពូកទី៦ នៃច្បាប់នេះ អាចប្តឹងតវ៉ាជាលាយ- លក្ខណ៍អក្សរទៅ **ន.ប.ធ.** ក្នុងរយៈពេល ៣០ ( សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេ

ច។ **ន.ម.ធ.** ត្រូវ សម្រេចលើបណ្តឹងតវ៉ា ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង។ ក្នុងករណីបុគ្គលនោះ មិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ **ន.ម.ធ.** បុគ្គលនោះមានសិទ្ធិផ្ញើបណ្តឹងទៅតុលាការតាមនីតិវិធី ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច (ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាព ក្រោមឱវាទរបស់ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)។

## ៣.៤.ការវិនិយោគលើវិស័យបរធនបាលកិច្ច

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ភូមិន្ទបាលបានចែងថា មានតែប្រជាពលរដ្ឋខ្មែរ និង/ឬបុគ្គលទទួលបានសញ្ជាតិខ្មែរទេ ដែលមានសិទ្ធិក្លាយជាកម្មសិទ្ធិករលើដី រីឯជនបរទេសគឺមិនមានសិទ្ធិនេះឡើយ។ តាមការអនុវត្តកន្លងមក វិនិយោគិនបរទេសអាចបណ្តាក់ទុនលើវិស័យអចលនទ្រព្យ បាន តាមរយៈការឱ្យបុគ្គល ឬក្រុមហ៊ុនដែលមានសញ្ជាតិខ្មែរ ឈរឈ្មោះជំនួស ធ្វើជាកម្មសិទ្ធិករលើដី និងមានការរៀបចំឯកសារគតិយុត្តមួយចំនួនដើម្បីការពារ ផលប្រយោជន៍របស់វិនិយោគិនបរទេសនោះ។

ក៏ប៉ុន្តែទាំងបុគ្គលឈរឈ្មោះជំនួស និងឯកសារគតិយុត្តទាំងនោះ មិនត្រូវ បានទទួលស្គាល់ដោយអាជ្ញាធរសាធារណៈណាមួយឡើយ។ ភាពខ្វះចន្លោះនេះហើយដែលបង្កជាហានិភ័យខ្ពស់ដល់វិនិយោគិនបរទេស ព្រោះបុគ្គលឈរឈ្មោះជំនួសអាចឆ្លៀតឱកាសចាត់ចែង អចលនទ្រព្យដោយឯកឯង ជាពិសេសនៅពេលដែលតម្លៃអចលនទ្រព្យមានការកើនឡើងខ្ពស់។ចំណុចពិសេសរបស់បរធនបានកិច្ចគឺ វិនិយោគិនបរទេសទទួលបានការការពារពីច្បាប់ និងស្ថាប័នអនុវត្តច្បាប់ (បើប្រៀបធៀបជាមួយនឹងប្រព័ន្ធគ្រប់គ្រងអចលនទ្រព្យជំនួសពីមុន ដែលមាន ការចំណាយច្រើនហើយទទួលរងហានិភ័យខ្ពស់)។ តាមរយៈបរធនបាលកិច្ចវិនិយោគិនបរទេសអាច កាន់កាប់អចលនទ្រព្យ តាមការជ្រើសតាំងបរធនបាលឱ្យធ្វើការគ្រប់គ្រងអចលនទ្រព្យជំនួសដោយមានការកំណត់នូវសិទ្ធិនិងកាតព្វកិច្ចឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរនៅក្នុងឯកសារផ្លូវ ច្បាប់ហៅថា «លិខិតបរធនបាលកិច្ច»។

បរធនបាលជាបុគ្គលដែលត្រូវមានការទទួលស្គាល់ពី និយ័តករបរធនបាលកិច្ច ហើយលិខិតបរធនបាលកិច្ចក៏ត្រូវចុះបញ្ជីនៅនិយ័តករបរធនបាលកិច្ចផងដែរ។ដូចនេះសិទ្ធិរបស់វិនិយោគិនបរទេសគឺត្រូវបានទទួល

ស្គាល់ដោយអាជ្ញាធរសាធារណៈដែលអនុញ្ញាតឱ្យពួកគេផ្ទេរ ឬ បញ្ចាំអចលនទ្រព្យបានយ៉ាងងាយស្រួល ដោយមិនពឹងផ្អែកទាំងស្រុងលើបុគ្គលឈរឈ្មោះជំនួសដូចពីមុននោះឡើយ។[17]

ទោះបីជាមានចំណុចពិសេសដូចខាងលើក៏ពិតមែន វិស័យបរធនបាលកិច្ចអាចចាត់ទុកថា ជាវិស័យមួយដែលថ្មីនៅកម្ពុជា ហេតុនេះឯកសារផ្លូវច្បាប់មួយចំនួននៅមានភាពស្មុគស្មាញច្រើន និងតម្រូវឱ្យមានភាពបត់បែនផងដែរ។ ហេតុនេះវិនិយោគិនគួរស្វែងរកការប្រឹក្សាយោបល់ពី អ្នកជំនាញជាមុនសិន ដើម្បីឱ្យការប្រើប្រាស់បរធនបាលកិច្ចស្របទៅនឹងកម្មវត្ថុវិនិយោគរបស់ខ្លួន ហើយស្របតាមខ្លឹមសារនិងនីតិវិធីច្បាប់។

## ៣.៤.អត្ថប្រយោជន៍នៃការវិនិយោគក្នុងវិស័យបរធនបាលកិច្ច

បរធនបាលកិច្ចសាធារណៈ ត្រូវបានបង្កើតឡើងក្នុងគោលបំណងជាប្រយោជន៍របស់ពលរដ្ឋខ្មែរទូទៅតាមរយៈ៖

១. ការអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា (បរធនបាលកិច្ចហិរញ្ញវត្ថុ) ហើយទ្រព្យសម្បត្តិមូលនិធិទាំងនោះ បាននិងកំពុងគ្រប់គ្រង និងចាត់ចែងនៅក្នុងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុឬបុគ្គលផ្សេងទៀត។[18]

២. ការតែងតាំងបរធនបាលដោយបញ្ញត្តិករពាក់ព័ន្ធសម្រាប់ជាប្រយោជន៍សាធារណៈផ្សេងទៀត រួមមាន៖ មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាល ឬត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, ដែលធ្លាក់ទៅជាទ្រព្យរដ្ឋ, ការការពារផលប្រយោជន៍របស់កុមារ ឬអសមត្ថជន។ បរធនបាលកិច្ចសង្គម៖ ត្រូវបានបង្កើតឡើងសម្រាប់ជាប្រយោជន៍ទូទៅក្នុងសង្គម (វប្បធម៌, អប់រំ, សាសនា, មនុស្សជាតិ ឬវិទ្យាសាស្ត្រ) តាមរយៈ ការធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់បរធនបាលទាយកទៅឱ្យបរធនបាលរួមមាន៖ មូលនិធិពិសេស (ប្រទានកម្មឬមតកសាសន៍, និងមិនស្វែងរកប្រាក់ចំណេញ) និងមូលនិធិសម្រាប់ប្រយោជន៍ដល់អង្គការវប្បធម៌ អប់រំ មនុស្សជាតិសាសនា ឬវិទ្យាសាស្ត្រ ដែលទទួលបានតាមរយៈប្រទានកម្ម ឬមតកសាសន៍។ ជារួម បរធនបាលកិច្ចទាំង២ គឺសម្រាប់ជាប្រយោជន៍ដល់ពលរដ្ឋខ្មែរ និងសង្គមខ្មែរដូចគ្នា គ្រាន់តែរូបភាពនៃការធ្វើប្រតិបត្តិការ និងការបង្កើតបរធនបាលកិច្ច មានលក្ខណៈខុសគ្នាដូចបានរៀបរាប់ខាងលើ។

បរធនបាលកិច្ចបុគ្គល (Individual/Personal Trust) ត្រូវបានបង្កើតឡើងដោយបរធនបាលទាយកដើម្បីផ្ទេរទ្រព្យសម្បត្តិឬមូលនិធិទៅឱ្យបរធនបាលធ្វើការចាត់ចែងគ្រប់គ្រងនិងថែរក្សាជំនួសសម្រាប់ផល-ប្រយោជន៍របស់បរធនបាលទាយកខ្លួនឯងឬសម្រាប់បុគ្គលដែលបានកំណត់ជាក់លាក់ដោយបរធនបាល

[17] ឱកាសសម្រាប់វិនិយោគិន លើវិស័យអចលនទ្រព្យនៅកម្ពុជា តាមរយៈបរធនបាលកិច្ច (freshnewsasia.com) (បានចូលទស្សនានៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣)

[18] https://www.trustregulator.gov.kh/InvestorFAQs.html (បានចូលទស្សនានៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣)

ទាយកតាមលក្ខខណ្ឌដូចខាងក្រោម៖

១.ការធ្វើប្រទានកម្មទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនឱ្យទៅបរធនបាល

២. បរធនបាលទាយកត្រូវធ្វើលិខិតបរធនបាលកិច្ច ករណីបរធនបាលទាយកនៅមានជីវិត ឬ ការធ្វើមតកសាសន៍ ដែលបង្កើតជាបរធនបាលកិច្ច ករណីបរធនបាលទាយកនោះទទួលមរណភាព។ បរធនបាលកិច្ចពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ឬគោលបំណងផ្សេងទៀត សម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬបុគ្គលណាមួយជាក់លាក់ ដែលកំណត់ដោយអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនោះ។

លក្ខណៈនៃបរធនបាលកិច្ចពាណិជ្ជកម្មមាន៣ធំៗដូចខាងក្រោម៖

1. មូលនិធិសោធននិវត្តន៍ មូលនិធិអប់រំ និងមូលនិធិប្រហាក់ប្រហែល ដែលត្រូវបានផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិទាំងនោះទៅឱ្យបរធនបាលគ្រប់គ្រង និងចាត់ចែង ឬវិនិយោគ ដើម្បីជាប្រយោជន៍ដល់ម្ចាស់មូលនិធិ អ្នកផ្តល់វិភាគទានឬបុគ្គលផ្សេងទៀត។

2. សេវារក្សាទុកដែលទ្រព្យសម្បត្តិឬមូលនិធិ ត្រូវបានផ្ទេរដោយបុគ្គលណាមួយ ឱ្យទៅបរធនបាល ហើយបរធនបាលនោះ ត្រូវផ្ទេរទ្រព្យសម្បត្តិឬមូលនិធិនោះ ត្រឡប់ទៅបុគ្គលនោះវិញ ឬបុគ្គលណាមួយផ្សេងទៀត នៅពេលបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- រក្សាទុកដោយបុគ្គលណាមួយ ជាអាទិ៍មន្ទីរសារការី ឬការិយាល័យមេធាវី ឬក្រុមហ៊ុនគណនេយ្យ ឬ
- សេវារក្សាទុកផ្សេងទៀតដែលមានការអនុញ្ញាតពីបញ្ញត្តិករពាក់ព័ន្ធដូចជា ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជាឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានការកាន់កាប់ទ្រព្យសម្បត្តិ ឬមូលនិធិតម្កល់ ដើម្បីជាប្រយោជន៍របស់វិនិយោគិន អ្នកទិញអចលនវត្ថុ និងដើម្បីប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀត។

3. គម្រោងភាគហ៊ុននិយោជិត ឬផលប្រយោជន៍និយោជិត នៅពេលដែលបរធនបាល គ្រប់គ្រងទ្រព្យសម្បត្តិ ឬមូលនិធិដើម្បីវិនិ-យោគក្នុងនាមនិយោជិត។ ពាក់ព័ន្ធនឹងសំណួរនេះ សុទ្ធតែជាបរធនបាលកិច្ចពាណិជ្ជកម្មដែលទាក់ទិនទៅនឹងអចលនវត្ថុ។

### ៣.៤.១ អត្ថប្រយោជន៍នៃបរធនបាលទាយក

យោងតាមច្បាប់ ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាលកិច្ច ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីភាគីសំខាន់ចំនួន៣គឺ បរធនបាលទាយក, បរធនបាល, និងអត្ថគាហកៈ ព្រមទាំងអាចមានភាគីចូលរួមផ្សេងទៀត។តាមការបង្កើតបរធនបាលកិច្ច បរធនបាលទាយក និងអត្ថគាហកៈនៃបរធនបាលកិច្ច នឹងទទួលបានផលប្រយោជន៍ រួមមាន៖

១-សិទ្ធិរបស់បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ក្នុងការរៀបចំ ចាត់ចែង និងផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួន តាមសណ្តាប់ធ្នាប់ ជាសារធារណៈទៅឱ្យអត្ថគាហកៈ តាមគោលបំណងដែលខ្លួន ចង់បានដោយមានការគ្រប់គ្រង និងចាត់ចែងត្រឹមត្រូវដោយបរធនបាល ដែលទទួលបានអាជ្ញាបណ្ណទទួលស្គាល់ ពីនិយ័តករបរធនបាលកិច្ច (ន. ប. ធ) ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ។

២-ការការពារបរធន ឬទ្រព្យសម្បត្តិ ដែលបានផ្ទេរចូលក្នុងបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន ប្រកបដោយសណ្តាប់ធ្នាប់ របៀបរៀបរយជាសាធារណៈ ដោយមានអាជ្ញាធរមានសមត្ថកិច្ចច្បាស់លាស់ ក្នុងការការពារសិទ្ធិ និងអត្ថប្រយោជន៍ជាអតិបរមាដល់ម្ចាស់ទ្រព្យ ឬបរធនបាលទាយក និងអ្នកទទួលផល ឬអត្ថគាហកៈ។

### ៣.៤.២ អត្ថប្រយោជន៍នៃអត្ថគាហកៈ

អត្ថគាហកៈ មានសិទ្ធិទទួលផលប្រយោជន៍ពេញលេញ ពីបរធនបាលកិច្ច ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន និងទៅតាមគោលបំណងរបស់បរធនបាលទាយក។ សិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាលទាយក, បរធនបាល និងអត្ថគាហកៈ មានចែកលម្អិតនៅក្នុងច្បាប់ ស្តីពីបរធនបាលកិច្ច (២០១៩)៕[19]

## ៣.៥. ទំហំកើនឡើងនៃបរធនបាលកិច្ចនៅកម្ពុជា ដែលបានចុះបញ្ជីក្នុងរយៈពេលបីឆ្នាំចុងក្រោយ

| ទំហំកើនឡើងនៃបរធនបាលកិច្ចនៅកម្ពុជា ដែលបានចុះបញ្ជីក្នុងរយៈពេល3ឆ្នាំចុងក្រោយ | | | | |
|---|---|---|---|---|
| ឆ្នាំ | ចំនួនក្រុមហ៊ុនចុះបញ្ជី | សរុបចំនួនក្រុមហ៊ុនចុះបញ្ជី | ទំហំបរធនបាល | សរុបទំហំបរធនបាល |
| មុនឆ្នាំ២០២១ | ១៧ | ១៧ | ១៥៦ លានដុល្លារ | ១៥៦ លានដុល្លារ |
| ឆ្នាំ២០២២ | ២៨៣ | ៣០០ | ២៧០ លានដុល្លារ | ៤២៦ លានដុល្លារ |
| ឆ្នាំ២០២៣ | ៣២០ | ៦២០ | ៧៤៦ លានដុល្លារ | ១១៧២ លានដុល្លារ |

ទំហំកើនឡើងនៃបរធនបាលកិច្ចនៅកម្ពុជាដែលបានចុះបញ្ជីក្នុងរយៈពេល ៣ឆ្នាំចុងក្រោយគិតមកដល់ពេលបច្ចុប្បន្ននេះទំហំបរធនបាលកិច្ចដែលបានចុះបញ្ជីកើនឡើងដល់ប្រមាណ ១១៧២ លានដុល្លារ បើគិតជាភាគរយជាង ៣៥០០ % ដែលបង្ហាញពីការរីកចម្រើនយ៉ាងរហ័សនៃវិស័យបរធនបាលនៅកម្ពុជា។ កាលពីមុនឆ្នាំ ២០២១ ចំនួនបរធនបាលដែលបានចុះបញ្ជីស្របច្បាប់មានត្រឹមតែ ១៧ ករណីក្នុងទំហំបរធនបាល១៥៦ លានដុល្លារអាមេរិកតែប៉ុណ្ណោះ ដែលភាគច្រើនបំផុតគឺតំណាងដោយបរធនបាលកិច្ចហិរញ្ញវត្ថុដែលពាក់ព័ន្ធនិងហិរញ្ញប្បទានឥតសំណង ឬបំណុលដែលដៃគូអភិវឌ្ឍន៍ប្រគល់ជូនរាជរដ្ឋាភិបាលឲ្យចាត់ចែងនិងគ្រប់គ្រងដោយក្រុមការងារប្រតិ-បត្តិការនៅក្នុងគ្រឹះស្ថាននិងធនាគារហិរញ្ញវត្ថុប៉ុន្តែនាពេលបច្ចុប្បន្នឆ្នាំ២០២៣ នេះបរធនបាលកិច្ចបានចុះបញ្ជីរហូតដល់ ៦២០ ករណីកើនឡើងជាង ៣៥០០% ក្នុងទំហំបរធនបាលកើនឡើងដល់ប្រមាណ ១១៧២លានដុល្លារអាមេរិក ដែលកំណើនមួយឆាប់បំផុតក្នុងរយៈពេលខ្លី។[20]

[19] បរធនបាលកិច្ច អត្ថបទប្រចាំសប្តាហ៍ បានចេញនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១

[20] https://m.freshnewsasia.com/index.php/en/business/300318-2023-07-19-10-07-25.html (បានចូលទស្សនានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣

# សេចក្ដីសន្និដ្ឋាន

# និង

# ការផ្ដល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ផ្អែកលើការសិក្សាស្រាវជ្រាវទាំងទៅលើទ្រឹស្តី នឹងក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "**ប្រតិបត្តិការបរធនបាលកិច្ចនៅប្រទេសកម្ពុជា** រួចមក ធ្វើឱ្យក្រុមយើងខ្ញុំបានសិក្សាឈ្វេងយល់កាន់តែបានច្បាស់ និងទទួលបាននូវចំណេះដឹងទាក់ទងជាមួយនឹងបរធនបាលកិច្ចនៅកម្ពុជា ដែលយើងខ្ញុំមិនធ្លាប់បានដឹងពីមុនមក បានកាន់តែច្រើនផងដែរ។ បើយើងនិយាយពី **ន.ប.ធ** គឺជាអាជ្ញាធរគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។ រួមជាមួយការប្រមូល និងវិភាគទិន្នន័យដែលទទួលបានតាមរយៈកម្រងសំណួរ, យើងខ្ញុំអាចទាញរកសេចក្តីសន្និដ្ឋានជារួមបានថា វិស័យបរធនបាលកិច្ច គឺជាវិស័យហិរញ្ញវត្ថុមិនមែនធនាគារមួយ ដែលមានការផ្តោតយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការគ្រប់គ្រងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលដែលជាបុគ្គលទទួលរក្សាទ្រព្យជំនួសឱ្យបុគ្គលដទៃ ដែលអាចត្រូវបានគេហៅថាជា "បរធនបាល" ហើយបុគ្គលប្រភេទនេះ ត្រូវបានចុះបញ្ជី ទទួលអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត និង/ឬការទទួលស្គាល់ពី និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ជាមុន ដើម្បីអាចធ្វើប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន។ ជាការពិតណាស់ ពីមួយថ្ងៃទៅមួយថ្ងៃ វិស័យបរធនបាលកិច្ចកាន់តែមានភាពទូលំទូលាយ និងប្រកបដោយនវានុវត្តន៍ដែលកាន់តែសម្បូរបែបនូវផលិតផល និងសេវាកម្មបរធនបាលកិច្ចជាច្រើននៅក្នុងទីផ្សារបរធនបាលកិច្ច។ ជាមួយគ្នានេះ ក្នុងស្ថានភាពជាក់ស្តែង **ន.ប.ធ.** តែងតែបានអនុញ្ញាដល់អ្នកសិក្សាស្រាវជ្រាវ សិស្ស-និស្សិត ក៏ដូចជាសាធារណជនទូទៅ ដែលមានបំណងចង់ឈ្វេងយល់ និងសិក្សាស្រាវជ្រាវពីវិស័យបរធនបាលកិច្ច អាចស្នើសុំមក **ន.ប.ធ.** ក្នុងគោលបំណងចុះកម្មសិក្សា ក៏ដូចជាបានផ្តល់ឱកាសដល់ពួកគេអាចបម្រើការងារជាមន្ត្រីនៅ **ន.ប.ធ.** ដោយការពិនិត្យលើគុណវុឌ្ឍិរបស់ពួកគេ សម្រាប់បន្តរួមចំណែកអភិវឌ្ឍអង្គភាពនាពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត។

សរុបសេចក្តីមក ជាលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា ទោះបីជាវិស័យបរធនបាលកិច្ច ជាវិស័យថ្មីមួយដែលទើបនឹងកកើតមិនយូរប៉ុន្មាន ក៏ប៉ុន្តែវិស័យនេះបានវិវត្តខ្លួនយ៉ាងឆាប់រហ័ស និង ដើរតួជា កាតាលីករដ៏មានសក្តានុពលក្នុងការកៀរគរមូលធនពីសាធារណជនទាំងក្នុង និងក្រៅប្រទេស។ លើសពីនេះទៅទៀត ក្រុមហ៊ុនបរធនបាលកិច្ច ពិតជាបានចូលរួមជាផ្នែកមួយ យ៉ាងសំខាន់ ក្នុងការជម្រុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យមានភាពរីកចម្រើនលូតលាស់ ទៅមុខយ៉ាងឆាប់រហ័ស។

## ២. ការផ្តល់អនុសាសន៍

បើទោះបីជាវិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជាមានការរីកចម្រើនក៏ដោយ ក៏ប្រជាជនកម្ពុជា នៅមិនទាន់មានចំណេះដឹងទូលំទូលាយអំពីដំណើរការនៃទីផ្សារបរធនបាលកិច្ចនៅកម្ពុជានៅឡើយទេ។ ដើម្បីជាជំនួយដល់ប្រសិទ្ធិភាពនៃទីផ្សារបរធនបាលកិច្ច យើងចាំបាច់ត្រូវមានការចូលរួម និងសហការពីសំណាក់ស្ថាប័នឯកជន ស្ថាប័នសាធារណៈ និងស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការផ្សព្វផ្សាយឱ្យទូលំទូលាយបានច្រើនជាងនេះទៅទៀត។ ដូច្នេះក្នុងនាមយើងខ្ញុំជាអ្នកសិក្សាជំនាន់ថ្មី សូមចូលរួមចំណែកផ្តល់ជាអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

- ដើម្បីជំរុញនូវការរីកចម្រើន ក៏ដូចជាការកើនឡើងនូវចំនួនក្រុមហ៊ុនចុះបញ្ជី និងការវិនិយោគនៅលើទីផ្សារបរធនបាលកិច្ច **ន.ប.ធ.** គួរតែបង្កើនការលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនចុះបញ្ជីដំបូង។
- **ន.ប.ធ.** គួរតែផ្សព្វផ្សាយចំណេះដឹងបន្ថែមដល់សាធារណជន ហើយបង្កើនចំនួនសិក្ខាសិលាជាសាធារណៈ និងការតាំងពិព័រណ៍ស្តីពីវិស័យបរធនបាលកិច្ច ដោយមានការចូលរួមពីអ្នកជំនាញពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចនៅកម្ពុជា។
- **ន.ប.ធ.** គួររៀបរៀងសៀវភៅណែនាំខ្លីៗអំពីវិស័យបរធនបាលកិច្ច ដោយធ្វើការសម្រាយពីច្បាប់ បញ្ញត្តអនុក្រឹត្យ និងគោលការណ៍ណែនាំផ្សេងៗ ដើម្បីផ្សព្វផ្សាយដល់សាធារណជន។
- **ន.ប.ធ.** គួរតែរៀបចំនូវវគ្គបណ្តុះបណ្តាលខ្លីៗទាក់ទងនឹងវិស័យបរធនបាលកិច្ចជូនដល់សិស្ស/និស្សិត ដើម្បីឲ្យពួកគាត់បានយល់ពីវិស័យបរធនបាលកិច្ចឲ្យបានកាន់តែទូលំទូលាយទាំងដំណើរការប្រតិបត្តិការ និងសារៈសំខាន់នៃបរធនបាលកិច្ច។
- **ន.ប.ធ.** គួរតែបង្កើននូវការផ្សព្វផ្សាយព័ត៌មានបន្ថែមទៅតាមវិទ្យាស្ថានអប់រំមួយចំនួន ជាពិសេសសាកលវិទ្យាល័យ ដើម្បីឲ្យសិស្ស/និស្សិតបានជ្រួតជ្រាបជាព័ត៌មាន ក៏ដូចជាចំណេះដឹងបន្ថែមទាក់ទាងនឹងវិស័យបរធនបាលកិច្ចនៅកម្ពុជា។

សរុបសេចក្តីមក វិស័យបរធនបាលកិច្ចអាចរីកចម្រើនបានក៏ដោយសារការចូលរួមយ៉ាង សកម្មពីរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនបរធនបាល និង វិនិយោគិនសាធារណៈទាំងអស់ក្នុង ការលើកទឹកចិត្ត អនុវត្ត និងផ្សព្វផ្សាយពីវិស័យនេះអោយកាន់តែមានភាពរីកលូតលាស់បន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ

- អនុក្រឹត្យស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច" នៃនិយ័តករ-បរធនបាលកិច្ច
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច។
- ប្រកាសស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្រកាសស្តីពីការកែសម្រួលប្រការ១២ នៃប្រការលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច
- ប្រកាសស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីនៃនិយ័តករបរធនបាលកិច្ចនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់និយ័តករបរធនបា-លកិច្ច
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់អគ្គ លេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច
- ប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច
- ប្រកាសស្តីពី "បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច"
- ប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"
- ប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនសវនកម្មក្នុងវិស័យបរធនបាលកិច្ច"។
- សេចក្តីណែនាំស្តីពីបែបបទនៃការអនុវត្តការងាររបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែន ធនាគារ

- សេចក្ដីសម្រេចលេខ ០៧ សសរ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ស្ដីពីការតែងតាំងសមាសភាពគណៈ- កម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- សេចក្ដីសម្រេចលេខ ០៦៤ សហវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការបង្កើតក្រុមការងាររៀបចំសេចក្ដី ព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា
- គោលការណ៍ណែនាំស្ដីពីការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការស៊ើបអង្កេត និងកិច្ចសហការជាតិក្នុងការស៊ើបអង្កេត
- គោលការណ៍ណែនាំរួមស្ដីពី "ការចុះបញ្ជី និងការស្នើសុំការអនុញ្ញាតបន្ថែមរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិ ជំនួសនៃគម្រោងវិនិយោគរួម និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ"
- សេចក្ដីណែនាំស្ដីពី "ការរាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដោយបុគ្គលរាយការណ៍សម្រាប់វិស័យបរធនបាលកិច្ច"
- គោលការណ៍ណែនាំស្ដីពី "បែបបទនិងយន្តការពិគ្រោះយោបល់ពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។

## អត្ថបទផ្សេងៗ

- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី១២ ខែមេសា ២០២៣
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី១០ ខែឧសភា ២០២៣
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០២២
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០២២
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី០២ ខែសីហា ២០២១
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី១១ ខែតុលា ២០២១
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញផ្សាយនៅថ្ងៃទី២៥ ខែតុលា ២០២១
- បរធនបាលកិច្ច អត្ថបទប្រចាំសប្ដាហ៍ បានចេញនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១

## គេហទំព័រ

- https://www.trustregulator.gov.kh/TrustyCompany.html (បានចូលទស្សនានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣

- https://www.trustregulator.gov.kh/TrustyIndependant.html (បានចូលទស្សនានៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០២៣)
- https://www.trustregulator.gov.kh/OperatorDeposit.html (បានចូលទស្សនានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣)
- https://www.trustregulator.gov.kh/OperatorEvaluate.html(បានចូលទស្សនានៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣)
- ឱកាសសម្រាប់វិនិយោគិន លើវិស័យអចលនទ្រព្យនៅកម្ពុជា តាមរយៈបរធនបាលកិច្ច (freshnewsasia.com) (បានចូលទស្សនានៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣)
- https://www.trustregulator.gov.kh/InvestorFAQs.html (បានចូលទស្សនានៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣)

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ ៖ ច្បាប់ស្តីពីបរធនបាលកិច្ច

ឧបសម្ព័ន្ធទី ២ ៖ អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច

ឧបសម្ព័ន្ធទី ៣ ៖ អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី ៤ ៖ ប្រកាសស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី ៥ ៖ ប្រកាសស្តីពីការកែសម្រួលប្រការ១២ នៃប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី ៦ ៖ ប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច

# ឧបសម្ព័ន្ធទី១

# ច្បាប់ស្តីពីបរធនបាលកិច្ច

# ច្បាប់

# ស្ដីពី

# បរធនបាលកិច្ច

# ជំពូកទី១

# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងបរធនដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .–**

ច្បាប់នេះមានគោលដៅកំណត់អំពី វិធាន នីតិវិធីនៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ច។

**មាត្រា៣ .–**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .–**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី២

# បរធនបាលកិច្ច

## ផ្នែកទី១

## ភាគី ការបង្កើត និងអានុភាពនៃបរធនបាលកិច្ច

**មាត្រា៥ .–**

ភាគីនៃបរធនបាលកិច្ច ជាសំខាន់មាន៣ (បី) គឺ បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ។

បរធនបាលកិច្ចអាចមានភាគីចូលរួមផ្សេងទៀតដូចជា អ្នកផ្ដល់វិភាគទានបរធនបាលកិច្ច និងបរធនបាលទាយកជំនួស។

**មាត្រា៦ .–**

បរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបរធនបាលទាយកឬបទប្បញ្ញត្តិជាធរមាននិងត្រូវមានកម្មវត្ថុស្របច្បាប់និងមិនផ្ទុយទៅនឹងសណ្ដាប់ធ្នាប់សាធារណៈ។

**មាត្រា៧ .–**

ដំណើរការនៃការបង្កើតបរធនបាលកិច្ចមានដូចខាងក្រោម៖

- ករណីដែលបរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបរធនបាលទាយក  បរធនបាលទាយកត្រូវផ្ទេរទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនឱ្យទៅបរធនបាល  តាមរយៈលិខិតបរធនបាលកិច្ចដោយមានបញ្ជាក់ពីគោលបំណងជាក់លាក់របស់បរធនបាលកិច្ចនិង/ឬបញ្ជាក់ពីអត្តសញ្ញាណអត្ថគាហកៈ។
- ករណីដែលបរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបទប្បញ្ញត្តិជាធរមាន  បរធនត្រូវបានផ្ទេរដោយស្វ័យប្រវត្តិឱ្យទៅបរធនបាល ដើម្បីគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ ស្របតាមបទប្បញ្ញត្តិជាធរមាន ដោយមានបញ្ជាក់ពីគោលបំណងជាក់លាក់របស់បរធនបាលកិច្ចនិង/ឬបញ្ជាក់ពីអត្តសញ្ញាណអត្ថគាហកៈ។

**មាត្រា៨ .-**

បរធនបាលកិច្ចមានអានុភាពអនុវត្ត នៅពេលដែលបរធនបាលយល់ព្រមទទួលយកជាលាយលក្ខណ៍អក្សរចំពោះការតែងតាំង។

## ផ្នែកទី២
## គោលបំណងនៃបរធនបាលកិច្ច

**មាត្រា៩ .-**

បរធនបាលកិច្ចត្រូវបានបែងចែកជា៤ (បួន)ប្រភេទ ដូចខាងក្រោម៖

-បរធនបាលកិច្ចពាណិជ្ជកម្ម

-បរធនបាលកិច្ចសាធារណៈ

-បរធនបាលកិច្ចសង្គម

-បរធនបាលកិច្ចបុគ្គល។

**មាត្រា១០ .-**

បរធនបាលកិច្ចពាណិជ្ជកម្មត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ សម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានបរធនបាលកិច្ចឬបុគ្គលណាមួយជាក់លាក់ដែលកំណត់ដោយអ្នកផ្តល់វិភាគទានបរធនបាលកិច្ច រួមមាន៖

១-មូលនិធិសោធននិវត្តន៍  មូលនិធិអប់រំ  និងមូលនិធិប្រហាក់ប្រហែលផ្សេងទៀតដែលបុគ្គលណាមួយផ្ទេរទ្រព្យសម្បត្តិឱ្យបរធនបាល  ហើយត្រូវបានផ្ទេរត្រឡប់ទៅបុគ្គលនោះវិញឬផ្ទេរឱ្យបុគ្គលណាមួយផ្សេងទៀតនៅពេលដែលបានបំពេញតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

ក-មានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិទៅក្នុងបរធនបាលកិច្ចដោយបុគ្គលណាម្នាក់ឱ្យទៅបរធនបាលជាប្រចាំ ហើយបរធនបាលគ្រប់គ្រងនិងចាត់ចែងមូលនិធិនេះសម្រាប់ជាប្រយោជន៍ជាក់លាក់របស់បុគ្គលនេះឬបុគ្គលផ្សេងទៀត ហើយ

ខ-នៅពេលដែលទ្រព្យសម្បត្តិឬមូលនិធិរបស់អ្នកផ្តល់វិភាគទានផ្សេងទៀតត្រូវបានដាក់បញ្ចូលក្នុងគម្រោងវិនិយោគ ហើយត្រូវបានវិនិយោគដោយបរធនបាលសម្រាប់ជាប្រយោជន៍របស់អ្នកផ្តល់វិភាគទានទាំងអស់តាមលក្ខខណ្ឌដែលបានកំណត់ និង

គ-នៅពេលដែលទ្រព្យសម្បត្តិនិងផលដែលបានមកពីការវិនិយោគត្រូវបានកំណត់ គ្រប់គ្រង និងរាយការណ៍ដាច់ដោយឡែកទៅបុគ្គលនោះ។

២-សេវារក្សាទុកដែលក្នុងនោះមានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ ឱ្យទៅបរធនបាល ហើយបរធនបាលត្រូវផ្ទេរត្រឡប់ឱ្យទៅបុគ្គលនេះវិញឬឱ្យទៅបុគ្គលណាមួយផ្សេងទៀត នៅពេលដែលបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

ក-មានការរក្សាទុកទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ ជាអាទិ៍ មន្ទីរសារការី ឬការិយាល័យមេធាវី ឬក្រុមហ៊ុនគណនេយ្យ ឬ

ខ-មានការកាន់កាប់ទ្រព្យសម្បត្តិឬមូលនិធិតម្កល់ដើម្បីជាប្រយោជន៍របស់វិនិយោគិន អ្នកទិញអចលនវត្ថុ និងដើម្បីប្រតិបត្តិការពាណិជ្ជកម្មផ្សេងៗទៀត ឬ

គ-សេវារក្សាទុកផ្សេងទៀតដែលទទួលបានការអនុញ្ញាតតាមសេចក្តីសម្រេចរបស់បញ្ញត្តិករផ្សេងទៀត ជាអាទិ៍ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងសកម្មភាពនានាដែលស្ថិតក្រោមតួនាទីនិងភារកិច្ចរបស់ខ្លួន។

៣-គម្រោងភាគហ៊ុននិយោជិតឬផលប្រយោជន៍និយោជិត នៅពេលដែលបរធនបាល គ្រប់គ្រងទ្រព្យសម្បត្តិឬមូលនិធិដើម្បីវិនិយោគក្នុងនាមនិយោជិតនោះ និង

៤-ដើម្បីគោលបំណងផ្សេងទៀត៖

ក-នៅពេលដែលមានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានឬបុគ្គលផ្សេងទៀតដែលកំណត់ដោយអ្នកផ្តល់វិភាគទាន និង

ខ-នៅពេលដែលបទប្បញ្ញត្តិជាធរមាន ចែងអំពីវិធានស្តីពីដំណើរការនិងការគ្រប់គ្រងសកម្មភាពនៃបរធនបាលកិច្ច។

មាត្រា ១១

បរធនបាលកិច្ចសាធារណៈត្រូវបានបង្កើតឡើងក្នុងគោលបំណងជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទូទៅ។

បរធនបាលកិច្ចនេះរួមមាន៖

១-ការអភិវឌ្ឍវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅពេលដែល៖

ក-ដៃគូអភិវឌ្ឍផ្តល់ទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនសម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ហើយទ្រព្យសម្បត្តិឬមូលនិធិទាំងនោះបាននិងកំពុងគ្រប់គ្រងនិងចាត់ចែងនៅក្នុងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀត និង

ខ-តាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

២-ជាប្រយោជន៍សាធារណៈផ្សេងទៀតនៅពេលដែលបញ្ញត្តិករពាក់ព័ន្ធតែងតាំងបរធនបាល ដើម្បីគ្រប់គ្រងនិងការពារមូលនិធិនានាតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។ លក្ខខណ្ឌទាំងនេះមានជាអាទិ៍៖

ក-មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាលឬត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញគោលបំណងជាក់លាក់ណាមួយរបស់អ្នកផ្តល់ជំនួយ ហើយអ្នកផ្តល់ជំនួយទាមទារឱ្យមូលនិធិនេះត្រូវបានចាត់ចែងប្រើប្រាស់និងអាស្រ័យផលស្របតាមគោលបំណងរបស់ខ្លួន ឬ

ខ-ត្រូវការពារផលប្រយោជន៍របស់កុមារឬអសមត្ថជនផ្សេងទៀត ឬ

គ-មតិកដែលធ្លាក់ទៅជាទ្រព្យរដ្ឋតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១២ .-**

បរធនបាលកិច្ចសង្គមត្រូវបានបង្កើតឡើងនៅពេលដែលបរធនបាលទាយកធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបរធនបាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គម ដូចជាក្នុងគោលបំណងវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

១-មូលនិធិពិសេស៖

ក-មូលនិធិដែលបង្កើតដោយបរធនបាលទាយកតាមរយៈប្រទានកម្មឬមតកសាសន៍

ខ-តាមរយៈការទទួលទ្រព្យសម្បត្តិពីអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនៅមានជីវិតឬទទួលទ្រព្យសម្បត្តិតាមមតកសាសន៍របស់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច និង

គ-ទ្រព្យសម្បត្តិត្រូវបានផ្ទេរឱ្យទៅបរធនបាល ដើម្បីបំពេញគោលបំណងជាប្រយោជន៍សង្គម និង

ឃ-មិនស្វែងរកប្រាក់ចំណេញឬគ្មានប្រតិបត្តិការជាសហគ្រាសពាណិជ្ជកម្ម និង

ង-លើកលែងតែមានចែងផ្សេងក្នុងលិខិតបរធនបាលកិច្ច ទ្រព្យសម្បត្តិដំបូងនិងទ្រព្យសម្បត្តិបន្ថែមផ្សេងទៀត ដែលអ្នកផ្តល់វិភាគទានបរធនបាលកិច្ចបានផ្ទេរចូលមូលនិធិណាមួយ ត្រូវរក្សាទុកដើម្បីបំពេញគោលបំណងបរធនបាលកិច្ច ហើយអនុញ្ញាតឱ្យចែកចាយតែផលដែលបានពីទ្រព្យសម្បត្តិនោះប៉ុណ្ណោះ។

២-មូលនិធិសម្រាប់ជាប្រយោជន៍ដល់អង្គការវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ : ទ្រព្យសម្បត្តិទទួលពីបុគ្គល រួមមានប្រទានកម្ម ឬមតកសាសន៍ ហើយទ្រព្យសម្បត្តិនេះត្រូវបានផ្ទេរដើម្បីបម្រើ

គោលដៅសម្រាប់ជាប្រយោជន៍ ជាអាទិ៍ វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

**មាត្រា១៣ .-**

បរធនបាលកិច្ចបុគ្គលត្រូវបានបង្កើតឡើងសម្រាប់ជាប្រយោជន៍របស់បរធនបាលទាយកឬបុគ្គលដែលកំណត់ជាក់លាក់ដោយបរធនបាលទាយកតាមលក្ខខណ្ឌដូចខាងក្រោម៖

១-បរធនបាលទាយកជារូបវន្តបុគ្គលដែលធ្វើប្រទានកម្មទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួន ឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍របស់ខ្លួនផ្ទាល់ឬរបស់បុគ្គលផ្សេងទៀត ឬ

២-ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិ ដោយបរធនបាលទាយក៖

ក-ករណីបរធនបាលទាយកនៅមានជីវិត បរធនបាលទាយកនោះត្រូវធ្វើលិខិតបរធនបាលកិច្ចដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬឃុំសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

ខ-ករណីបរធនបាលទាយកធ្វើមតកសាសន៍ នៅពេលដែលបរធនបាលទាយកនោះទទួលមរណភាពតាមរយៈមតកសាសន៍នេះ បង្កើតជាបរធនបាលកិច្ចដែលស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

**មាត្រា១៤ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃបរធនបាលកិច្ចដែលបានចែងក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ និងមាត្រា១៣ ត្រូវកំណត់ដោយបញ្ញត្តិករពាក់ព័ន្ធ។

## ផ្នែកទី៣
## ការកែប្រែគោលបំណងនិងរយៈពេលនៃបរធនបាលកិច្ច

**មាត្រា១៥ .-**

បរធនបាលអាចស្នើសុំកែប្រែគោលបំណងបរធនបាលកិច្ចទៅបញ្ញត្តិករពាក់ព័ន្ធ និងជូនដំណឹងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់៖

- មូលហេតុដែលបរធនបាលកិច្ចមិនបានអនុវត្តតាមគោលបំណងដើម
- ការយល់ព្រមពីបរធនបាលទាយក
- ការយល់ព្រមជាឯកច្ឆន្ទពីបរធនបាល
- ការយល់ព្រមពីបុគ្គលដែលទទួលខុសត្រូវ និង
- លក្ខខណ្ឌនៃលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៦ .-**

រយៈពេលនៃបរធនបាលកិច្ចនីមួយៗត្រូវកំណត់ក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ចំពោះបរធនបាលកិច្ច ក្នុងគោលបំណងជាប្រយោជន៍បុគ្គល រយៈពេលកំណត់មិនត្រូវឱ្យលើសពី ១០០(មួយរយ)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ច។

ក្នុងករណីទ្រព្យសម្បត្តិបរធនបាលកិច្ចដែលត្រូវបែងចែកបន្ទាប់ពីបរធនបាលកិច្ចត្រូវបានបញ្ចប់ ប៉ុន្តែអត្ថគាហកៈមិនទាន់ទទួលការអនុញ្ញាតឬសិទ្ធិក្នុងការកាន់កាប់នៃទ្រព្យសម្បត្តិដែលជាដីធ្លី នោះទ្រព្យសម្បត្តិបរធនបាលកិច្ចត្រូវក្លាយជាសិទ្ធិជួល រហូតដល់អត្ថគាហកៈមានសិទ្ធិពេញលេញក្នុងការកាន់កាប់ដីធ្លីស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣

## បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ

### ផ្នែកទី១

### បរធនបាលទាយក

**មាត្រា១៧ .-**

បរធនបាលទាយកមានសិទ្ធិជាអាទិ៍ ដូចខាងក្រោម៖

- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចដែលមានជាអាទិ៍ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត
- តែងតាំងនិងបញ្ឈប់បរធនបាល តាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា១៨ .-**

បរធនបាលទាយកមានកាតព្វកិច្ចជាអាទិ៍ ដូចខាងក្រោម៖

- ផ្ទេរទ្រព្យសម្បត្តិឬមូលនិធិជាបរធនឱ្យទៅបរធនបាល គ្រប់គ្រង និងចាត់ចែងជំនួស សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ
- ចូលរួមឬសម្រួលក្នុងកិច្ចការផ្ទេរបរធនឱ្យទៅបរធនបាល គ្រប់គ្រង និងចាត់ចែង
- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការផ្លាស់ប្តូរបរធនបាលទាយកឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬការកែប្រែលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច
- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៩ .-**

ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាពឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន [illegible]ការដែលពាក់ព័ន្ធមានសមត្ថកិច្ចបំពេញមុខងារមួយចំនួន ជាបរធនបាលទាយកជំនួស។

# ផ្នែកទី២

## បរធនបាល

**មាត្រា២០ .-**

បុគ្គលដែលអាចតែងតាំងជាបរធនបាលមានដូចជា៖

១- រូបវន្តបុគ្គលឬក្រុមរូបវន្តបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់តាមក្រមរដ្ឋប្បវេណី ឬ

២- នីតិបុគ្គលឬក្រុមនីតិបុគ្គលស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

៣- ក្រុមចម្រុះនៃរូបវន្តបុគ្គលនិងនីតិបុគ្គល។

បុគ្គលខាងលើអាចត្រូវបានតែងតាំងជាបរធនបាលបាន លុះត្រាតែមិនត្រូវបានហាមឃាត់ដើម្បីធ្វើជាបរធនបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ចំពោះបរធនបាលកិច្ចដែលបរធនបាលទាយកជារូបវន្តបុគ្គល បរធនបាលទាយកនិង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនិងអត្ថគាហកៈអាចក្លាយជាបរធនបាល។ ប៉ុន្តែដើម្បីជៀសវាងទំនាស់ផលប្រយោជន៍បរធនបាលទាយកនិង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងអត្ថគាហកៈ មិនអាចក្លាយជាបរធនបាលក្នុងពេលតែមួយបានឡើយ ហើយត្រូវតែងតាំងបរធនបាលមួយផ្សេងទៀត។

**មាត្រា២១ .-**

បរធនបាលមានសិទ្ធិជាអាទិ៍ដូចខាងក្រោម៖

- ទទួលលាភការឬកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ច ដែលអាចប្រែប្រួលទៅតាមបទពិសោធការងារនិង/ឬគុណវុឌ្ឍិវិជ្ជាជីវៈរបស់ខ្លួន
- គ្រប់គ្រងនិងចាត់ចែងបរធនតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច
- ចំណាយក្នុងសកម្មភាពសង្គម ស្របតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច
- ស្វែងរកជំនួយឬមូលនិធិផ្សេងៗដើម្បីជាប្រយោជន៍របស់បរធនបាលកិច្ច
- តំណាងឱ្យបរធនបាលទាយកឬអត្ថគាហកៈនៅចំពោះមុខច្បាប់ ឬអាជ្ញាធរមានសមត្ថកិច្ច និង
- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា២២ .-**

បរធនបាលមានកាតព្វកិច្ចជាអាទិ៍ដូចខាងក្រោម៖

- ដាក់ពាក្យចុះបញ្ជីបរធនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមបែបបទ និងនីតិវិធីដូចមានចែងក្នុងមាត្រា២៨នៃច្បាប់នេះ
- បែងចែកឱ្យបានច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងទ្រព្យសម្បត្តិបរធនបាលកិច្ច
- គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយយកចិត្តទុកដាក់និងដោយប្រុងប្រយ័ត្ន

- រក្សាភាពស្មោះត្រង់និងសុចរិត ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច
- មិនអាចផ្ទេរមុខងាររបស់ខ្លួនឱ្យទៅបុគ្គលផ្សេងទៀតបានឡើយ
- គ្រប់គ្រងនិងចាត់ចែងលើទ្រព្យសម្បត្តិបរធនបាលកិច្ចឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធភាព ដើម្បីជាប្រយោជន៍របស់អត្ថគាហកៈ
- ចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិបរធនបាលកិច្ច
- រាយការណ៍និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចឱ្យបរធនបាលទាយក អត្ថគាហកៈ និងបញ្ញត្តិករពាក់ព័ន្ធ
- រក្សាកំណត់ហេតុនៃកិច្ចប្រជុំ រៀបចំគណនីប្រចាំឆ្នាំ និងឆ្លើយតបទៅនឹងបញ្ញត្តិករពាក់ព័ន្ធ
- ចាត់វិធានការសមស្របដើម្បីការពារទ្រព្យសម្បត្តិបរធនបាលកិច្ច និងអត្ថគាហកៈ
- បង់ពន្ធគ្រប់ប្រភេទដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិបរធនបាលកិច្ច
- ចុះកិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវក្នុងមុខងារជាបរធនបាល
- ផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិករពាក់ព័ន្ធនិងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍ និង
- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៣ .-**

បរធនបាលមានការទទួលខុសត្រូវចំពោះសកម្មភាពដូចខាងក្រោម៖

- ការធ្វើឱ្យបាត់បង់ឬថយចុះនៃបរធនដោយគ្មានមូលហេតុត្រឹមត្រូវ
- ការខកខានមិនបានបង្ករប្រាក់ចំណេញទុកក្នុងបរធន ក្នុងករណីដែលទ្រព្យសម្បត្តិបរធនបាលកិច្ចនោះអាចផ្តល់ប្រាក់ចំណេញបាន
- ការប្រើប្រាស់បរធនខុសពីគោលបំណងបរធនបាលកិច្ច
- កំហុសដែលបានប្រព្រឹត្តដោយចេតនាឬអចេតនា ក្នុងការបំពេញការងាររបស់ខ្លួន
- ការទទួលខុសត្រូវផ្សេងទៀត តាមលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៤ .-**

ក្នុងការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ប្រសិនបើបរធនបាលមិនអាចព្រមព្រៀងគ្នាដោយសំឡេងភាគច្រើន បរធនបាលត្រូវមាន៖

- កត់ត្រាភាពខ្វែងគំនិតគ្នាជាលាយលក្ខណ៍អក្សរ
- ជូនដំណឹងភ្លាមពីភាពខ្វែងគំនិតគ្នានេះជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬបញ្ញត្តិករពាក់ព័ន្ធ។

- បញ្ញត្តិករពាក់ព័ន្ធត្រូវដោះស្រាយវិវាទនេះ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៥ .-**

បរធនបាលអាចត្រូវបានជំនួសដោយបុគ្គលផ្សេងទៀតតាមលក្ខខណ្ឌនិងនីតិវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ករណីដែលគ្មានចែងអំពីលក្ខខណ្ឌនិងនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី១ បរធនបាលត្រូវបានជំនួសតាមលក្ខខណ្ឌដូចខាងក្រោម៖

១-បើបរធនបាលជារូបវន្តបុគ្គល បរធនបាលនេះត្រូវបានជំនួស៖

ក-ជាស្វ័យប្រវត្តិ នៅពេលដែលខ្លួនទទួលមរណភាព អសមត្ថភាពផ្លូវកាយឬផ្លូវចិត្ត ត្រូវបានប្រកាសដោយអាជ្ញាធរមានសមត្ថកិច្ចថាក្ស័យធន ប្រព្រឹត្តបទល្មើសមជ្ឈិមឬឧក្រិដ្ឋ ឬតាមលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយបទប្បញ្ញត្តិជាធរមានរបស់បញ្ញត្តិករពាក់ព័ន្ធ។

ខ-តាមសេចក្តីសម្រេចភាគច្រើនដាច់ខាតរបស់បរធនបាលទាំងអស់ នៅពេលដែលបរធនបាលចូលនិវត្តន៍ ឬបដិសេធមិនបំពេញការងារ ឬមិនសក្តិសមបំពេញការងារ។

២-បើបរធនបាលជានីតិបុគ្គលបរធនបាលនេះត្រូវបានជំនួសនៅពេលដែលបរធនបាលបញ្ឈប់សកម្មភាពរបស់ខ្លួន ហើយត្រូវបានជម្រះបញ្ជីឬត្រូវបានរំលាយ។

បញ្ញត្តិករពាក់ព័ន្ធជាអ្នកចេញសេចក្តីសម្រេចតែងតាំងបរធនបាលជំនួស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៣

## អត្ថគាហកៈ

**មាត្រា២៦ .-**

អត្ថគាហកៈអាចជាបុគ្គលដែលត្រូវបានបង្កើតស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជាឬអាចជាបរធនបាលទាយក។

អត្ថគាហកៈអាចទទួលផលពីបរធនបាលកិច្ចចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃបរធនបាលកិច្ចលើកលែងតែមានបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ករណីដែលមានអត្ថគាហកៈច្រើន អត្ថគាហកៈទាំងនេះអាចទទួលផលដូចគ្នាឬផ្សេងៗពីគ្នាតាមរបៀបឬវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច។

ករណីដែលគ្មានរបៀបឬវិធីទទួលផលដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវសន្មតថាអត្ថគាហកៈទាំងនេះទទួលផលស្មើៗគ្នា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២៧ .-**

អត្ថគាហកៈមានសិទ្ធិជាអាទិ៍ដូចខាងក្រោម៖

- ទទួលអត្ថប្រយោជន៍ដូចដែលមានចែងក្នុងលិខិតបរធនបាលកិច្ច
- ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ចដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចនិងតាមបទប្បញ្ញត្តិជាធរមាន
- ទទួលព័ត៌មានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងចាត់ចែងនៃបរធនបាលកិច្ច និង
- សិទ្ធិផ្សេងៗទៀតដែលមានចែងក្នុងលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

# ជំពូកទី៤
# ការចុះបញ្ជីបរធន ការត្រួតពិនិត្យនិងការបញ្ចប់បរធនបាលកិច្ច
## ផ្នែកទី១
## ការចុះបញ្ជីបរធន

**មាត្រា២៨ .-**

បរធនបាលកិច្ចទាំងអស់មានសុពលភាព លុះត្រាតែចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ច។

លក្ខខណ្ឌនិងនីតិវិធីលម្អិតនៃការចុះបញ្ជីត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

មុននឹងធ្វើការចុះបញ្ជីសម្រាប់ប្រតិបត្តិករបរធនបាលកិច្ចនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមមាត្រា២៨នៃច្បាប់នេះ ការបង្កើតបរធនបាលកិច្ចដើម្បីគោលបំណងណាមួយនៃច្បាប់នេះ ត្រូវមានការអនុញ្ញាតជាគោលការណ៍ជាមុនពីបញ្ញត្តិករពាក់ព័ន្ធ។

ការធ្វើប្រតិបត្តិការនៃបរធនបាលកិច្ចស្របតាមគោលបំណងនៃច្បាប់នេះត្រូវមានអាជ្ញាបណ្ណពីបញ្ញត្តិករពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិដែលមានជាធរមាន។

**មាត្រា៣០ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកត់ត្រា គ្រប់គ្រង និងរក្សាទុកនូវរាល់ព័ត៌មានរបស់បរធនបាលទាយក ឈ្មោះនៃអត្ថគាហកៈ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ ប្រតិវេទន៍ប្រចាំឆ្នាំ ការផ្លាស់ប្តូរបរធនបាល និងព័ត៌មានចាំបាច់ផ្សេងៗពាក់ព័ន្ធនឹងការចុះបញ្ជី។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

លក្ខខណ្ឌនិងនីតិវិធីធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងសេចក្តីជូនដំណឹងពីការផ្លាស់ប្តូរបរធនបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២

## ការត្រួតពិនិត្យនិងការបញ្ចប់បរធនបាលកិច្ច

**មាត្រា៣១ .-**

រាល់ប្រតិបត្តិការនៃបរធនបាលកិច្ចត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់បញ្ញត្តិករពាក់ព័ន្ធ ដើម្បីការពារការប្រើប្រាស់បរធនឱ្យស្របតាមគោលបំណងបរធនបាលកិច្ច។

ករណីចាំបាច់ដែលមិនមានការកំណត់ផ្សេងពីនេះពីបញ្ញត្តិករពាក់ព័ន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចតម្រូវឱ្យធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយសវនករឯករាជ្យ។ សវនករឯករាជ្យត្រូវមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយចំណាយលើសវនកម្មជាបន្ទុករបស់បរធនបាលកិច្ច។

តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមិនមានការកំណត់ផ្សេងពីនេះពីបញ្ញត្តិករពាក់ព័ន្ធ បរធនបាលត្រូវអនុញ្ញាតឱ្យមានការត្រួតពិនិត្យលើកំណត់ត្រាបរធនបាលកិច្ចនិងផ្តល់របាយការណ៍ហិរញ្ញវត្ថុ ឬព័ត៌មានផ្សេងទៀត។

**មាត្រា៣២ .-**

បរធនបាលកិច្ចត្រូវបានបញ្ចប់ ក្នុងករណីដូចខាងក្រោម៖

- ការមកដល់នៃកាលាវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច
- បានសម្រេចគោលបំណងរបស់បរធនបាលកិច្ច
- ការសម្រេចដោយឆន្ទានុសិទ្ធិឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក
- តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬ
- តាមករណីផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា៣៣ .-**

នៅពេលបញ្ចប់បរធនបាលកិច្ច បរធនបាលត្រូវប្រគល់របាយការណ៍នៃការគ្រប់គ្រងបរធនបាលកិច្ចទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬបញ្ញត្តិករពាក់ព័ន្ធដោយលម្អិតអំពីព័ត៌មាននៃបរធនដែលនៅសល់ ចំណូល ចំណាយ និងព័ត៌មានដែលចាំបាច់ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ហើយបរធនបាលកិច្ចត្រូវបន្តអានុភាពអនុវត្តរហូតដល់បញ្ចប់ការជម្រះបញ្ជី ហើយដែលអ្នកជម្រះបញ្ជីត្រូវជ្រើសរើសដោយបុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

បរធននៅសល់ក្រោយពីការជម្រះបញ្ជីត្រូវបែងចែកឬផ្តល់ឱ្យទៅបរធនបាលទាយកឬបុគ្គលផ្សេងទៀត ដូចមានចែងក្នុងលិខិតបរធនបាលកិច្ចឬទុកជាទ្រព្យសម្បត្តិរដ្ឋ។

# ជំពូកទី៥
# ការដោះស្រាយវិវាទនិងការធ្វើអធិការកិច្ច

## ផ្នែកទី១
## ការដោះស្រាយវិវាទ

**មាត្រា៣៤ .-**

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ច ត្រូវដោះស្រាយដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយបញ្ញត្តិករពាក់ព័ន្ធ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទជាកម្មវត្ថុនៃបណ្តឹងរដ្ឋបាលឬបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២
## ការធ្វើអធិការកិច្ច

**មាត្រា៣៥ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិចាត់តាំងមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដើម្បីតាមដានស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិធ្វើអធិការកិច្ចលើបរធនបាលកិច្ចនិងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិតាមដាន ត្រួតពិនិត្យ ស្រាវជ្រាវ និងស៊ើបអង្កេតបទល្មើសក្នុងវិស័យបរធនបាលកិច្ច។

**មាត្រា៣៦ .-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ដោយអនុវត្តឱ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្ដល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៧ .-**

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការពិនិត្យនិងការស៊ើបអង្កេតបទល្មើសដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិអំណាចធ្វើការឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីចាំបាច់ដែលត្រូវឃាត់ខ្លួនជនសង្ស័យ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។

រាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ក្នុងការពិនិត្យ ស៊ើបអង្កេតបទល្មើស និងការឃាត់ខ្លួនជនសង្ស័យត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មានសិទ្ធិស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គភាពប្រដាប់អាវុធឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា៣៨ .-**

នៅក្នុងដំណើរការអធិការកិច្ចបរធនបាលកិច្ច ក្នុងករណីមានភស្តុតាងឬលទ្ធផលវិភាគផ្ទៀងផ្ទាត់ បញ្ជាក់ថាមានការធ្វើបរធនបាលកិច្ចដែលផ្ទុយពីការអះអាងនិងការផ្ដល់សិទ្ធិនៅក្នុងលិខិតបរធនបាលកិច្ច មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិចាត់វិធានការផ្អាកជាបណ្ដោះអាសន្ន។

**មាត្រា៣៩ .-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច អាចប្ដឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គិតចាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេច។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យប្ដឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បុគ្គលនោះមានសិទ្ធិធ្វើបណ្ដឹងទៅតុលាការតាមនីតិវិធី ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេច។

**មាត្រា៤០ .-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់និងសញ្ញាស័ក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៤១ .-**

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤២ .-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចដែលបំពេញមុខងារនិងភារកិច្ចត្រឹមត្រូវតាមច្បាប់ត្រូវបានការពារដោយច្បាប់។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៤៣ .-**

បរធនបាលដែលធ្វើប្រតិបត្តិការដោយមិនបានមកស្នើសុំចុះបញ្ជីបរធន ដូចមានកំណត់ក្នុងមាត្រា២៨ នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពបរធនបាលកិច្ចជាបន្ទាន់ រួចតម្រូវឱ្យមកចុះបញ្ជីបរធននៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ ១០០ ០០០ ០០០(មួយរយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ។

**មាត្រា៤៤ .-**

បរធនបាលត្រូវផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ពី ២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន)រៀល ចំពោះអំពើដូចខាងក្រោម៖

- មិនបានរាយការណ៍និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច ឱ្យបរធនបាលទាយក អគ្គគាហកៈនិងបញ្ញត្តិករពាក់ព័ន្ធ។
- មិនផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិករពាក់ព័ន្ធ និងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ ១០០ ០០០ ០០០(មួយរយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ។

**មាត្រា៤៥ .-**

ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើណាមួយក្នុងវិស័យបរធនបាលកិច្ច ក្នុងចំណោមអំពើដូចខាងក្រោម៖

១- រំលោភលើទំនុកចិត្តឬរំលោភអំណាចក្នុងការបំពេញមុខងាររបស់បរធនបាល ក្នុងគោលបំណងទទួលផលប្រយោជន៍ផ្ទាល់ខ្លួនឬដល់តតិយជនឬក្នុងគោលបំណងធ្វើឱ្យខូចប្រយោជន៍ដល់ភាគីពាក់ព័ន្ធ។

២- ឆបោកក្នុងវិស័យបរធនបាលកិច្ចដែលប្រព្រឹត្តដោយបរធនបាល។

៣- រារាំងឬជ្រៀតជ្រែកដល់មន្ត្រីអធិការកិច្ចក្នុងការបំពេញមុខងារដូចមានចែងក្នុងមាត្រា៣៥នៃច្បាប់នេះ។

៤- ក្លែងបន្លំឯកសារ ឬបំភ័ន្តក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬផ្សព្វផ្សាយឬផ្តល់ព័ត៌មានមិនពិតប្រព្រឹត្តដោយបរធនបាល ដែលនាំឱ្យខូចផលប្រយោជន៍ដល់ភាគីពាក់ព័ន្ធ។

៥- បំផ្លាញឯកសារភស្តុតាងនៃបទល្មើសក្នុងវិស័យបរធនបាលកិច្ច ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្រាវជ្រាវរបស់មន្ត្រីអធិការកិច្ចឬមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៤៦ .-**

បរធនបាលដែលមានចេតនាផ្តល់ព័ត៌មានមិនពិត ក្នុងការចុះបញ្ជីបរធនដំបូងឬចុះបញ្ជីបរធនបន្ត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ២០០ ០០០ ០០០(ពីររយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំ។

**មាត្រា៤៧ .-**

បុគ្គលឬបរធនបាលដែលចូលរួមប្រព្រឹត្តបទល្មើសទាក់ទងនឹងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវផ្តន្ទាទោសដោយអនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន។

**មាត្រា៤៨ .-**

បរធនបាលដែលទម្លាយការសម្ងាត់វិជ្ជាជីវៈដែលបណ្តាលឱ្យខូចផលប្រយោជន៍ភាគីពាក់ព័ន្ធត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ១០០ ០០០ ០០០(មួយរយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ។

**មាត្រា៤៩ .-**

នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៤៣ កថាខណ្ឌទី២នៃមាត្រា៤៤ និងចំណុចទី១ ទី៤ និងទី៥នៃមាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៨ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ២០០ ០០០ ០០០(ពីររយលាន)រៀល និងមិនអនុញ្ញាតឱ្យធ្វើជាបរធនបាលនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ ស្តីពីទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៥០ .-**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៤៣ កថាខណ្ឌទី២ នៃមាត្រា៤៤ និងមាត្រា៤៥ដល់មាត្រា៤៨នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៤(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ ដោយរួមទាំងការសម្រេចមិនអនុញ្ញាតឱ្យធ្វើជាបរធនបាលនៅព្រះរាជាណាចក្រកម្ពុជា។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៥១ .-**

ចំពោះបទល្មើសទាំងឡាយណាដែលពុំមានចែងនៅក្នុងច្បាប់នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៥២ .-**

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្ដីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចដូចមានចែងនៅក្នុងជំពូកនេះ អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេច។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យប្ដឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បុគ្គលនោះមានសិទ្ធិធ្វើបណ្ដឹងទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេច។

**មាត្រា៥៣ .-**

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ)នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ)នៃមាតិកាទី៣(ការបង្ខំដល់រូបកាយ)នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្ដីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

[illegible]រយៈពេល៣(បី)ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន បុគ្គលដែលបាននិងកំពុងគ្រប់គ្រងបរធនបាលកិច្ច [illegible]ចុះបញ្ជីបរធនបាលកិច្ច ដូចមានចែងក្នុងមាត្រា២៨នៃច្បាប់នេះ។

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីបរធនបាលកិច្ច

## សន្ទានុក្រម

បច្ចេកសព្ទសំខាន់ៗជាសារវន្ត ដែលត្រូវបានប្រើក្នុងច្បាប់ស្តីពីបរធនបាលកិច្ចមាននិយមន័យដូចតទៅ៖

១- ក្រមរដ្ឋប្បវេណី សំដៅដល់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

២- ក្រមព្រហ្មទណ្ឌ សំដៅដល់ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៣- ក្រមនីតិវិធីព្រហ្មទណ្ឌ សំដៅដល់ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៤- ទ្រព្យសម្បត្តិ សំដៅដល់ចលនវត្ថុនិងអចលនវត្ថុដែលបានកំណត់ក្នុងមាត្រា១២០នៃក្រមរដ្ឋប្បវេណី។

៥- ទ្រព្យសម្បត្តិបរធនបាលកិច្ច សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅក្នុងបរធនបាលកិច្ច និងផលដែលបានពីទ្រព្យសម្បត្តិឬមូលនិធិនោះ។

៦- បរធន សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅឱ្យបរធនបាលគ្រប់គ្រងនិងចាត់ចែងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៧- បរធនបាល សំដៅដល់បុគ្គលដែលទទួលសិទ្ធិគ្រប់គ្រងនិងចាត់ចែងបរធនពីបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៨- បរធនបាលកិច្ច សំដៅដល់កិច្ចការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៩- បរធនបាលទាយក សំដៅដល់បុគ្គលដែលបង្កើតនិងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិឬមូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច។

១០- បុគ្គល សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ទោះជាបុគ្គលនោះស្វែងរកប្រាក់ចំណេញឬមិនស្វែងរកប្រាក់ចំណេញ។

១១- ប្រទានកម្ម សំដៅដល់កិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនគិតថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១២- **មតកសាសន៍** សំដៅដល់លិខិតបណ្តាំដែលបុគ្គលបានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ដើម្បីសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។

១៣- **លិខិតបរធនបាលកិច្ច** សំដៅដល់៖

ក- លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពីការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដែលត្រូវបានធ្វើឡើងរវាងបរធនបាលទាយកឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាល ដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬឃុំសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែល មានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

ខ- មតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។

១៤- **សិទ្ធិប្រត្យក្ស** សំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។

១៥- **សេវារក្សាទុក** សំដៅដល់ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយទៅឱ្យបរធនបាលដើម្បីរក្សាទុក ហើយប្រគល់ទៅឱ្យបុគ្គលផ្សេងទៀតឬប្រគល់ត្រឡប់ទៅឱ្យបុគ្គលនោះវិញ តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ច។

១៦- **អត្ថគាហក:** សំដៅដល់បុគ្គលដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។

១៧- **អ្នកផ្តល់វិភាគទានបរធនបាលកិច្ច** សំដៅដល់បុគ្គលដែលផ្តល់វិភាគទានទៅក្នុងបរធនបាលកិច្ច ឬបរធនបាលកិច្ចដែលមានស្រាប់ និងមានសិទ្ធិចូលរួមកំណត់លក្ខខណ្ឌនៃការបង់វិភាគទានដែលនឹងត្រូវគ្រប់គ្រង និងចាត់ចែងដោយបរធនបាល និងលក្ខខណ្ឌនៃការទទួលផលរបស់អត្ថគាហក:។

១៨- **អំណោយ** សំដៅដល់ការផ្ទេរទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដោយគ្មានតម្លៃតបស្នងឬកាតព្វកិច្ចត្រឡប់។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ឧបសម្ព័ន្ធទី ២
# អនុក្រឹត្យស្តីពីការចុះបញ្ជី
# បរធនបាលកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១១៤ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការចុះបញ្ជីបរធនបាលកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្ដីពី បរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងការចុះបញ្ជីបរធនបាលកិច្ចដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីវិធាននិងនីតិវិធីនៃការចុះបញ្ជីបរធនបាលកិច្ច។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសមត្ថកិច្ចជាបញ្ញត្តិករនៃបរធនបាលកិច្ចដែលមានភារកិច្ចជាអាទិ៍ដូចខាងក្រោម៖

- កំណត់វិធាន និងនីតិវិធីនៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យរបស់បរធនបាលកិច្ច
- កំណត់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុសម្រាប់បរធនបាលកិច្ច
- ទទួលចុះបញ្ជី រក្សា និងគ្រប់គ្រងបញ្ជីបរធនបាលកិច្ច
- កត់ត្រាក្នុងបញ្ជីបរធនបាលកិច្ចនូវរាល់ការផ្លាស់ប្តូរពាក់ព័ន្ធនឹងបរធនបាលកិច្ច
- គ្រប់គ្រងនិងត្រួតពិនិត្យអនុលោមភាពនៃលិខិតបរធនបាលកិច្ច
- កំណត់ទណ្ឌកម្ម វិន័យ និងវិធានការរដ្ឋបាលចំពោះសកម្មភាពបំពានបទប្បញ្ញត្តិពាក់ព័ន្ធនឹងបរធនបាលកិច្ច
- ចាត់វិធានការតាមផ្លូវច្បាប់ចំពោះបុគ្គលដែលគ្រប់គ្រងមូលនិធិជាបរធនដែលមិនបានចុះបញ្ជី
- ចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីដកហូតបរធនឱ្យរដ្ឋគ្រប់គ្រងជំនួសឬចាត់តាំងបរធនបាលជំនួសដោយសហការជាមួយបញ្ញត្តិករពាក់ព័ន្ធ
- ប្រកាសបញ្ចប់បរធនបាលកិច្ចតាមសំណើរបស់បរធនបាលទាយក
- ផ្សះផ្សានិងធ្វើសេចក្តីសម្រេចលើវិវាទដែលពាក់ព័ន្ធនឹងបរធនបាលកិច្ច
- បំពេញកិច្ចការផ្សេងទៀតដែលចាំបាច់សម្រាប់ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យបរធនបាលកិច្ច។

**មាត្រា៥ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃបរធនបាលកិច្ចដូចមានចែងក្នុងមាត្រា១៤នៃច្បាប់ស្តីពីបរធនបាលកិច្ចដែលមិនត្រូវបានកំណត់ដោយបញ្ញត្តិករពាក់ព័ន្ធ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២
## លិខិតបរធនបាលកិច្ច

**មាត្រា៦ .-**

បរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយលិខិតលាយលក្ខណ៍អក្សរតាមទម្រង់ដែលមានខ្លឹមសារកំណត់ជាមូលដ្ឋានដូចខាងក្រោម៖

- ឈ្មោះនិងអាសយដ្ឋានរបស់បរធនបាល អត្ថគាហកៈ និងបរធនបាលទាយក និង/ឬបរធនបាលទាយកជំនួស និង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច
- គោលបំណងនៃបរធនបាលកិច្ច
- លិខិតយុត្តិការបញ្ជាក់បរធនមានជាអាទិ៍ ៖
  - ការបញ្ជាក់ពីប្រភពនៃបរធន
  - ចំនួនសរុបនិង/ឬសមតុល្យនៃមូលនិធិបរធនបាលកិច្ច
- រយៈពេលកំណត់នៃបរធនបាលកិច្ច
- សិទ្ធិនិងកាតព្វកិច្ចរបស់បរធនបាល អត្ថគាហកៈ និងបរធនបាលទាយក និង/ឬបរធនបាលទាយកជំនួស និង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច
- លក្ខខណ្ឌនៃការបញ្ចប់បរធនបាលកិច្ច
- ការចាត់ចែងបរធននៅពេលបរធនបាលកិច្ចត្រូវបានបញ្ចប់
- លក្ខខណ្ឌនៃការកែប្រែបរធនបាលកិច្ច
- គោលដៅនៃការវិនិយោគនិង/ឬប្រើប្រាស់ទ្រព្យសម្បត្តិរបស់បរធនបាលកិច្ច
- បញ្ជីបរធនដែលជាកម្មវត្ថុនៃបរធនបាលកិច្ច
- ធាតុផ្សំផ្សេងទៀតដែលតម្រូវតាមគោលបំណងនៃបរធនបាលទាយកនិង/ឬបរធនបាលទាយកជំនួស និង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និង
- លាភការរបស់បរធនបាលដែលត្រូវកំណត់ដោយផ្អែកលើគុណវុឌ្ឍិវិជ្ជាជីវៈ និងបទពិសោធការងារ

លិខិត បរធនបាលកិច្ចមានគំរូកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការចុះបញ្ជីបរធនបាលកិច្ច

**មាត្រា៧ .-**

បរធនបាលនៃបរធនបាលកិច្ចមានកាតព្វកិច្ចចុះបញ្ជីបរធនបាលកិច្ចនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែកបរធនបាលកិច្ចហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី១នៃមាត្រា១១នៃច្បាប់ស្តីពីបរធនបាលកិច្ចត្រូវអនុវត្តដោយអនុលោមតាមអនុក្រឹត្យលេខ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ។

ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ចត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

ក្នុងករណីមានការតម្រូវពីបញ្ញត្តិករពាក់ព័ន្ធ បរធនបាលអាចធ្វើការស្នើសុំគោលការណ៍អនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ឯកសារតម្រូវសម្រាប់ការស្នើសុំគោលការណ៍អនុញ្ញាតជាមុនមានដូចខាងក្រោម៖

- លិខិតតែងតាំងបុគ្គលតំណាងស្របច្បាប់ដើម្បីស្នើសុំការចុះបញ្ជីបរធនបាលកិច្ចឬលិខិតបរធនបាលកិច្ច
- សញ្ញាបត្រឬវិញ្ញាបនបត្របញ្ជាក់ការសិក្សាដែលមានកម្រិតទាបបំផុតស្មើនឹងបរិញ្ញាបត្ររបស់បុគ្គលតំណាងស្របច្បាប់ ដើម្បីស្នើសុំការចុះបញ្ជីបរធនបាលកិច្ច
- សេចក្តីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត ចំពោះនីតិបុគ្គល
- ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិក : លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណថតចម្លង (សម្រាប់ភាគទុនិកជារូបវន្តបុគ្គល) ឈ្មោះ ទម្រង់គតិយុត្ត និងអាសយដ្ឋានទីស្នាក់ការកណ្តាល (សម្រាប់ភាគទុនិកជានីតិបុគ្គល)
- ឯកសារថតចម្លងបញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល។ ឯកសារមានជាអាទិ៍ លិខិតឆ្លងដែនឬអត្តសញ្ញាណបណ្ណថតចម្លង ប្រវត្តិរូបសង្ខេបស្តីពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រឬវិញ្ញាបនបត្រជំនាញ
- ឯកសារផ្សេងៗ ទៅតាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រោយពីពិនិត្យនិងវាយតម្លៃលើឯកសារតម្រូវខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិសម្រេចចេញគោលការណ៍អនុញ្ញាតឬបដិសេធក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំដែលបានបំពេញលក្ខខណ្ឌនិងមានលិខិតគ្រប់គ្រាន់។

**មាត្រា៩ .-**

បរធនបាលដែលទទួលបានការអនុញ្ញាតជាគោលការណ៍ជាមុន ឬអាជ្ញាបណ្ណជាប្រតិបត្តិករពីបញ្ញត្តិករពាក់ព័ន្ធនិង/ ឬបានបំពេញនីតិវិធីតាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើការស្នើសុំចុះបញ្ជីបរធនបាលកិច្ច ដោយភ្ជាប់មកជាមួយនូវលិខិតពាក់ព័ន្ធដូចខាងក្រោម៖

**ក- ក្នុងករណីបរធនបាលជារូបវន្តបុគ្គលឬក្រុមនៃរូបវន្តបុគ្គល**

- លិខិតបរធនបាលកិច្ច
- លិខិតបញ្ជាក់តុល្យភាពនៃបរធនពីស្ថាប័នហិរញ្ញវត្ថុ
- វិញ្ញាបនបត្របញ្ជាក់ការសិក្សា (ដែលមានកម្រិតទាបបំផុតត្រឹមបរិញ្ញាបត្រជំនាញ)
- ប្រវត្តិរូបសង្ខេបដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ
- លិខិតថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃលិខិតថ្កោលទោសរបស់បរធនបាល
- កិច្ចសន្យាធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងលើបរធន
- កិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើមុខងារជាបរធនបាល និង
- ឯកសារផ្សេងទៀត ទៅតាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលទទួលបានការអនុញ្ញាតជាគោលការណ៍ឬអាជ្ញាបណ្ណពីបញ្ញត្តិករពាក់ព័ន្ធ បរធនបាលត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារថតចម្លងដូចដែលបានរៀបរាប់ខាងលើ។

**ខ- ក្នុងករណីបរធនបាលជានីតិបុគ្គល ក្រុមនៃនីតិបុគ្គលឬក្រុមចម្រុះរវាងរូបវន្តបុគ្គល និងនីតិបុគ្គល**

បរធនបាលជានីតិបុគ្គល ក្រុមនៃនីតិបុគ្គល ឬក្រុមចម្រុះរវាងរូបវន្តនិងនីតិបុគ្គល ត្រូវបំពេញឯកសារដូចមានចែងក្នុងចំណុច “ក” នៃមាត្រា៩ និងបន្ថែមឯកសារជាសារវន្ត ដូចខាងក្រោមៈ

- លិខិតនិងលក្ខន្តិកៈដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និង/ឬ បញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធ និង
- លិខិតចម្លងនៃគោលការណ៍អនុញ្ញាតជាមុនឬអាជ្ញាបណ្ណឱ្យប្រកបអាជីវកម្មពីបញ្ញត្តិករពាក់ព័ន្ធ។

**មាត្រា១០ .-**

បរធនបាលត្រូវមានសមាសភាពជាចំនួនសេសលើសពី១ (មួយ) ដែលជារូបវន្តបុគ្គលឬតំណាងនីតិបុគ្គល លើកលែងតែប្រភេទបរធនបាលកិច្ចបុគ្គលដែលអាចមានបរធនបាលជារូបវន្តបុគ្គលតែ១(មួយ)រូប។ នីតិបុគ្គលនីមួយៗមានសិទ្ធិចាត់តាំងតំណាងជារូបវន្តបុគ្គលតែ១(មួយ)រូបប៉ុណ្ណោះដើម្បីចូលរួមក្នុងសមាសភាពបរធនបាល។

សម្រាប់បរធនបាលដែលមានសមាសភាពជាក្រុម សេចក្តីសម្រេចក្នុងកិច្ចការគ្រប់គ្រងបរធនបាលកិច្ចត្រូវធ្វើឡើងតាមសំឡេងភាគច្រើនដាច់ខាត។

ក្នុងករណីបរធនបាលជានីតិបុគ្គលតែមួយ បរធនបាលកិច្ចត្រូវគ្រប់គ្រងដោយថ្នាក់ដឹកនាំនៃនីតិបុគ្គលនោះ។

**មាត្រា១១ .-**

បុគ្គលដែលអាចត្រូវតែងតាំងជាបរធនបាលត្រូវទទួលការបណ្តុះបណ្តាលលើជំនាញវិជ្ជាជីវៈបរធនបាលតាមការកំណត់របស់បញ្ញត្តិករនៃវិស័យបរធនបាលកិច្ច។

**មាត្រា១២ .-**

បរធនបាលត្រូវមកចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីទទួលបន្ទុកចុះបញ្ជីបរធនបាលកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាអះអាងនិងទទួលខុសត្រូវអំពីភាពត្រឹមត្រូវនិងភាពពិតប្រាកដនៃសំណុំលិខិតស្នើសុំចុះបញ្ជីបរធនបាលកិច្ច។

**មាត្រា១៣ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចទទួលចុះបញ្ជីបរធនបាលកិច្ចឬបដិសេធចុះបញ្ជីបរធនបាលកិច្ចក្នុងរយៈពេល៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី។ ក្នុងករណីចាំបាច់ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជូនដំណឹងដល់ម្ចាស់សំណើស្នើសុំចុះបញ្ជី។

ក្នុងករណីសំណុំលិខិតស្នើសុំចុះបញ្ជីពុំបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនដំណឹងដល់បរធនបាលដែលជាម្ចាស់សំណើយ៉ាងយូររយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ហើយបរធនបាលដែលជាម្ចាស់សំណើត្រូវកែតម្រូវឯកសារនិងបំពេញបន្ថែមលក្ខខណ្ឌដែលខ្វះចន្លោះនិងប្រគល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ មិនឱ្យលើសរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃជូនដំណឹង។ ការហួសរយៈពេលកំណត់នេះ ពាក្យស្នើសុំចុះបញ្ជីត្រូវចាត់ទុកថាបោះបង់ចោល។

បន្ទាប់ពីសម្រេចទទួលចុះបញ្ជីបរធនបាលកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវផ្ដល់វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចជូនបរធនបាលដែលជាម្ចាស់សំណើចុះបញ្ជី។

## ជំពូកទី៤
## វិញ្ញាបនបត្រចុះបញ្ជីនិងការស្នើសុំផ្លាស់ប្ដូរពាក់ព័ន្ធនឹងលិខិតបរធនបាលកិច្ច

### មាត្រា១៤ .-

វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច មានសុពលភាពសម្រាប់ថិរវេលាដែលត្រូវបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ចឬតាមការកំណត់របស់បញ្ញត្តិករនៃវិស័យបរធនបាលកិច្ច។

បរធនបាលត្រូវធ្វើការស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចរយៈពេលយ៉ាងតិច៦០(ហុកសិប)ថ្ងៃ មុនពេលវិញ្ញាបនបត្រអស់សុពលភាព ដោយត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរនិងបំពេញសំណុំឯកសារពាក់ព័ន្ធ ទៅតាមតម្រូវការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### មាត្រា១៥ .-

រាល់ការផ្លាស់ប្ដូរដែលមានការពាក់ព័ន្ធនឹងលិខិតបរធនបាលកិច្ច បរធនបាលត្រូវធ្វើការស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធសម្រាប់កត់ត្រាការផ្លាស់ប្ដូរនេះក្នុងបញ្ជីបរធនបាលកិច្ច លើកលែងតែការកែប្រែគោលបំណងនៃបរធនបាលកិច្ច ដូចមានចែងក្នុងមាត្រា១៥នៃច្បាប់ស្ដីពីបរធនបាលកិច្ច។

### មាត្រា១៦ .-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិធ្វើការបដិសេធទៅនឹងសំណើរបស់បរធនបាលដូចមានចែងក្នុងមាត្រា១៤និងមាត្រា១៥នៃអនុក្រឹត្យនេះ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់តាមរយៈលិខិតជាលាយលក្ខណ៍អក្សរផ្ញើទៅម្ចាស់សំណើ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិស្នើសុំនូវសំណុំឯកសារបន្ថែមនិង/ឬអញ្ជើញភាគីពាក់ព័ន្ធមកធ្វើការបកស្រាយនិងឆ្លើយបំភ្លឺនូវសំណើសុំកែប្រែផ្លាស់ប្ដូរទាំងឡាយតាមការចាំបាច់។

ក្នុងករណីសំណុំលិខិតស្នើសុំកែប្រែផ្លាស់ប្ដូរខាងលើពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់កត់ត្រាការកែប្រែផ្លាស់ប្ដូរក្នុងបញ្ជីបរធនបាលកិច្ច នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ដល់រយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងទៅម្ចាស់សំណើ។ ការហួសរយៈពេលកំណត់នេះ សំណើសុំនោះត្រូវចាត់ទុកថាបោះបង់ចោល។

## ជំពូកទី៥
## ការត្រួតពិនិត្យនិងការបញ្ចប់បរធនបាលកិច្ច

**មាត្រា១៧ .-**

បរធនបាលត្រូវមានកាតព្វកិច្ចផ្តល់កំណត់ត្រាបរធនបាលកិច្ច របាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានផ្សេងទៀតតាមការកំណត់របស់បញ្ញត្តិករបរធនបាលកិច្ច ដូចមានចែងក្នុងមាត្រា៣១នៃច្បាប់ស្តីពីបរធនបាលកិច្ច។

**មាត្រា១៨ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចដកហូតវិញ្ញាបនបត្របរធនបាលកិច្ច ក្នុងករណីណាមួយដូចខាងក្រោម៖

- បរធនបាលផ្តល់ព័ត៌មានមិនពិត មិនជាក់លាក់ឬបិទបាំង ឬមិនបង្ហាញការពិតនៅក្នុងពាក្យស្នើសុំចុះបញ្ជី ឬបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច
- បរធនបាលបានប្រើប្រាស់ប្រតិបត្តិការបរធនបាលកិច្ច ក្នុងគោលបំណងនៃការសម្អាតប្រាក់និង/ឬ ហិរញ្ញប្បទានភេរវកម្មឬឧក្រិដ្ឋកម្ម
- បរធនត្រូវបានប្រើប្រាស់ខុសពីគោលបំណងដើមនិង/ឬហួសរយៈពេលកំណត់របស់បរធនបាលកិច្ច
- បរធនមានសមតុល្យអវិជ្ជមាន
- បរធនបាលខកខានក្នុងការបង់សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំឬសោហ៊ុយប្រតិវេទន៍ប្រចាំឆ្នាំ ក្នុងរយៈពេល ២(ពីរ)ឆ្នាំបន្តបន្ទាប់
- បរធនបាលខកខានមិនបានអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា២៣នៃច្បាប់ស្តីពីបរធនបាលកិច្ច
- បរធនបាលបន្តធ្វើប្រតិបត្តិការបរធនបាលកិច្ចដោយបំពានឬមិនអនុលោមតាមបទប្បញ្ញត្តិជាធរមាន បន្ទាប់ពីទទួលបានការណែនាំឬទទួលរងការពិន័យពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ
- ក្នុងករណីដែលបញ្ញត្តិករពាក់ព័ន្ធដកហូតអាជ្ញាបណ្ណ។

**មាត្រា១៩ .-**

ក្រោយពីការដកហូតវិញ្ញាបនបត្រដូចមានចែងក្នុងមាត្រា១៨នៃអនុក្រឹត្យនេះ ក្រសួងត្រូវអនុវត្តនីតិវិធីនៃការបញ្ចប់បរធនបាលកិច្ចដូចមានចែងនៅក្នុងជំពូកទី៤នៃច្បាប់ស្តីពីបរធនបាលកិច្ចនិងជំពូកទី៥នៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២០ .-**

បរធនបាលឬបុគ្គលពាក់ព័ន្ធដែលមិនសុខចិត្តនឹងសេចក្តីសម្រេចដកហូតវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច មានសិទ្ធិប្តឹងតវ៉ាអំពីសេចក្តីសម្រេចនេះ ទៅតាមយន្តការដោះស្រាយវិវាទដូចមានចែងក្នុងមាត្រា៣៤ នៃច្បាប់ស្តីពីបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២១ .-**

បរធនបាលទាយកឬបរធនបាលទាយកជំនួសមានសិទ្ធិចាត់តាំងអភិបាលបណ្តោះអាសន្នសម្រាប់គ្រប់គ្រងបរធនបាលកិច្ច ក្នុងករណីយល់ឃើញថាមានហានិភ័យលើសាធនភាពតាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា២២ .-**

ក្នុងករណីដែលបរធនបាលកិច្ចត្រូវបានបញ្ចប់ បរធនបាលទាយកឬបរធនបាលទាយកជំនួសត្រូវជ្រើសតាំងអ្នកជម្រះបញ្ជីដើម្បីគ្រប់គ្រងនិងវាយតម្លៃបរធនដូចមានចែងក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

បរធនបាលកិច្ចត្រូវបន្តអត្ថិភាពគតិយុត្តរហូតដល់ការជម្រះបញ្ជីត្រូវបានបញ្ចប់ជាស្ថាពរ។

**មាត្រា២៣ .-**

អ្នកជម្រះបញ្ជីមានភារកិច្ចដូចខាងក្រោម៖

- បំពេញនិងបញ្ចប់កិច្ចការដែលនៅសេសសល់របស់បរធនបាល
- ប្រមូលនិងទូទាត់បំណុលដែលនៅសល់
- វាយតម្លៃបរធនដែលនៅសល់។

បរធនដែលនៅសល់ក្រោយពីការជម្រះបញ្ជី ត្រូវបែងចែកឬផ្តល់ឱ្យទៅបរធនបាលទាយកឬអត្ថគាហកៈ ឬបុគ្គលផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ចឬទុកជាទ្រព្យសម្បត្តិរដ្ឋ។

ក្នុងករណីអត្ថគាហកៈជាកុមារឬអសមត្ថជន នោះបញ្ញត្តិករបរធនបាលកិច្ច ឬអាណាព្យាបាលស្របច្បាប់ ឬហិតូបត្ថម្ភកៈមានសមត្ថកិច្ចបំពេញមុខងារជាបរធនបាលទាយកជំនួស ដូចមានចែងក្នុងក្រមរដ្ឋប្បវេណីរហូតដល់អត្ថគាហកៈនោះមានសិទ្ធិពេញលេញឬមានសមត្ថភាពឡើងវិញក្នុងការកាន់កាប់ទ្រព្យសម្បត្តិ ស្របច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៦
## ការពិន័យអន្តរការណ៍

**មាត្រា២៤ .-**

បរធនបាលឬបរធនបាលទាយកត្រូវទទួលការផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ចពី ១០ ០០០ ០០០ (ដប់លាន) រៀលទៅ៣០ ០០០ ០០០ (សាមសិបលាន) រៀលនិង/ឬត្រូវបញ្ឈប់បរធនបាលកិច្ចជាបន្ទាន់ រួចតម្រូវឱ្យមកដាក់ពាក្យស្នើសុំនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទបញ្ញត្តិនៃច្បាប់ស្តីពីបរធនបាលកិច្ច ចំពោះការប្រព្រឹត្តណាមួយដូចខាងក្រោម៖

- យឺតយ៉ាវឬខកខានក្នុងការស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច។
- ខកខានក្នុងការស្នើសុំផ្លាស់ប្តូរបរធនបាល
- ខកខានក្នុងការស្នើសុំផ្លាស់ប្តូរដែលពាក់ព័ន្ធនឹងលិខិតបរធនបាលកិច្ច

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទៅតាមច្បាប់និងបទប្បញ្ញត្តិដែលមានជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ លើកលែងអនុក្រឹត្យលេខ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ កើត ខែស្រាពណ៍ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ លើកលែងអនុក្រឹត្យលេខ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ កើត ខែស្រាពណ៍ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៣

# អនុក្រឹត្យស្តីពីបរធនបាលកិច្ច

# ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧៦ . អនក្រ . បក

# អនុក្រឹត្យ

# ស្តីពី

# បរធនបាលកិច្ចហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីវិធាន និងនីតិវិធី នៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា២ ._**

អនុក្រឹត្យនេះ មានគោលបំណងគ្រប់គ្រងមូលនិធិជាបរធនដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

**មាត្រា៣ ._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុដែលទទួលមូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ឬអនុបំណុល ក្នុងគោលបំណងអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ._**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចជាបញ្ញត្តិករ នៃបរធនបាលកិច្ចហិរញ្ញវត្ថុដែលមានភារកិច្ចជាអាទិ៍ដូចខាងក្រោម÷

- កំណត់វិធាន និងនីតិវិធីនៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- កំណត់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់បរធនបាលកិច្ចហិរញ្ញវត្ថុ
- ចុះបញ្ជី និងគ្រប់គ្រងបញ្ជីរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- កត់ត្រាក្នុងបញ្ជីនូវរាល់ការផ្លាស់ប្តូរពាក់ព័ន្ធនឹងបរធនបាលកិច្ចហិរញ្ញវត្ថុ
- គ្រប់គ្រង និងត្រួតពិនិត្យដំណើរការរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- កំណត់ទណ្ឌកម្មវិន័យ និងវិធានការរដ្ឋបាលចំពោះសកម្មភាពបំពានបទប្បញ្ញត្តិពាក់ព័ន្ធបរធនបាលកិច្ចហិរញ្ញវត្ថុ
- ចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីដកហូតបរធនឱ្យរដ្ឋគ្រប់គ្រងជំនួស ឬចាត់តាំងបរធនបាលជំនួស ក្នុងករណីបរធនបាលមិនអនុវត្តតាមខ្លឹមសារនៃលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន
- ប្រកាសបញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ តាមសំណើរបស់បរធនបាលទាយក បន្ទាប់ពីការជម្រះបញ្ជី
- ចាត់វិធានការតាមផ្លូវច្បាប់ ចំពោះបុគ្គលដែលគ្រប់គ្រងមូលនិធិជាបរធនដែលមិនបានចុះបញ្ជី

- ផ្សះផ្សា និងធ្វើសេចក្តីសម្រេចលើវិវាទដែលពាក់ព័ន្ធនឹងបរធនបាលកិច្ចហិរញ្ញវត្ថុ នៅក្នុងក្របខណ្ឌនៃក្រុមប្រឹក្សានីតិកម្ម
- បង្កើតមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ
- បំពេញកិច្ចការផ្សេងទៀតដែលចាំបាច់សម្រាប់ការទ្រទ្រង់ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា៥ .-**

ពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះមានន័យ ដូចខាងក្រោម÷

**-បរធន** សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិដែលបានមកពីមូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ដែលបានចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

**-បរធនបាល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលថែរក្សា និងគ្រប់គ្រងបរធន ដោយអនុលោមតាមបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលត្រូវបានចុះបញ្ជី នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**-បរធនបាលទាយក** សំដៅដល់ដៃគូអភិវឌ្ឍដែលបានចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលក្នុងគោលបំណងផ្តល់មូលនិធិជាបរធនឱ្យទៅបរធនបាល សម្រាប់អភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈនៅព្រះរាជាណាចក្រកម្ពុជា។

**-អត្ថគាហកៈ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលប្រយោជន៍អំពីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**-បរធនបាលកិច្ច** សំដៅដល់កិច្ចការរបស់បរធនបាលក្នុងការថែរក្សា និងគ្រប់គ្រងបរធនដែលផ្តល់ដោយបរធនបាលទាយក ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ។

**-លិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ** សំដៅដល់លិខិតគតិយុត្ត ដែលកំណត់អំពីការបង្កើត ការគ្រប់គ្រង ការត្រួតពិនិត្យ និងការបញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ។

**-មូលនិធិហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ** សំដៅដល់សមតុល្យហិរញ្ញប្បទានឥតសំណងសរុបចុងក្រោយ បន្ទាប់ពីត្រូវបានប្រើប្រាស់ស្របតាមគោលបំណងរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ។ សមតុល្យនេះត្រូវគណនាតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់គោលបំណងនៃការចុះបញ្ជី។

**-ហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ** សំដៅដល់មូលនិធិជំនួយឥតសំណងដំបូងដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍឱ្យទៅបុគ្គលណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់គោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ។

**-អនុបំណុល** សំដៅដល់មូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ដែលកំពុងត្រូវបានប្រើប្រាស់ដោយនីតិបុគ្គលណាមួយ ក្នុងគោលបំណងបន្តសកម្មភាពអភិវឌ្ឍន៍វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀងអនុបំណុល។

**-កិច្ចព្រមព្រៀងអនុបំណុល** សំដៅដល់កិច្ចព្រមព្រៀងដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើឡើងជាមួយដៃគូអភិវឌ្ឍ ដើម្បីទទួលយកអនុបំណុលមកគ្រប់គ្រងជំនួស សម្រាប់បន្តសកម្មភាពអភិវឌ្ឍន៍វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។

-ឆ្នាំសារពើពន្ធ សំដៅរយៈពេលរាប់គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឬថ្ងៃផ្តើមធ្វើប្រតិបត្តិការ ចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុទើបបង្កើតថ្មី រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឬរយៈពេលផ្សេងទៀតដែលសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ២
## ការបង្កើត និងការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ

**មាត្រា៦ ._**

បរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយលិខិតលាយលក្ខណ៍អក្សរតាមទម្រង់កំណត់ និងត្រូវចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បុគ្គលទាំងឡាយណាដែលមានបំណងបង្កើត ឬធ្វើប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ មានកាតព្វកិច្ចរៀបចំបង្កើតលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមុនសិន តាមវិធាន និងនីតិវិធីជាធរមាន។

បុគ្គលទាំងឡាយណាដែលទទួលមូលនិធិជាបរធន ដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ មានកាតព្វកិច្ចបង្កើតបរធនបាលកិច្ចហិរញ្ញវត្ថុ និងចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមវិធាន និងនីតិវិធីជាធរមាន។ ក្នុងករណីដែលដៃគូអភិវឌ្ឍពាក់ព័ន្ធពុំមានលទ្ធភាព ឬសមត្ថភាពជាស្ថាពរក្នុងការចូលរួមបង្កើតបរធនបាលកិច្ចហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចបំពេញមុខងារជំនួស។

បទប្បញ្ញត្តិខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះបុគ្គលទាំងឡាយដែលគ្រប់គ្រងអនុបំណុល។

**មាត្រា៧ ._**

បរធនបាលកិច្ចហិរញ្ញវត្ថុ មានសុពលភាព និងអានុភាពគតិយុត្ត លុះត្រាតែត្រូវបានចុះបញ្ជី នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចទទួលចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីទទួលបានសំណើដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ សម្រាប់ការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

ក្នុងករណីបដិសេធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជាក់អំពីមូលហេតុច្បាស់លាស់តាមរយៈលិខិតលាយលក្ខណ៍អក្សរផ្ញើជូនទៅម្ចាស់សំណើ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសំណើ។

**មាត្រា៨ ._**

បរធនបាលកិច្ចហិរញ្ញវត្ថុដែលមានសុពលភាព ត្រូវមានអានុភាពបង្កើតសិទ្ធិ និងកាតព្វកិច្ចដល់បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ តាមលក្ខខណ្ឌ និងខ្លឹមសារដែលមានចែងក្នុងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន។

រាល់ប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្រោមច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៣
## បរធនបាលទាយក និង អត្ថគាហកៈ

**មាត្រា៩ .-**

បរធនបាលទាយកមានសិទ្ធិជាសារវន្ត ដូចខាងក្រោម÷

- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលមានជាអាទិ៍របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត
- តែងតាំង និងបញ្ឈប់បរធនបាល តាមលក្ខខណ្ឌដែលបានកំណត់
- អាចបំពេញមុខងារជាបរធនបាលដោយខ្លួនឯង
- បញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងករណីដែលគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុមិនត្រូវបានបំពេញត្រឹមត្រូវ ឬត្រូវបានសម្រេចរួចរាល់ហើយ
- បញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ ដោយឆន្ទានុសិទ្ធិ ឬមតិជាឯកច្ឆន្ទក្នុងករណីបរធនបាលទាយកមានច្រើនស្របតាមវិធាន និងនីតិវិធីជាធរមាន
- ចាត់តាំងអភិបាលបណ្ដោះអាសន្នសម្រាប់គ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងករណីយល់ឃើញថាមានហានិភ័យលើសាធនភាព
- ចាត់តាំងអ្នកជម្រះបញ្ជី ក្នុងករណីបរធនបាលកិច្ចហិរញ្ញវត្ថុត្រូវបានបញ្ចប់។

**មាត្រា១០ .-**

បរធនបាលទាយកមានកាតព្វកិច្ចជាសារវន្ត ដូចតទៅ÷

- ផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិជាបរធនឱ្យទៅបរធនបាលថែរក្សា និងគ្រប់គ្រងជំនួស ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ
- ចូលរួម ឬសម្រួលក្នុងកិច្ចការផ្ទេរបរធនជូនទៅបរធនបាលថែរក្សា និងគ្រប់គ្រង
- គោរពតាមខ្លឹមសារ និងលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១១ .-**

រាល់ការផ្លាស់ប្តូរបរធនបាលទាយក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសាមីបរធនបាលទាយក។

ការផ្លាស់ប្តូរនេះត្រូវកត់ត្រាក្នុងបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

### មាត្រា១២ ៖

ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាព ឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចបំពេញមុខងារជាបរធនបាលទាយកជំនួស។

### មាត្រា១៣ ៖

អត្ថគាហកៈ មានសិទ្ធិជាសារវន្ត ដូចខាងក្រោម÷

- ទទួលអត្ថប្រយោជន៍ពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ច ដែលកំណត់ដោយលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន
- ទទួលព័ត៌មានពាក់ព័ន្ធនឹងដំណើរការនៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្តឹងទាមទារឱ្យបរធនបាល គោរពកាតព្វកិច្ចនៃបរធនបាលកិច្ចហិរញ្ញវត្ថុ។

## ជំពូកទី ៤

## បរធនបាល

### មាត្រា១៤ ៖

បរធនបាលត្រូវមានសមាសភាពជាក្រុមនៃរូបវន្តបុគ្គល ក្រុមនៃនីតិបុគ្គល ក្រុមចម្រុះរវាងរូបវន្តបុគ្គល និងនីតិបុគ្គល ឬជានីតិបុគ្គលតែមួយ។

ក្នុងករណីជាក្រុម បរធនបាលត្រូវមានសមាសភាពចំនួន ០៣ (បី) រូប ឬ ០៥ (ប្រាំ) រូប ដែលជារូបវន្តបុគ្គល ឬតំណាងនីតិបុគ្គល។ នីតិបុគ្គលនីមួយៗមានសិទ្ធិចាត់តាំងតំណាងតែ ០១ (មួយ) រូបប៉ុណ្ណោះ ចូលរួមក្នុងសមាសភាពបរធនបាល។ សេចក្តីសម្រេចក្នុងកិច្ចការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុត្រូវធ្វើឡើងតាមសម្លេងភាគច្រើន។

ក្នុងករណីបរធនបាលជានីតិបុគ្គលតែមួយ បរធនបាលកិច្ចហិរញ្ញវត្ថុត្រូវគ្រប់គ្រងដោយថ្នាក់ដឹកនាំនៃនីតិបុគ្គលនោះ។

### មាត្រា១៥ ៖

រាល់ការផ្លាស់ប្តូរបរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបរធនបាលទាយក។

ការផ្លាស់ប្តូរនេះត្រូវកត់ត្រាក្នុងបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

### មាត្រា១៦ ៖

បរធនបាលមានសិទ្ធិ ដូចខាងក្រោម÷

- ទទួលលាភការ ឬកម្រៃនានា ក្នុងក្របខណ្ឌនៃការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ
- គ្រប់គ្រង និងប្រើប្រាស់បរធន ក្នុងគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- ស្វែងរកទីប្រឹក្សា ឬជំនួយការបច្ចេកទេស សម្រាប់ពង្រឹង និងពង្រីកការងារបរធនបាលកិច្ចហិរញ្ញវត្ថុ
- អភិវឌ្ឍបរធនបាលកិច្ចហិរញ្ញវត្ថុ តាមរយៈការវិនិយោគមូលនិធិបរធន ក្រោមរូបភាពជាឥណទាន ឬដើមទុន
- ចំណាយក្នុងសកម្មភាពសង្គម ស្របតាមគោលបំណងបរធនបាលកិច្ចហិរញ្ញវត្ថុ
- អនុវត្តចំណាយ និងទូទាត់ចំណូលដែលបានមកពីការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ។ ក្នុងករណីចំណូលមានចំនួនមិនគ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយ ចំនួននៃចំណាយដែលខ្វះ អាចទូទាត់ចេញពីបរធនបាន លុះត្រាតែបរធនបាលមានការបញ្ជាក់អំពីមូលហេតុច្បាស់លាស់។

**មាត្រា១៧.-**

បរធនបាលមានកាតព្វកិច្ច ដូចខាងក្រោម÷

- បំពេញមុខងារ នៅក្នុងបរធនបាលកិច្ចហិរញ្ញវត្ថុ ដោយខ្លួនឯងផ្ទាល់ ប្រកបដោយការយកចិត្តទុកដាក់ និងការប្រុងប្រយ័ត្ន ប្រៀបដូចជាបំពេញការងាររបស់ខ្លួន
- ពុំអាចផ្ទេរមុខងាររបស់ខ្លួនទៅឱ្យបុគ្គលដទៃឡើយ
- ប្រកាន់ជំហរអព្យាក្រឹត នៅចំពោះបណ្តាអត្ថគាហកៈ
- ត្រូវបែងចែកឱ្យបានច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងបរធន ដោយមិនត្រូវទាញយកផលប្រយោជន៍ខុសច្បាប់ ពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ នៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- រក្សាភាពស្មោះត្រង់ និងសុចរិតភាព នៅក្នុងការបំពេញមុខងាររបស់ខ្លួន
- ចាត់វិធានការសមស្រប ចំពោះកិច្ចការពារអំពើរំលោភលើទំនុកចិត្ត
- ផ្តល់របាយការណ៍ និងព័ត៌មានពាក់ព័ន្ធបរធនបាលកិច្ចហិរញ្ញវត្ថុទៅឱ្យបរធនបាលទាយក អត្ថគាហកៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្តល់ផលប្រយោជន៍តាមការកំណត់ទៅឱ្យអត្ថគាហកៈ
- ចុះកិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើមុខងារជាបរធនបាល
- គោរពតាមខ្លឹមសារ និងលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៨.-**

បរធនបាល មានកាតព្វកិច្ចទទួលខុសត្រូវ ចំពោះសកម្មភាព ដូចខាងក្រោម÷

- ការបាត់បង់ ឬការថយចុះនៃបរធន ដោយគ្មានមូលហេតុត្រឹមត្រូវ
- ការខកខានមិនបានបង្គរប្រាក់ចំណេញទុកនៅក្នុងបរធន
- ការប្រើប្រាស់បរធន ដោយខុសពីគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- កំហុសដែលបានប្រព្រឹត្តដោយចេតនា ឬការធ្វេសប្រហែសក្នុងការអនុវត្តមុខងាររបស់ខ្លួន

- រាល់ការចំណាយ ដែលខុសគោលដៅនៃបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា១៩.-**

បរធនបាលត្រូវមានក្រមសីលធម៌វិជ្ជាជីវៈជាសារវន្ត ដូចខាងក្រោម÷

- បំពេញភារកិច្ចដោយភាពស្មោះត្រង់
- ជំរុញឱ្យមានជោគជ័យនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈទាំងឡាយ ដោយរួមបញ្ចូលទាំងពង្រឹងប្រសិទ្ធភាពក្នុងការទាមទារសំណងជូនបរធនបាលកិច្ចហិរញ្ញវត្ថុ និងការពារការទាមទារសំណងពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ធ្វើការសម្រេចចិត្តដោយឯករាជ្យ ដោយមានការវិនិច្ឆ័យស្របតាមចំណេះដឹង ជំនាញ និងបទពិសោធន៍វិជ្ជាជីវៈ
- ជៀសវាងស្ថានភាពដែលបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ទោះដោយផ្ទាល់ ឬដោយប្រយោល ហើយធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍។

**មាត្រា២០.-**

លាភការរបស់បរធនបាល ត្រូវកំណត់ក្នុងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ ដោយផ្អែកលើគុណវុឌ្ឍិវិជ្ជាជីវៈ និងបទពិសោធន៍ការងារ។

## ជំពូកទី ៥
## ការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

**មាត្រា២១.-**

បរធនបាលត្រូវបំពេញកាតព្វកិច្ចរបាយការណ៍ ដូចខាងក្រោម÷

-អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងកិច្ចប្រជុំបរធនបាលតាមសម្លេងភាគច្រើន ដោយមានហត្ថលេខាបញ្ជាក់ពីបរធនបាលគ្រប់រូប និងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ

-ស្នើសុំពន្យារពេលពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនកាលវសាននៃថ្ងៃផ្តល់របាយការណ៍ហិរញ្ញវត្ថុ ក្នុងករណីមានការយឺតយ៉ាវ

-បំពេញបន្ថែមព័ត៌មានលើរបាយការណ៍ហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២២.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវធ្វើសវនកម្មដោយសវនករឯករាជ្យ។

ការជ្រើសរើសសវនករឯករាជ្យ ត្រូវសម្រេចនៅដើមឆ្នាំសារពើពន្ធនីមួយៗ ដោយបរធនបាល តាមការអនុម័តដោយសម្លេងភាគច្រើន។

## ជំពូកទី ៦
## ការបញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ

**មាត្រា២៣ .-**

បរធនបាលកិច្ចហិរញ្ញវត្ថុអាចត្រូវបានបញ្ចប់ក្នុងករណី ដូចខាងក្រោម÷

- ការសម្រេចដោយឆន្ទានុសិទ្ធិ ឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក
- ការមកដល់នៃកាលវសាន ដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ
- ការបំពានធ្ងន់ធ្ងររបស់បរធនបាលលើបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា២៤ .-**

ក្នុងករណីដែលបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបានបញ្ចប់ដូចមានចែងក្នុងមាត្រា២៣ ខាងលើ បរធនបាលទាយកត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី ដើម្បីគ្រប់គ្រងនិងវាយតម្លៃបរធន។

បរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបន្តអត្ថិភាពគតិយុត្ត រហូតដល់ការជម្រះបញ្ជីត្រូវបានបញ្ចប់ជាស្ថាពរ។

**មាត្រា២៥ .-**

អ្នកជម្រះបញ្ជីមានភារកិច្ច ដូចខាងក្រោម÷

- បំពេញ និងបញ្ចប់កិច្ចការដែលនៅសេសសល់របស់បរធនបាល
- ប្រមូល និងទូទាត់បំណុលដែលនៅសល់
- វាយតម្លៃបរធនដែលនៅសល់។

បរធនដែលនៅសល់ក្រោយពីការជម្រះបញ្ជី ត្រូវប្រគល់ជូនបរធនបាលទាយក ឬទុកជាទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា២៦ .-**

តម្លៃការ និងសោហ៊ុយដែលកើតចេញពីការអភិបាលបណ្ដោះអាសន្ន ឬជម្រះបញ្ជីត្រូវគិតគូរលើមូលដ្ឋាននៃអត្រាតម្លៃវិជ្ជាជីវៈ និងជាបន្ទុកស្វ័យប្រវត្តិរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ។

## ជំពូកទី ៧
## ការដោះស្រាយវិវាទ

**មាត្រា២៧ .-**

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវដោះស្រាយក្នុងក្របខណ្ឌនៃក្រុមប្រឹក្សានីតិកម្មនៃ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយការផ្សះផ្សា សម្រុះសម្រួល ឬការធ្វើសេចក្តីសម្រេច។

ចំពោះវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចហិរញ្ញវត្ថុមិនទាន់បានចុះបញ្ជី ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិអំណាចចាត់វិធានការដោះស្រាយតាមផ្លូវច្បាប់ ដើម្បីដកហូតបរធនឱ្យរដ្ឋគ្រប់គ្រងជំនួស។

**មាត្រា២៨ .-**

ភាគី ដែលមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិប្តឹងចំពោះសេចក្តីសម្រេចនេះ ក្នុងរយៈពេល ១ (មួយ) ខែ ទៅមជ្ឈត្តការ ឬតុលាការមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីការពារសេចក្តីសម្រេចលើវិវាទដែលកើតចេញពីបរធនបាលកិច្ចហិរញ្ញវត្ថុ នៅចំពោះមុខស្ថាប័នតុលាការ ក្រុមប្រឹក្សានីតិកម្មត្រូវចាត់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសមាសភាពជាមន្ត្រីជំនាញបរធនបាលកិច្ចហិរញ្ញវត្ថុ និងមន្ត្រីច្បាប់របស់ក្រសួង តាមសំណើរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា២៩ .-**

បរធនបាល ដែលគ្រប់គ្រង ឬប្រើប្រាស់បរធន ក្នុងលក្ខណៈមិនសមស្រប ឬខុសគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ឬធ្វើឱ្យបាត់បង់ តាមរយៈការលួចកិបកេង ការក្លែងបន្លំនានា ការក្លែងបន្លំរបាយការណ៍ ការក្លែងបន្លំឯកសារ ត្រូវទទួលទោសព្រហ្មទណ្ឌ ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មរដ្ឋប្បវេណី តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុមិនបានចុះបញ្ជីតាមបទប្បញ្ញត្តិជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីដកហូតឱ្យរដ្ឋគ្រប់គ្រងជំនួសនូវសមតុល្យនៃបរធនដែលបាននិងកំពុងកាន់កាប់ដោយបំពាននីតិវិធីចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី១ និងទី២ ខាងលើ ត្រូវយកមកអនុវត្តផងដែរ ចំពោះអភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជីរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣០ .-**

ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃអនុក្រឹត្យនេះ បុគ្គលដែលបាននិងកំពុងគ្រប់គ្រងបរធនត្រូវមកចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា៣១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

# ប្រកាសស្ដីពីការគ្រប់គ្រង និងការត្រួតពិនិត្យ បរធនបាលកិច្ចហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៤១ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្រកាសលេខ ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ប្រកាសលេខ ១០៨១ សហវ.ប្រក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់វិធានក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុដែលប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណងពង្រឹងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការនៃបរធនបាលកិច្ចហិរញ្ញវត្ថុសំដៅអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុដែលត្រូវបានបង្កើតឡើងដោយបរធនដែលមានប្រភពមកពីមូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ឬអនុបំណុលដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## លិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ

**ប្រការ៤.-**

បរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយលិខិតលាយលក្ខណ៍អក្សរតាមទម្រង់ដែលមានខ្លឹមសារកំណត់ជាមូលដ្ឋាន ដូចខាងក្រោម÷

- ឈ្មោះ និងអាសយដ្ឋានបរធនបាលកិច្ចហិរញ្ញវត្ថុ
- គោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- លិខិតយុត្តិការបញ្ជាក់បរធនមានជាអាទិ៍÷
    - ការបញ្ជាក់ពីប្រភពនៃបរធន
    - សមតុល្យមូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ឬអនុបំណុលជាប្រាក់រៀល ឬដុល្លារអាមេរិក
- ថិរវេលានៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- សិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ
- ក្រមសីលធម៌វិជ្ជាជីវៈ បរធនបាល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ
- លាភការរបស់បរធនបាល
- លក្ខខណ្ឌនៃការបញ្ចប់នៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- ការចាត់ចែងបរធន នៅពេលបរធនបាលកិច្ចហិរញ្ញវត្ថុត្រូវបានបញ្ចប់
- លក្ខខណ្ឌនៃការកែប្រែបរធនបាលកិច្ចហិរញ្ញវត្ថុ
- គោលដៅនៃការវិនិយោគទ្រព្យសម្បត្តិរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- បញ្ជីបរធនដែលជាកម្មវត្ថុនៃបរធនបាលកិច្ចហិរញ្ញវត្ថុ

- និងធាតុផ្សំផ្សេងទៀត ដែលតម្រូវតាមគោលបំណងនៃបរធនបាលទាយក។

គំរូលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចបំពេញមុខងារជាបរធនបាលទាយកជំនួស ដើម្បីបំពេញលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ តាមសំណើរបស់បរធនបាលក្នុងករណីដូចខាងក្រោម÷

- បរធនបាលទាយកដើម ពុំអាចកំណត់អត្តសញ្ញាណបាន
- បរធនបាលទាយកដើម ទទួលមរណភាពដោយពុំមានសន្ទស់ទាយាទ
- បរធនបាលទាយកដើម លះបង់ ឬត្រូវបានសន្មត់ថាលះបង់បរធន។

ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ បរធនបាលអាចស្នើសុំចុះលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញបែបបទចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ដោយអនុលោមតាមស្មារតីនៃកិច្ចព្រមព្រៀងដែលបរធនបាលបានចុះជាមួយបរធនបាលទាយកដើម ឬលិខិតគតិយុត្តផ្សេងទៀត ។

## ជំពូកទី ៣
## ការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ

**ប្រការ៦.-**

បុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបំពេញនឹងប្រគល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវសំណុំឯកសារស្នើសុំចុះបញ្ជីត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

ការស្នើសុំចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បរធនបាលទាយក ឬបរធនបាលត្រូវភ្ជាប់មកជាមួយនូវលិខិតពាក់ព័ន្ធ ដូចខាងក្រោម÷

**ក. ក្នុងករណីបរធនបាលជារូបវន្តបុគ្គល**

- លិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ
- កិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើមុខងារជាបរធនបាល
- ប្រវត្តិរូបសង្ខេបដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ
- លិខិតថ្កោលទោសរបស់បរធនបាល និងបរធនបាលទាយក

**ខ. ក្នុងករណីបរធនបាលជានីតិបុគ្គល ក្រុមនៃនីតិបុគ្គល ឬក្រុមចម្រុះរវាងរូបវន្តបុគ្គល និងនីតិបុគ្គល**

បរធនបាលជានីតិបុគ្គល ក្រុមនៃនីតិបុគ្គល ឬក្រុមចម្រុះរវាងរូបវន្តបុគ្គល និងនីតិបុគ្គលត្រូវបំពេញឯកសារដូចមានចែងក្នុងចំណុច "ក" នៃប្រការ៦ និងបន្ថែមឯកសារជាសារវន្ត ដូចខាងក្រោម÷

- លិខិត និងលក្ខន្តិកៈ ដែលបានចុះបញ្ជី នៅក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ឬក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- លិខិតចម្លងនៃអាជ្ញាបណ្ណរបស់ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ៧.-**

បរធនបាល ឬបរធនបាលទាយក ត្រូវមកចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាអះអាង និងទទួលខុសត្រូវអំពីភាពត្រឹមត្រូវ និងភាពពិតប្រាកដនៃសំណុំលិខិតស្នើសុំចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**ប្រការ៨.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចទទួលចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ បន្ទាប់ទទួលបានសំណើដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី។

ក្រសួងអាចបដិសេធចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់តាមរយៈលិខិតផ្ញើទៅម្ចាស់សំណើ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសំណើ។

ក្នុងករណីសំណុំលិខិតស្នើសុំចុះបញ្ជី ពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់រយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង ដើម្បីកែតម្រូវឯកសារ និងបំពេញបន្ថែមលក្ខខណ្ឌដែលខ្វះចន្លោះ។ ហួសរយៈពេលកំណត់នេះ ពាក្យស្នើសុំចុះបញ្ជីត្រូវចាត់ទុកថាបោះបង់ចោល។

បន្ទាប់ពីសម្រេចទទួលចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់វិញ្ញាបនបត្រចុះបញ្ជីជូនបរធនបាល ឬបរធនបាលទាយកដែលជាម្ចាស់សំណើចុះបញ្ជី។

## ជំពូកទី ៤
## វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ

**ប្រការ៩.-**

វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ មានសុពលភាព សម្រាប់ចិរវេលាដែលត្រូវបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ។

**ប្រការ១០.-**

រាល់ការផ្លាស់ប្តូរដែលមានការពាក់ព័ន្ធនឹងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ បរធនបាលទាយក ឬបរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតពាក់ព័ន្ធសម្រាប់កត់ត្រាការផ្លាស់ប្តូរនេះ ក្នុងបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**ប្រការ១១.-**

បរធនបាលទាយក ឬបរធនបាល ត្រូវបង់កម្រៃរដ្ឋបាលចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល សម្រាប់ការស្នើសុំចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ព្រមទាំងត្រូវបង់សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំចំនួន ២.០០០.០០០ (ពីរលាន) រៀល នៅមុនដំណាច់ខែមករា រៀងរាល់ឆ្នាំ។

ការស្នើសុំផ្លាស់ប្តូរបរធនបាល ឬលិខិតបរធនបាលកិច្ច ឬសំណុំលិខិតផ្សេងៗនៃការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុត្រូវបង់សោហ៊ុយចំនួន ២.០០០.០០០ (ពីរលាន) រៀល។

សោហ៊ុយវិញ្ញាបនបត្រ និងកម្រៃរដ្ឋបាល ដូចមានចែងក្នុងកថាខណ្ឌខាងលើត្រូវបង់ទៅក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិនៅធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២.-**

បរធនបាលទាយក ឬបរធនបាល ត្រូវធ្វើការបង់វិភាគទាន ០,៥% (សូន្យក្បៀសប្រាំភាគរយ) ក្នុង ០១ (មួយ) ឆ្នាំ លើសមតុល្យនៃបរធនប្រចាំឆ្នាំ សម្រាប់មូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ។

វិភាគទាននេះត្រូវបង់ក្នុងរយៈពេល០៣ (បី) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ ឬរយៈពេលផ្សេងទៀតដែលសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលបានចុះបញ្ជីក្នុងខែនៃឆ្នាំ បរធនបាល ឬបរធនបាលទាយក ត្រូវបង់វិភាគទាននេះ តាមការគណនាលើសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំសារពើពន្ធ។

នីតិវិធីនៃការបង្កើត និងប្រើប្រាស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ៥
## ការដកហូតវិញ្ញាបនបត្របរធនបាលកិច្ចហិរញ្ញវត្ថុ

**ប្រការ១៣.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចដកហូតវិញ្ញាបនបត្របរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងករណីណាមួយដូចខាងក្រោម÷

- បរធនបាល ឬ បរធនបាលទាយកផ្តល់ព័ត៌មានមិនពិត មិនជាក់លាក់ ឬបិទបាំង ឬមិនបង្ហាញការពិតនៅក្នុងពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បរធនបាល ឬបរធនបាលទាយក បានប្រើប្រាស់ប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងគោលបំណងនៃការសម្អាតប្រាក់ និង/ឬ ហិរញ្ញប្បទានភេរវកម្ម ឬឧក្រិដ្ឋកម្ម
- បរធនត្រូវបានប្រើប្រាស់ខុសពីគោលបំណងដើម និង/ឬ ហួសថេរវេលារបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- បរធនមានសមតុល្យអវិជ្ជមាន
- បរធនបាល ឬបរធនបាលទាយក មិនបានបង់កម្រៃវិភាគទានប្រចាំឆ្នាំ អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- បរធនបាល ខកខានមិនបានអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១៧ មាត្រា១៨ មាត្រា១៩ និងមាត្រា២១ នៃអនុក្រឹត្យស្តីពី បរធនបាលកិច្ចហិរញ្ញវត្ថុ
- បរធនបាល ឬបរធនបាលទាយក បន្តធ្វើប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុដោយបំពាន ឬមិនអនុលោមតាមបទប្បញ្ញត្តិជាធរមាន បន្ទាប់ពីទទួលការណែនាំ ឬទទួលរងការពិន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៤.-**

ក្រោយពីការដកហូតវិញ្ញាបនបត្រដូចមានចែងក្នុងប្រការ១៣ ក្រសួងមានសិទ្ធិអនុវត្តនីតិវិធីនៃការបញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុដូចមានចែងនៅក្នុងជំពូកទី៦ នៃអនុក្រឹត្យ។

**ប្រការ១៥.-**

បរធនបាល ឬបរធនបាលទាយក ដែលមិនសុខចិត្ត និងសេចក្តីសម្រេចដកហូតវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ មានសិទ្ធិប្តឹងអំពីសេចក្តីសម្រេចនេះ ទៅតាមយន្តការដោះស្រាយវិវាទដូចមានចែងក្នុងជំពូកទី៧ នៃអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ។

## ជំពូកទី ៦
## ការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

**ប្រការ១៦.-**

បរធនបាលត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុង មាត្រា១៧ មាត្រា១៨ និងមាត្រា២១ នៃអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ។

បរធនបាលត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងរបាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ និងព័ត៌មានផ្សេងៗទៀតមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាំបាច់។

**ប្រការ១៧._**

បញ្ញត្តិករបរធនបាលកិច្ចហិរញ្ញវត្ថុមានសិទ្ធិ ដូចខាងក្រោម÷

- ត្រួតពិនិត្យដល់ទីកន្លែងលើឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ចតាមការចាំបាច់។
- ជួលអ្នកឯកទេសផ្នែកគណនេយ្យ ឬសវនករឱ្យចូលរួមក្នុងការធ្វើកិច្ចប្រតិបត្តិការត្រួតពិនិត្យ ក្នុងករណីចាំបាច់ និងមានសិទ្ធិធ្វើការថតចម្លងឯកសារពាក់ព័ន្ធនានាតាមតម្រូវការដើម្បីធ្វើការត្រួតពិនិត្យ។ ចំពោះការចំណាយលើអ្នកឯកទេសផ្នែកគណនេយ្យ និងសវនកម្មនេះជាបន្ទុករបស់បរធនបាលកិច្ចហិរញ្ញវត្ថុ ។

**ប្រការ១៨._**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលបំពេញការងារតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនត្រូវបានប្តឹងចំពោះការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ប្រសិនបើការបំពេញការងារនោះត្រូវបានធ្វើឡើងដោយសុចរិតភាព។

## ជំពូកទី ៧
## ពិន័យអន្តរកាល

**ប្រការ១៩._**

ការពិន័យអន្តរកាល ត្រូវបានកំណត់ដូចខាងក្រោម÷

- ករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១១ បរធនបាល ឬបរធនបាលទាយកត្រូវទទួលរងពិន័យអន្តរកាលចំនួន ១០០.០០០ (មួយរយពាន់) រៀល ក្នុង ០១ (មួយ) ថ្ងៃ
- ចំពោះការយឺតយ៉ាវក្នុងការបង់វិភាគទានប្រចាំឆ្នាំ ដូចមានចែងក្នុងប្រការ១២ តិចជាង៣០ (សាមសិប) ថ្ងៃ បរធនបាល ឬបរធនបាលទាយក ត្រូវបង់ប្រាក់ផាកពិន័យចំនួន ២% (ពីរភាគរយ) លើចំនួនប្រាក់ដែលត្រូវបង់។ ក្នុងករណីយឺតយ៉ាវលើសពី ៣០ (សាមសិប) ថ្ងៃ បរធនបាល ឬបរធនបាលទាយកត្រូវបង់ប្រាក់ផាកពិន័យចំនួន ២០% (ម្ភៃភាគរយ) លើចំនួនប្រាក់ដែលត្រូវបង់។

ចំពោះប្រាក់ដែលបានមកពីការផាកពិន័យ ត្រូវបង់ទៅគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិ នៅធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**ប្រការ២០._**

បរធនបាលកិច្ចហិរញ្ញវត្ថុដែលខកខានមិនបានចុះបញ្ជី ជាកម្មវត្ថុនៃការស៊ើបអង្កេតពីការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងចាត់វិធានការតាមផ្លូវច្បាប់ ដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា២៩ នៃអនុក្រឹត្យ។

**ប្រការ២១._**

បុគ្គលដែលប្រព្រឹត្តអំពើវិលោភលើទំនុកចិត្ត ឆបោក ក្លែងបន្លំ ផ្តល់ព័ត៌មានមិនពិត ទម្លាយការសំងាត់វិជ្ជាជីវៈ និងបំផ្លិចបំផ្លាញឯកសារ ត្រូវទទួលទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ២២.-**

ចំពោះបទល្មើសទាំងឡាយណាដែលពុំមានកំណត់នៅក្នុងប្រកាសនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**ប្រការ២៣.-**

បទប្បញ្ញត្តិ ឬលិខិតបទដ្ឋានទាំងឡាយណាដែលៗផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ២៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៥

## ប្រកាសស្តីពីការកែសម្រួលប្រការ១២ នៃប្រកាស លេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យ បរធនបាលកិច្ចហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ [illegible]

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ១២ នៃប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្រកាសលេខ ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ប្រកាសលេខ ១០៨១ សហវ.ប្រក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855 23 427 798

# សម្រេច

**ប្រការមួយ.–**

ប្រការ១២ នៃប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបានកែសម្រួលដូចខាងក្រោម÷

**ប្រការ១២ ថ្មី.–**

បរធនបាលទាយក ឬបរធនបាល ត្រូវបង់វិភាគទានសម្រាប់មូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ លើសមតុល្យនៃបរធនប្រចាំឆ្នាំ ដូចបានកំណត់ក្នុងតារាងខាងក្រោម÷

| ចំនួនបរធនសរុបប្រចាំឆ្នាំ (ដុល្លារអាមេរិក) | អត្រាបង់វិភាគទាន |
|---|---|
| តិចជាងឬស្មើ ១៥.០០០.០០០ | ០,៥% |
| ចាប់ពី ១៥.០០០.០០១ ដល់ ២៥.០០០.០០០ | ០,៤% |
| ចាប់ពី ២៥.០០០.០០១ ដល់ ៤០.០០០.០០០ | ០,៣% |
| ចាប់ពី ៤០.០០០.០០១ ដល់ ១០០.០០០.០០០ | ០,២៥% |
| លើសពី ១០០.០០០.០០០ | ០,២% |

វិភាគទាននេះត្រូវបង់ក្នុងរយៈពេល០៣ (បី) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ ឬរយៈពេលផ្សេងទៀតដែលសម្រេចដោយអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលបានចុះបញ្ជីក្នុងខែនៃឆ្នាំ បរធនបាល ឬបរធនបាលទាយក ត្រូវបង់វិភាគទាននេះ តាមការគណនាលើសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំសារពើពន្ធ។

**ប្រការពីរ.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការបី.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០១៦

អូន ព័ន្ធមុនីរ័ត្ន

<u>កន្លែងទទួល÷</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៦

# ប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

G.3035

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៨៥៦ សហវ.ប្រក

# ប្រកាស

## ស្តីពី

## តម្លៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- បានឃើញប្រកាសលេខ ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវា និងការប្រមូលកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពីចំនួនកម្រៃសេវា និងបែបបទនៃការបង់កម្រៃសេវាពាក់ព័ន្ធការចុះបញ្ជីបរធនបាលកិច្ច។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចដែលត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## កម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច

**ប្រការ៤.-**

សុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច÷

- ត្រូវកំណត់តាមថិរវេលានៃលិខិតបរធនបាលកិច្ច ឬ
- ត្រូវកំណត់ថិរវេលា ៥(ប្រាំ) ឆ្នាំ ក្នុងករណីលិខិតបរធនបាលកិច្ចមានថិរវេលាកំណត់លើសពី ៥(ប្រាំ) ឆ្នាំ។

**ប្រការ៥.-**

បរធនដែលជាចលនវត្ថុ ឬអចលនវត្ថុ ត្រូវទទួលការវាយតម្លៃជាសាច់ប្រាក់ច្បាស់លាស់ដោយអ្នកជំនាញវិជ្ជាជីវៈលើវិស័យនោះដែលត្រូវបានទទួលស្គាល់ដោយបញ្ញត្តិករពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវចុះបញ្ជីសារពើភណ្ឌនៃបរធន ហើយត្រូវចុះហត្ថលេខាដោយបរធនបាលទាយក ឬបរធនបាលទាយកជំនួស។

**ប្រការ៦.-**

សម្រាប់ការស្នើសុំចុះបញ្ជីបរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលត្រូវបង់កម្រៃរដ្ឋបាល និងសោហ៊ុយវិញ្ញាបនបត្រដូចខាងក្រោម÷

គិតជារៀល

| ល.រ | តម្លៃនៃបរធន | កម្រៃរដ្ឋបាល | សោហ៊ុយ វិញ្ញាបនបត្រប្រចាំឆ្នាំ |
|---|---|---|---|
| **បរធនបាលកិច្ចពាណិជ្ជកម្ម** | | | |
| ១ | ក្រោម ៨០០ ០០០ ០០០ | ២ ០០០ ០០០ | ៣ ០០០ ០០០ |
| ២ | ចាប់ពី ៨០០ ០០០ ០០០ ដល់ ៤ ០០០ ០០០ ០០០ | ៣ ០០០ ០០០ | ៥ ០០០ ០០០ |
| ៣ | លើសពី ៤ ០០០ ០០០ ០០០ ដល់ ២០ ០០០ ០០០ ០០០ | ៥ ០០០ ០០០ | ៧ ០០០ ០០០ |
| ៤ | លើសពី ២០ ០០០ ០០០ ០០០ ដល់ ៤០ ០០០ ០០០ ០០០ | ៧ ០០០ ០០០ | ៩ ០០០ ០០០ |
| ៥ | លើសពី ៤០ ០០០ ០០០ ០០០ ដល់ ៨០ ០០០ ០០០ ០០០ | ៩ ០០០ ០០០ | ១៣ ០០០ ០០០ |
| ៦ | លើសពី ៨០ ០០០ ០០០ ០០០ ដល់ ១២០ ០០០ ០០០ ០០០ | ១៣ ០០០ ០០០ | ១៧ ០០០ ០០០ |
| ៧ | លើសពី ១២០ ០០០ ០០០ ០០០ ដល់ ១៦០ ០០០ ០០០ ០០០ | ១៧ ០០០ ០០០ | ២១ ០០០ ០០០ |
| ៨ | លើសពី ១៦០ ០០០ ០០០ ០០០ ដល់ ២០០ ០០០ ០០០ ០០០ | ២១ ០០០ ០០០ | ២៥ ០០០ ០០០ |
| ៩ | លើសពី ២០០ ០០០ ០០០ ០០០ ឡើងទៅ | ២៥ ០០០ ០០០ | ២៩ ០០០ ០០០ |

**ប្រការ៧.-**

សម្រាប់ការស្នើសុំចុះបញ្ជីបរធនបាលកិច្ចសាធារណៈ ឬបរធនបាលកិច្ចសង្គម បរធនបាលត្រូវបង់កម្រៃរដ្ឋបាល និងសោហ៊ុយវិញ្ញាបនបត្រដូចខាងក្រោម៖

គិតជារៀល

| ល.រ | តម្លៃនៃបរធន | កម្រៃរដ្ឋបាល | សោហ៊ុយ វិញ្ញាបនបត្រប្រចាំឆ្នាំ |
|---|---|---|---|
| **បរធនបាលកិច្ចសាធារណៈ ឬបរធនបាលកិច្ចសង្គម** | | | |
| ១ | ក្រោម ៤០០ ០០០ ០០០ | ៥០០ ០០០ | ១ ០០០ ០០០ |
| ២ | ចាប់ពី ៤០០ ០០០ ០០០ ដល់ ៤ ០០០ ០០០ ០០០ | ១ ០០០ ០០០ | ២ ០០០ ០០០ |
| ៣ | លើសពី ៤ ០០០ ០០០ ០០០ ដល់ ២០ ០០០ ០០០ ០០០ | ២ ០០០ ០០០ | ៣ ០០០ ០០០ |

| | | | |
|---|---|---|---|
| ៤ | លើសពី ២០ ០០០ ០០០ ០០០ ដល់ ៤០ ០០០ ០០០ ០០០ | ៣ ០០០ ០០០ | ៤ ០០០ ០០០ |
| ៥ | លើសពី ៤០ ០០០ ០០០ ០០០ ដល់ ៨០ ០០០ ០០០ ០០០ | ៤ ០០០ ០០០ | ៦ ០០០ ០០០ |
| ៦ | លើសពី ៨០ ០០០ ០០០ ០០០ ដល់ ១២០ ០០០ ០០០ ០០០ | ៦ ០០០ ០០០ | ៨០០០ ០០០ |
| ៧ | លើសពី ១២០ ០០០ ០០០ ០០០ ដល់ ១៦០ ០០០ ០០០ ០០០ | ៨ ០០០ ០០០ | ១០ ០០០ ០០០ |
| ៨ | លើសពី ១៦០ ០០០ ០០០ ០០០ ដល់ ២០០ ០០០ ០០០ ០០០ | ១០ ០០០ ០០០ | ១២ ០០០ ០០០ |
| ៩ | លើសពី ២០០ ០០០ ០០០ ០០០ ឡើងទៅ | ១២ ០០០ ០០០ | ១៤ ០០០ ០០០ |

**ប្រការ៨..**

សម្រាប់ការស្នើសុំចុះបញ្ជីបរធនបាលកិច្ចបុគ្គល បរធនបាលត្រូវបង់កម្រៃរដ្ឋបាល និងសោហ៊ុយវិញ្ញាបនបត្រដូចខាងក្រោម÷

**គិតជារៀល**

| ល.រ | តម្លៃនៃបរធន | កម្រៃរដ្ឋបាល | សោហ៊ុយ វិញ្ញាបនបត្រប្រចាំឆ្នាំ |
|---|---|---|---|
| **បរធនបាលកិច្ចបុគ្គល** | | | |
| ១ | ក្រោម ៨០០ ០០០ ០០០ | ១ ០០០ ០០០ | ២ ០០០ ០០០ |
| ២ | ចាប់ពី ៨០០ ០០០ ០០០ ដល់ ៤ ០០០ ០០០ ០០០ | ២ ០០០ ០០០ | ៤ ០០០ ០០០ |
| ៣ | លើសពី ៤ ០០០ ០០០ ០០០ ដល់ ២០ ០០០ ០០០ ០០០ | ៤ ០០០ ០០០ | ៦ ០០០ ០០០ |
| ៤ | លើសពី ២០ ០០០ ០០០ ០០០ ដល់ ៤០ ០០០ ០០០ ០០០ | ៦ ០០០ ០០០ | ៨ ០០០ ០០០ |
| ៥ | លើសពី ៤០ ០០០ ០០០ ០០០ ដល់ ៨០ ០០០ ០០០ ០០០ | ៨ ០០០ ០០០ | ១២ ០០០ ០០០ |
| ៦ | លើសពី ៨០ ០០០ ០០០ ០០០ ដល់ ១២០ ០០០ ០០០ ០០០ | ១២ ០០០ ០០០ | ១៦ ០០០ ០០០ |
| ៧ | លើសពី ១២០ ០០០ ០០០ ០០០ ដល់ ១៦០ ០០០ ០០០ ០០០ | ១៦ ០០០ ០០០ | ២០ ០០០ ០០០ |
| ៨ | លើសពី ១៦០ ០០០ ០០០ ០០០ ដល់ ២០០ ០០០ ០០០ ០០០ | ២០ ០០០ ០០០ | ២៤ ០០០ ០០០ |
| ៩ | លើសពី ២០០ ០០០ ០០០ ០០០ ឡើងទៅ | ២៤ ០០០ ០០០ | ២៨ ០០០ ០០០ |

**ប្រការ៩.-**

បរធនបាលត្រូវបង់សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំ ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅមុនដំណាច់ខែឧសភានៃឆ្នាំនីមួយៗ។

**ប្រការ១០.-**

ការស្នើសុំគោលការណ៍អនុញ្ញាតជាមុន ត្រូវបង់សោហ៊ុយរដ្ឋបាលចំនួន ៥ ០០០ ០០០ (ប្រាំលាន) រៀល។

**ប្រការ១១.-**

ការផ្លាស់ប្តូរគោលបំណងនៃបរធនបាលកិច្ច ឬការផ្លាស់ប្តូរណាមួយដែលមានការពាក់ព័ន្ធនឹងសំណុំលិខិតបរធនបាលកិច្ច ឬសំណុំលិខិតផ្សេងៗនៃការចុះបញ្ជីបរធនបាលកិច្ចត្រូវបង់សោហ៊ុយចំនួន ៥ ០០០ ០០០ (ប្រាំលាន) រៀល។

**ប្រការ១២.-**

កម្រៃរដ្ឋបាល និងសោហ៊ុយវិញ្ញាបនបត្រ ត្រូវបង់ទៅក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិនៅធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៣.-**

សម្រាប់ការស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ច បរធនបាលត្រូវបង់កម្រៃដូចមានចែងក្នុងប្រការ៦ ប្រការ៧ និងប្រការ៨ នៃប្រកាសនេះ។

**ប្រការ១៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិពិចារណាលើកលែងការបង់កម្រៃរដ្ឋបាល និង/ឬ សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំ ដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ សម្រាប់បរធនបាលកិច្ចសាធារណៈ និងបរធនបាលកិច្ចសង្គម តាមរយៈការស្នើសុំរបស់មន្ត្រីទទួលបន្ទុកកិច្ចការបរធនបាលកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ៣

## ពិន័យអន្តរការណ៍

**ប្រការ១៥.-**

បរធនបាលដែលមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ ត្រូវទទួលរងការពិន័យអន្តរការណ៍ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល បូកបន្ថែម ២ (ពីរ) ភាគរយលើចំនួនសោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំដែលត្រូវបង់។ ក្នុងករណីយឺតយ៉ាវលើសពី ៣០ (សាមសិប) ថ្ងៃ បរធនបាលត្រូវទទួលរងការពិន័យអន្តរកាលចំនួន ២ ០០០ ០០០ (ពីរលាន) រៀល បូកបន្ថែម ២៥ (ម្ភៃប្រាំ) ភាគរយ លើចំនួនសោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំដែលត្រូវបង់។

ចំពោះប្រាក់ដែលបានមកពីការផាកពិន័យ ត្រូវបង់ទៅគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិ នៅធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**ប្រការ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី - ខេត្ត
- ដូចប្រការ ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ